# ក្របខ័ណ្ឌអភិវឌ្ឍន៍ជនជាតិភាគតិច

ជំហានឯកសារៈ សេចក្តីព្រាង
គម្រោងលេខៈ 53240-003
ខែតុលា ឆ្នាំ២០២២

# គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែច្រវាក់តម្លៃសត្វ (ប្រទេសកម្ពុជា)

**រៀបចំដោយៈ** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

## **អត្រាប្តូរប្រាក់**

**អរូបិយប័ណ្ណមានតម្លៃស្មើ**

(គិត្រឹមថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០២២)

| | | |
|---|---|---|
| ឯកតារូបិយប័ណ្ណ | – | រៀល (ខ្មែរ) |
| ១.0 រៀល | = | 0.000២៤ ដុល្លារអាមេរិក |
| ១.0 ដុល្លារអាមេរិក | = | ៤,១១៧.៤៦ រៀល |

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ADB | – | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AI | – | ការបង្កាត់ពូជសិប្បនិម្មិត |
| AMR | – | ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ |
| APHIS | – | ប្រព័ន្ធព័ត៌មានសុខភាពសត្វ និងផលិតកម្មសត្វ |
| BSL2 | – | ជីវសុវត្ថិភាពកម្រិត ២ |
| CLHVCIP | – | គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែរតម្លៃសត្វ |
| DCZs | – | តំបន់ត្រួតពិនិត្យជំងឺ |
| DOAHP | – | ការិយាល័យសុខភាពសត្វ និងបសុព្យាបាលស្រុក |
| EM | – | ជនជាតិភាគតិច |
| EMDP | – | ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច |
| FMD | – | ជំងឺអុតក្តាម |
| FPIC | – | គោលការណ៍ព្រមព្រៀងដោយសេរីជាមុន និងផ្អែកលើព័ត៌មានពេញលេញ |
| GAHP | – | ការអនុវត្តការចិញ្ចឹមសត្វល្អ |
| GDAHP | – | អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| GLP | – | ការអនុវត្តមន្ទីរពិសោធន៍ល្អ |
| GMP | – | ការអនុវត្តផលិតកម្មល្អ |
| GMS | – | មហាអនុតំបន់ទន្លេមេគង្គ |
| HACCP | – | ស្តង់ដាសុវត្ថិភាពផលិតផល |
| ICT | – | បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ |
| ISO | – | អង្គការស្តង់ដាអន្តរជាតិ |
| Lao PDR | – | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ |
| LEI | – | ប្រព័ន្ធគ្រប់គ្រងរោគរាតត្បាតសត្វ និងព័ត៌មានវិទ្យា |
| LIMS | – | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ទីរពិសោធន៍ |
| LITS | – | ប្រព័ន្ធកំណត់អត្តសញ្ញាណសត្វ និងការតាមដានសត្វ |
| LPQCC | – | ការត្រួតពិនិត្យគុណភាព និងការចេញវិញ្ញាបនបត្រផលិតផលសត្វ |
| LPS | – | សេវាផលិតកម្មសត្វ |
| LSD | – | ជំងឺដុំពកស្បែក |
| MEF | – | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| MISTI | – | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MOE | – | ក្រសួងបរិស្ថាន |
| NAHPRI | – | វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ |
| NCBC | – | មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ |
| NVVC | – | មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ |
| O&M | – | ប្រតិបត្តិការ និងការគ្រប់គ្រង |
| PAE | – | សហគ្រាសគ្រប់គ្រងដោយរដ្ឋ |
| PCP | – | មាគ៌ាត្រួតពិនិត្យវឌ្ឍនភាព |
| POAHP | – | ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត |
| PPP | – | ភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| SIA | – | ការវាយតម្លៃហេតុប៉ះពាល់ផ្នែកសង្គម |
| SPS | – | សេចក្តីថ្លែងគោលនយោបាយការពារ |
| TRTA | – | ជំនួយផ្នែកបច្ចេកទេសដំណាក់កាលចាប់ផ្តើម |
| TVET | – | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| VAHW | – | ភ្នាក់ងារសុខភាពសត្វភូមិ |

**ចំណាំ**

នៅក្នុងរបាយការណ៍នេះ "$" សំដៅលើក្រដាសប្រាក់ដុល្លារសហរដ្ឋអាមេរិក

ក្របខ័ណ្ឌអភិវឌ្ឍន៍ជនជាតិភាគតិចនេះ គឺជាឯកសាររបស់ប្រទេសទទួលកម្ចី។ ទស្សនៈដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ ឬបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឡើយ ហើយអាចជាលក្ខណៈបឋម។ សូមអ្នកអាចយកចិត្តទុកដាក់ទៅលើផ្នែក "លក្ខខណ្ឌនៃការប្រើប្រាស់" ចំពោះគេហទំព័រនេះ។

ក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រ ការផ្តល់ហិរញ្ញប្បទានដល់គម្រោងណាមួយរបស់ប្រទេសណាមួយ ឬដោយការជ្រើសរើសទុកជាមុន ឬយោងទៅលើទឹកដី ឬទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយនៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី គ្មានបំណងធ្វើការវិនិច្ឆ័យណាមួយទៅលើស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពផ្សេងទៀតនៃទឹកដី ឬតំបន់ណាមួយ។

# មាតិកា


I. **សេចក្តីផ្តើម** 6
- ក. សាវតាគម្រោង 6
- ខ. ផលជះ សមិទ្ធិផល និងលទ្ធផល 6
- គ. ការចាត់ថ្នាក់ផ្នែកកិច្ចគាំពារ 16
- ឃ. គោលបំណងនៃក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុមជនជាតិភាគតិច 17
- ង. គោលការណ៍ក្របខ័ណ្ឌ 18
- ច. ជាតិសាសន៍នៅក្នុងប្រទេសកម្ពុជា 19

II. **គោលបំណង និងក្របខ័ណ្ឌគោលនយោបាយ** 21
- ក. គោលនយោបាយការពារជនជាតិដើមភាគតិចនៃធនាគារអភិវឌ្ឍន៍អាស៊ី 21
- ខ. គោលនយោបាយពាក់ព័ន្ធរបស់ប្រទេសកម្ពុជា 23
- គ. គម្លាតផ្នែកគោលនយោបាយរវាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងរាជរដ្ឋាភិបាលកម្ពុជា 24

III. **ការកំណត់វិសាលភាព និងការពិនិត្យពិច័យអនុគម្រោង** 31
- ក. ការវាយតម្លៃហេតុប៉ះពាល់សង្គម 33

IV. **ការរៀបចំផែនការសម្រាប់ជនជាតិភាគតិច** 36
- ក. តារាងផលប៉ះពាល់ដោយសារគម្រោង 37
- ខ. គោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌអភិវឌ្ឍន៍ជនជាតិភាគតិច 45
- គ. ការពិគ្រោះយោបល់ និងការចូលរួមពីភាគីពាក់ព័ន្ធ 46
- ឃ. ការចងក្រងឯកសារនៃដំណើរការពិគ្រោះយោបល់ 50
- ង. ដំណោះស្រាយចំពោះគម្លាតយេនឌ័រ 51

V. **យន្តការដោះស្រាយបណ្តឹងតវ៉ា** (**ឬបណ្តឹងសាទុក្ខ**) 52

VI. **ការរៀបចំស្ថាប័នរបស់គម្រោង** CLHVCIP 54
- ក. ថ្នាក់ជាតិ 54
- ខ. ការរៀបចំការអនុវត្តផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP) 56
- គ. ថ្នាក់ខេត្ត 56
- ឃ. ថ្នាក់ស្រុក 57
- ង. ទីប្រឹក្សា 57

VII. **ការរៀបចំការត្រួតពិនិត្យតាមដាន និងការរាយការណ៍** 57
- ក. សូចនាករ 58

VIII. **ថវិកា និងការផ្តល់ហិរញ្ញប្បទាន** 59

**ឧបសម្ព័ន្ធ** 1. បញ្ជីត្រួតពិនិត្យជនជាតិភាគតិច 62

**ឧបសម្ព័ន្ធ** 2. ទស្សនទាន និងវិធីសាស្ត្រក្នុងការវាយតម្លៃហេតុប៉ះពាល់សង្គម 65

**ឧបសម្ព័ន្ធទី** 3. ទម្រង់ផែនការអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច (IPDP) 70

**ឧបសម្ព័ន្ធទី** 4. គំរូឧទាហរណ៍នៃការពិភាក្សាជាក្រុម (FGD) ដែលបានសម្របសម្រួលក្នុងអំឡុងពេលចុះត្រួតពិនិត្យផ្នែកបច្ចេកទេស TRTA ទីតាំង៖ ភូមិបឹងត្រាវី ឃុំស្ពោ ស្រុកកងមាស ខេត្តកំពង់ចាម 73

**ឧបសម្ព័ន្ធទី** 5. សង្ខេបបទសម្ភាសន៍រវាងអ្នកជំនាញ ជាមួយប្រធានសហគមន៍ចាម (ខេត្តកំពង់ចាម ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២) 76

# បញ្ជីតារាង

តារាងទី 1. ម៉ាទ្រិចនៃភាពខុសគ្នាផ្នែកគោលនយោបាយ ........ 26
តារាងទី 2. ផលប៉ះពាល់ដោយសារគម្រោង ........ 38
តារាងទី 3. សកម្មភាពនានានៅក្រោមផែនការអភិវឌ្ឍន៍ជនជាតិភាគតិច ........ 45
តារាងទី 4. ផែនការពិគ្រោះយោបល់ ........ 47
តារាងទី 5. ខ្ទង់ចំណាយសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ជនជាតិភាគតិច ........ 60

# បញ្ជីរូបភាព

រូបភាពទី 1. ទីតាំងរស់នៅជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច ........ 21

# I. សេចក្តីផ្តើម

## ក. សាវតាគម្រោង

១. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានអនុម័តលើជំនួយផ្នែកបច្ចេកទេសដំណាក់កាលចាប់ផ្តើម (TRTA) សម្រាប់គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែប្រវាក់តម្លៃសត្វ នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២០។ គម្រោងនេះត្រូវបានចុះបញ្ជីជាអាទិភាពនៅក្នុង *យុទ្ធសាស្ត្រលើកកម្ពស់ខ្សែប្រវាក់តម្លៃកសិផលដែលមានសុវត្ថិភាព និងមានមេត្រីភាពចំពោះបរិស្ថាននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ* ដែលគាំទ្រដោយរដ្ឋមន្ត្រីកសិកម្មនៃមហាអនុតំបន់ទន្លេមេគង្គ ក្នុងខែកញ្ញា ឆ្នាំ២០១៧។ គោលគំនិតនៃគម្រោងនេះ ត្រូវបានបង្កើតឡើងតាមរយៈកិច្ចពិគ្រោះយោបល់នៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ រួមទាំងប្រទេសកម្ពុជា កាលពីចន្លោះខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០១៩។ គោលគំនិតនេះ ត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមការងារមហាអនុតំបន់ទន្លេមេគង្គស្តីពីកសិកម្ម នៅថ្ងៃទី ៣-៤ ខែមេសា ឆ្នាំ២០១៩ នាទីក្រុងគុនមិញ នៃសាធារណៈរដ្ឋប្រជាមានិតចិន (PRC) និងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ១៦ នៃក្រុមការងារមហាអនុតំបន់ទន្លេមេគង្គស្តីពីកសិកម្ម នៅថ្ងៃទី ១៧-១៨ ខែមិថុនា ឆ្នាំ២០១៩ នាទីក្រុងលួងប្រាបាង នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (Lao PDR)។

២. ជំនួយផ្នែកបច្ចេកទេសដំណាក់កាលចាប់ផ្តើម (TRTA) ដែលត្រូវបានអនុម័តក្នុងចំនួនទឹកប្រាក់ ២.៧ លានដុល្លារសហរដ្ឋអាម៉េរិក ត្រូវបានផ្តល់ហិរញ្ញប្បទានលើមូលដ្ឋានផ្តល់ជំនួយដោយ (១). មូលនិធិកាត់បន្ថយភាពក្រីក្រ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ (១.២ លានដុល្លារ) របស់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីគ្រប់គ្រងពេញលេញដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB), (២). មូលនិធិសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់ (១.0 លានដុល្លារ), និង (៣). មូលនិធិពិសេសរបស់ ADB សម្រាប់ជំនួយបច្ចេកទេស (0.៥ លានដុល្លារ) ក្រោមជំនួយមូលនិធិបន្ថែមលើវិស័យកសិកម្ម ធនធានធម្មជាតិ និងជនបទតំបន់អាស៊ីអាគ្នេយ៍ - ដំណាក់កាលទី ២។ ជំនួយបច្ចេកទេស TRTA ត្រូវបានគេរំពឹងថានឹងរៀបចំគម្រោងវិនិយោគចំនួនបីដាច់ដោយឡែកពីគ្នាសម្រាប់ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

## ខ. ផលជះ សមិទ្ធិផល និងលទ្ធផល

៣. នៅប្រទេសកម្ពុជា គម្រោងនេះនឹងត្រូវអនុវត្តនៅក្នុងខេត្តចំនួនប្រាំមួយ រួមមាន៖ កំពង់ចាម ឧត្តរមានជ័យ រាជធានីភ្នំពេញ ព្រៃវែង សៀមរាប និងតាកែវ។

៤. **ផលជះ សមិទ្ធិផល និងលទ្ធផលនៃគម្រោង៖** រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពលើគោលបំណង និងវិសាលភាពរបស់គម្រោងទាំងមូល។ គម្រោងនេះមានលក្ខណៈស្របទៅនឹងផលជះជាអាទិ៍៖ ចក្ខុវិស័យនៃមហាអនុតំបន់ទន្លេមេគង្គ ក្នុងតួនាទីជាអ្នក ផ្គត់ផ្គង់ឈានមុខគេលើផលិតផលកសិកម្មប្រកបដោយសុវត្ថិភាព និងមានលក្ខណៈមេត្រីភាពចំពោះបរិស្ថាន។ លទ្ធផលរំពឹងទុកនៃគម្រោងនេះ គឺការកែលម្អសុខភាព ខ្សែប្រវាក់តម្លៃ និង

ពាណិជ្ជកម្មសត្វជាផ្លូវការ និងផលិតផលសត្វ។ រាជរដ្ឋាភិបាលកម្ពុជា បានយល់ស្របជាមួយនឹងលទ្ធផលដែលបានស្នើឡើង៖ (១). ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វ និងខ្សែ ច្រវាក់តម្លៃសត្វ ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ, (២). សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលបសុសត្វ ត្រូវបានពង្រឹង, និង (៣). ការរៀបចំជំរុញការអនុវត្តគោលនយោបាយសម្រាប់ការផ្គត់ផ្គង់ សុខភាព សុវត្ថិភាព និងពាណិជ្ជកម្ម និងផលិតផលសត្វ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។

៥. **លទ្ធផលទី ១៖ ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វនិងខ្សែច្រវាក់តម្លៃសត្វ ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ។** សកម្មភាពសំខាន់ៗរួមមាន៖ (១). ការបង្កើតតំបន់គ្រប់គ្រងជំងឺ (DCZ) និងការត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធតាមតម្រូវការ និងការបង្កើតជាមណ្ឌលចត្តាឡីស័ក; (២). ការពង្រីក វិសាលភាពនៃការបង្កាត់ពូជសត្វ និងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសុខភាពសត្វ; (៣). ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងច្រវាក់តម្លៃសត្វ រួមទាំងផ្សារលក់ដូរជាប្រពៃណី; ទីសត្តឃាត និងកន្លែងលក់ដូរ និងកែច្នៃសាច់សត្វ។ ហេដ្ឋារចនាសម្ព័ន្ធសំណង់ទាំងនេះ ក៏នឹងបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគិតគូរពិចារណាអំពីនិរន្តរភាពផ្នែកបរិស្ថានផងដែរ។ ជាងនេះទៅទៀត ការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសំណង់នេះ នឹងតម្រូវឱ្យមានលទ្ធផលត្រឡប់មកវិញដោយការពេញចិត្តទាំងលើផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ក៏ដូចជាផែនការប្រតិបត្តិការ និងការគ្រប់គ្រងលម្អិត (O&M)។

(១). **តំបន់គ្រប់គ្រងជំងឺសត្វ និងហេដ្ឋារចនាសម្ព័ន្ធនៃការដាក់ឱ្យនៅដាច់ពីគ្នា និងការត្រួតពិនិត្យដែលពាក់ព័ន្ធ៖** គម្រោងនេះនឹងគាំទ្រដល់ការបង្កើតតំបន់គ្រប់គ្រងជំងឺ (DCZs) ឱ្យបានចាប់ពីបីតំបន់ឡើងទៅ ក្នុងលក្ខណៈជាដំណាក់កាល និងផ្តល់ជាជំនួយអន្តរកាលដល់ប្រទេសកម្ពុជាពីសំណាក់អង្គការពិភពលោកសម្រាប់មាគ៌ាត្រួតពិនិត្យវឌ្ឍនភាព (PCP) លើការគ្រប់គ្រងជំងឺអុតក្តាម (FMD) នៅដំណាក់កាលទី ១ ឬយ៉ាងហោចណាស់រហូតដល់ដំណាក់កាលទី ២ ។ តំបន់គ្រប់គ្រងជំងឺ (DCZ) ដំបូងគេនៅខេត្តព្រៃវែង នឹងជួយគាំទ្រដល់លំហូរសត្វចិញ្ចឹមពីប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាម។ ទីតាំងរបស់ DCZs បន្ថែម នឹងត្រូវបានកំណត់ក្នុងអំឡុងពេលអនុវត្តគម្រោងដោយផ្អែកលើបទពិសោធន៍ទទួលបានពីខេត្តព្រៃវែង។ តំបន់ DCZs នឹងត្រូវការការវិនិយោគផ្នែកមន្ទីរពិសោធន៍នៅទីវាលដែលនៅដាច់ដោយឡែក (~២០០ ម៉ែត្រក្រឡា) កន្លែងត្រួតពិនិត្យខាងក្នុង និងនៅព្រំដែន (រួមមានការិយាល័យតូចមួយ និងបុគ្គលិក) ការចាក់វ៉ាក់សាំងប្រឆាំងការរីករាលដាលនៃជំងឺអុតក្តាម និងជំងឺដុំពកស្បែក (LSD) និងការណែនាំអំពីប្រព័ន្ធកំណត់អត្តសញ្ញាណ និងការតាមដានសត្វ (LITS)។ នៅខេត្តព្រៃវែង តំបន់ DCZ នឹងរួមបញ្ចូលមណ្ឌលចត្តាឡីស័ករបស់រដ្ឋ ដែលមានសមត្ថភាពកែច្នៃគោចំនួន ១០,០០០ ក្បាលក្នុងមួយឆ្នាំសម្រាប់តម្រូវការទីផ្សារក្នុងប្រទេសវៀតណាម។ គម្រោងនេះក៏នឹងបង្កើតជាស្ថានីយត្រួតពិនិត្យសត្វ និងតាមដានជំងឺសត្វនៅខេត្តឧត្តរមានជ័យ ជាប់ព្រំដែនថៃ-កម្ពុជា។ ដោយផ្អែកលើវឌ្ឍនភាពដែលពេញចិត្ត និងលទ្ធភាពទទួលបានមូលនិធិ បច្ចេកវិទ្យា និងការអនុវត្តរបស់ DCZ នឹងត្រូវបានពង្រីកជាលំដាប់ទៅកាន់តំបន់ផ្ទុះជំងឺផ្សេង

ទៀត និងតំបន់ដែលងាយរងគ្រោះ។ ក្រុមបេសកកម្មត្រួតពិនិត្យ បានទទួលស្គាល់ពីសក្តានុពល សម្រាប់ការកៀរគរការវិនិយោគពីវិស័យឯកជននៅកន្លែងមណ្ឌលចត្តាឡីស័កនេះ។

(២). **ហេដ្ឋារចនាសម្ព័ន្ធសម្រាប់លើកកម្ពស់ការបង្កាត់ពូជសត្វ សុខភាពសត្វ រួមទាំងមន្ទីរពិសោធន៍រោគវិនិច្ឆ័យ និងការវិភាគ៖** គម្រោងនេះនឹងគាំទ្រដល់ការសាងសង់មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC) ដើម្បីរក្សាទុកគោពូជដែលបានកែលម្អរហូតចាប់ពីចំនួន ១៦ ក្បាល ជាមួយនឹងគោលដៅផលិតទឹកកាម (ស្ពែម) ឱ្យបានចំនួន ៣២០,០០០ បំពង់ ក្នុងមួយឆ្នាំ នៅត្រឹមឆ្នាំ២០២៩។ មជ្ឈមណ្ឌលNCBC ដែលនឹងត្រូវសាងសង់នៅលើទីតាំងដីរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្ម (GDAHP) លើទំហំផ្ទៃដី ១៣១.១៨ ហិកតា ក្នុងខេត្តកំពង់ធំ ដែលស្ថិតនៅចម្ងាយ ២៩០ គីឡូម៉ែត្រពីរាជធានីភ្នំពេញ នឹងរួមមាន៖ នឹងរួមមាន៖ (ក). មន្ទីរពិសោធន៍ កែច្នៃទឹកកាម, (ខ). កន្លែងបណ្តុះបណ្តាលស្តីពីការបង្កាត់ពូជសិប្បនិម្មិត (AI) រួមទាំងកន្លែងស្នាក់នៅសម្រាប់ សិក្ខាកាម ចំនួន ១២ នាក់, (គ). រោងគោ និងក្រោលគោ, (ឃ). កន្លែងស្តុក និងកែច្នៃចំណីសត្វ, (ង). ស្ថានីយ និយ័តកម្មអាសូតរាវ, (ច). កន្លែងប្រព្រឹត្តកម្មទឹកកង្វក់ និងសំណល់រឹងដោយវិមជ្ឈការ, (ឆ). ដីវាលផលិត ចំណីសត្វមួយកន្លែងដែលមានទំហំប្រហែល ២០ ហិកតា, និង (ជ). ការិយាល័យ និងកន្លែងស្នាក់នៅសម្រាប់ បុគ្គលិកចំនួន ៤ ខ្នង។ ការគាំទ្ររួមមាន ការទិញគោពូជដែលមានដើមកំណើតនៅក្រៅប្រទេស និងគោពូជដែលល្អៗសម្រាប់ការផលិតនិងកែច្នៃយកទឹកកាម។ លើសពីនេះ គម្រោងនឹងគាំទ្រដល់ការសាងសង់កន្លែងផលិតអាសូ៊តរាវ និងកន្លែងស្តុក និងចែកចាយទឹកកាមកកត្រជាក់ចំនួនបីកន្លែង សម្រាប់ការបង្កាត់ពូជសិប្បនិម្មិត (AI) ក្នុងខេត្តកំពង់ចាម ព្រៃវៀង និងខេត្តសៀមរាប។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) បានស្វែងរកការគាំទ្រសម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC) ដែលអាចបំពេញតាមស្តង់ដា ISO 9001 និងជាកន្លែងសម្រាប់ផ្ទុក និងចែកចាយទឹកកាមបន្ថែមមួយទៀតនៅក្នុងខេត្តពោធិ៍សាត់។ កម្មវិធីបង្កាត់ពូជសត្វ នឹងគាំទ្រដោយការបង្កើតជាក្រុម AI នៅតាមទីតាំងគម្រោងនីមួយៗ ជាមួយនឹងមធ្យោបាយសម្រាប់ការងារបច្ចេកទេស AI ការដឹកជញ្ជូន និងការកសាងសមត្ថភាព។ យ៉ាងហោចណាស់ក្រុម AI ចំនួន ១០ នាក់នឹងត្រូវបានចងក្រងឡើងនៅក្នុងខេត្តគោលដៅនីមួយៗ។

គម្រោងនេះ ក៏នឹងបង្កើតជាមជ្ឈមណ្ឌលជាតិផ្តល់ថ្នាំបង្ការបេសុសត្វ (NVVC) ដែលមានសមត្ថភាពផលិតវ៉ាក់សាំងមួយចំនួនសម្រាប់សត្វតំពារអៀងធំៗ និងសត្វមាន់ទា។ មជ្ឈមណ្ឌលនេះ នឹងត្រូវបានសាងសង់នៅលើដីដែលលើកខ្ពស់ (កម្ពស់ ៤ ម៉ែត្រ ដើម្បីបង្កើនភាពធន់នឹងទឹកជំនន់) លើផ្ទៃដីទំហំ ១៥ ហិកតា នៅខេត្តកណ្តាល ដែលជាកម្មសិទ្ធិរបស់អគ្គនាយកដ្ឋាន GDAHP ជាមួយនឹងអង្គភាពផលិត វ៉ាក់សាំងប្រឆាំងមេរោគ និងបាក់តេរី និងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាព រួមជាមួយនឹងទីធ្លាការិយាល័យ កន្លែងស្នាក់នៅសម្រាប់បុគ្គលិក កន្លែងរោងសម្រាប់ធ្វើតេស្តសត្វ អណ្តូងទឹក និងអាងស្តុកទឹកលើកផុតពីដី (ស៊ីទែនទឹក) កន្លែងប្រព្រឹត្តកម្មសំណល់សរីរាង្គ និងសំណល់គីមីពុល ផ្លូវ

និងទេសភាពផងដែរ។ អគ្គនាយកដ្ឋាន GDAHP បានស្វែងរកការគាំទ្រសម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC0 ដែលអាចបំពេញតាមស្តង់ដា ISO 9001។

គម្រោងនេះ នឹងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ (NAHPRI) ដើម្បីពង្រីកបន្ទប់ពិសោធន៍ និងអនុញ្ញាតឱ្យមានការអនុវត្តតាមស្តង់ដា ISO 17025 និងវិញ្ញាបនបត្រទទួលស្គាល់ជីវសុវត្ថិភាពកម្រិត ២ (BSL2)។ មជ្ឈមណ្ឌលជាតិ NCBC, NVVC, NAHPRI និងមន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពដែលពាក់ព័ន្ធ នឹងត្រូវបានសាងសង់ ឬកែលម្អឱ្យទៅជាកម្រិត ISO 9001 ការអនុវត្តផលិតកម្មល្អ (GMP) និងស្តង់ដាអនុវត្តមន្ទីរពិសោធន៍ល្អ (GLP) រៀងៗខ្លួន ហើយត្រូវបានដោយបរិក្ខារដែលអនុលោមតាមកម្រិត ISO សម្រាប់ការវិនិច្ឆ័យរក និងការត្រួតពិនិត្យជំងឺសត្វ ជំងឺឆ្លងពីសត្វទៅមនុស្ស និងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) និងសម្រាប់ការធ្វើតេស្តចំណីសត្វ សាច់សត្វ ផលិតផលពេទ្យសត្វ និងសម្រាប់តេស្តគុណភាព និងសុវត្ថិភាព។ គោលការណ៍ប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងទឹកកង្វក់ និងសំណល់រឹង នឹងត្រូវអនុវត្តដើម្បីកាត់បន្ថយការបំពុលខ្យល់ ដី និងទឹក និងការបំភាយឧស្ម័នផ្ទះកញ្ចក់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) បានសង្កត់ធ្ងន់ថា ការកែលម្អបន្ទប់ពិសោធន៍គួរតែឱ្យស្របតាមយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ចំពោះរាល់មន្ទីរពិសោធន៍ដែលកំពុងរៀបចំធ្វើ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកត់សម្គាល់ថា ការវិនិយោគលើការកែលម្អមន្ទីរពិសោធន៍ គួរតែត្រូវបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន ហើយលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងយន្តការស្តារឡើងវិញនៃការចំណាយ គួរតែពន្យល់ឱ្យបានលម្អិត។ ក្រសួង MEF បានជូនដំណឹងដល់ក្រុមបេសកកម្មថា ច្បាប់ថ្មីស្តីពីហិរញ្ញវត្ថុសាធារណៈកំពុងរៀបចំសម្រាប់ការអនុម័តនៅចុងឆ្នាំ២០២២ ឬដើមឆ្នាំ២០២៣ ដើម្បីផ្តល់ភាពបត់បែនដល់សហគ្រាសគ្រប់គ្រងដោយរដ្ឋ (PAEs) ដែលមានគោលដៅរកប្រាក់ចំណូល នៅថ្នាក់ជាតិ និងថ្នាក់ខេត្តដើម្បីធ្វើប្រតិបត្តិការដោយស្វ័យភាព ដែលអាចអនុញ្ញាតឱ្យរក្សាបាននូវប្រាក់ចំណូលរបស់ខ្លួន ដើម្បីបំពេញការចំណាយលើប្រតិបត្តិការ និងវិនិយោគប្រាក់ចំណូលបន្ថែមក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ ក្រសួង MEF បានផ្តល់យោបល់ថា ក្រុមការងារអាចពិនិត្យមើលគំរូអាជីវកម្មនៃការដំណើរការ PAEs ដែលមានគោលដៅរកប្រាក់ចំណូលនៅក្នុងប្រទេសផ្សេងៗ ហើយអគ្គនាយកដ្ឋាន GDAHP អាចពិចារណាលើបែបបទក្នុងការវិនិយោគ តាមបែបភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) សម្រាប់ប្រតិបត្តិការ NCBC, NVVC និង NAPHRI នាពេលអនាគត ស្របតាមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលបានអនុម័ត កាលពីចុងឆ្នាំ ២០២១។

(៣). **ហេដ្ឋារចនាសម្ព័ន្ធខ្សែប្រវាក់តម្លៃសត្វ៖** គម្រោងនេះនឹងសាងសង់ទីសត្តឃាតរដ្ឋបែបគំរូនៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប ហើយកន្លែងទាំងនេះនឹងត្រូវដាក់ជួលឱ្យប្រតិបត្តិករឯកជន

បន្ទាប់ពីសាងសង់រួច។ ទីសត្តឃាតគំរូនេះ នឹងត្រូវសាងសង់ឡើងជាមួយនឹងការបំពាក់ដោយម៉ាស៊ីនត្រជាក់ និងកន្លែងគ្រប់គ្រងសំណល់ ផ្សារសេត្វ និងមន្ទីរពិសោធន៍ដែលពាក់ព័ន្ធសម្រាប់ការធ្វើតេស្តរហ័ស ហើយនឹងបំពេញតាមតម្រូវការនៃវិញ្ញាបនប័ត្រទទួលស្គាល់ជាការអនុវត្តផលិតកម្មល្អ (GMP) និងជាស្តង់ដាសុវត្ថិភាពផលិតផល (HACCP)។ បន្ថែមពីលើនេះ ក៏នឹងមានការគាំទ្រដល់ការសាងសង់ផ្សារលក់មាន់ទាដែលគ្រប់គ្រងដោយរដ្ឋក្នុងទីរួមខេត្តតាកែវ និងកន្លែងសត្តឃាតសម្រាប់ប្រើប្រាស់ដោយអ្នកលក់សត្វមាន់ទា និងអ្នកសត្តឃាត ដែលមានអាជ្ញាប័ណ្ណពីគណៈកម្មការគ្រប់គ្រងផ្សារជូនកែវ។ លើសពីនេះ ក៏នឹងត្រូវកែលម្អទីសត្តឃាតរដ្ឋចំនួន ៣ កន្លែងដែលមានស្រាប់នៅក្នុងខេត្តផ្សេងទៀតឱ្យមានកម្រិតស្តង់ដា GMP។ អ្នកចូលរួមពិគ្រោះយោបល់មួយចំនួន បានសម្តែងការព្រួយបារម្ភលើការទូទាត់សំណងដែលមិនទាក់ទងនឹងដី ដែលទាមទារជាមួយនឹងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃសត្វដែលមានស្រាប់។

គម្រោងនេះនឹងគាំទ្រដល់ការកៀរគរការវិនិយោគពីវិស័យឯកជនក្នុងការផលិត និងហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃសត្វ (ផ្សារលក់ដូរសត្វ សត្តឃាត ការលក់សាច់ និងកន្លែងកែច្នៃ) ប្រកបដោយនិរន្តរភាព និងភាពវៃឆ្លាតទៅនឹងអាកាសធាតុ នៅក្នុងខេត្តគោលដៅ តាមរយៈការគាំទ្រជាមួយនឹងការអភិវឌ្ឍន៍ផែនការអាជីវកម្ម។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានយល់ស្របថា ការចូលរួមរបស់វិស័យឯកជននៅក្នុងវិស័យបសុសត្វ គឺជាយន្តការដ៏សំខាន់ ហើយមានយន្តការសមស្របជាច្រើន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគរបស់ពួកគេ។ ក្រសួង MEF បានស្នើឱ្យក្រុមបេសកកម្មវិភាគថាតើឧបសគ្គទីផ្សារសំខាន់ៗសម្រាប់ការវិនិយោគក្នុងវិស័យឯកជននៅមានកម្រិត ភាគច្រើនបណ្តាលមកពីកង្វះហេដ្ឋារចនាសម្ព័ន្ធ ឬបទប្បញ្ញត្តិ ឬទាំងពីរ ឬយ៉ាងណា។

៦. **លទ្ធផលទី ២៖ សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលសត្វ ត្រូវបានពង្រឹង។** គំនិតផ្តួចផ្តើមសំខាន់ៗនៅក្រោមលទ្ធផលនេះរួមមាន៖ (១). ការបង្ការពោគរាតត្បាតសត្វពាហនៈ និងព័ត៌មានវិទ្យា (LEI); (២). ការផ្តល់សេវាអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃសត្វ (LPS) និង (៣). ការត្រួតពិនិត្យគុណភាព និងការចេញវិញ្ញាបនបត្រផលិតផលសត្វ (LPQCC)។ គំនិតផ្តួចផ្តើមទាំងបីនេះ នឹងត្រូវបានគាំទ្រ តាមរយៈការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល និងការដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សាពាក់ព័ន្ធ (ឧ. សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប) និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលចំណេះដឹងផ្នែកនេះអាចត្រូវបានធ្វើស្ថាប័នូបនីយកម្មសម្រាប់ការចែកចាយដល់សិស្ស-និស្សិតនាពេលអនាគត និងក្រុមបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) ឬក្រុមសិក្ខាកាមជាកសិករ។ ក្រុមបុគ្គលិករបស់អគ្គនាយកដ្ឋាន GDAHP និងការិយាល័យបសុសត្វខេត្ត និងស្រុក នឹងត្រូវបានបណ្តុះបណ្តាល ដើម្បីចែកចាយបន្តនូវកម្មវិធីសិក្សាទាំងនេះទៅដល់ក្រុមកសិករដែលចូលរួម ក្រុមពេទ្យសត្វ ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) អ្នកបច្ចេកទេសផ្នែកបង្កាត់ពូជ

សិប្បនិម្មិត និងអ្នកផ្តល់សេវាផ្សេងទៀត។ គំនិតផ្តួចផ្តើមទាំងបីចំណុចនេះ នឹងរួមបញ្ចូលការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងវិធានការកាត់បន្ថយ ដែលមានគោលបំណងកាត់បន្ថយភាពងាយរងគ្រោះ និងការបំភាយកាបូនពីខ្សែច្រវាក់តម្លៃសត្វ។

(១). **ប្រព័ន្ធគ្រប់គ្រងរោគរាតត្បាតសត្វ និងព័ត៌មានវិទ្យា (LEI)៖** គំនិតផ្តួចផ្តើម LEI នឹងពង្រឹងសមត្ថភាពសម្រាប់ការកំណត់អត្តសញ្ញាណ (ការឃ្លាំមើលសកម្ម និងអកម្ម) និងការគ្រប់គ្រងជំងឺឆ្លងសត្វ (ឧ. ជំងឺអុតក្តាម, ជំងឺដុំពកស្បែក, ជំងឺគ្រុនផ្តាសាយជ្រូក, ជំងឺប៉េស្តជ្រូកអាហ្វ្រិច, ជំងឺឈាមខ្មៅ (អង់ត្រាក់), ជំងឺគ្រុនផ្តាសាយបក្សី, ជំងឺទ្រីជីណូស៊ីស, ជំងឺជំងឺហ្វាស្យូឡូស៊ីស) និងការឃ្លាំមើល ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) ក្នុងការគាំទ្រដល់វិធីសាស្ត្រ "សុខភាពមួយ One Health" និងការធ្វើពាណិជ្ជកម្មសត្វក្នុងតំបន់។ សកម្មភាពសំខាន់ៗរួមមានការអភិវឌ្ឍន៍លើ៖ (ក). ប្រព័ន្ធកំណត់អត្តសញ្ញាណ និងការតាមដានសត្វ (LITS); (ខ). ប្រព័ន្ធព័ត៌មានផលិតកម្មសត្វ និងសុខភាពសត្វ (APHIS); និង (គ). ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ទីរពិសោធន៍ (LIMS)។ សកម្មភាពទាំងនេះ មានសារៈសំខាន់ក្នុងការសម្រួលដល់ប្រព័ន្ធរាយការណ៍ជំងឺ ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយនឹងការធ្វើរោគវិនិច្ឆ័យនៅមន្ទីរពិសោធន៍ និងពង្រឹងបណ្តាញគ្រប់គ្រងព័ត៌មានសម្រាប់ការវាយតម្លៃហានិភ័យនៃជំងឺរាតត្បាតតាមតំបន់ និងជីវសុវត្ថិភាព។

(ក). **ប្រព័ន្ធកំណត់អត្តសញ្ញាណ និងការតាមដានសត្វ (LITS)** គឺជាប្រព័ន្ធដែលដំណើរការដោយកម្មវិធីទូរស័ព្ទ (app) ដែលនឹងផ្តល់ជាលេខអត្តសញ្ញាណសម្គាល់សត្វមានតែមួយគត់ដែលអនុលោមតាមក្របខ័ណ្ឌអាស៊ាន និងព័ត៌មានស្តីពីការពិពណ៌នារូបរាងកាយសត្វ និងការព្យាបាល ទីតាំង និងចលនារបស់សត្វ។

(ខ). **ប្រព័ន្ធព័ត៌មានផលិតកម្មសត្វ និងសុខភាពសត្វ (APHIS)** ពាក់ព័ន្ធនឹងការបង្កើតកម្មវិធីដំណើរការដោយកម្មវិធីទូរស័ព្ទ (app) សម្រាប់ផ្តល់ព័ត៌មានទាក់ទងនឹងសុខភាពសត្វ និងផលិតកម្មសត្វ ដោយផ្អែកលើប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធចាប់យកទិន្នន័យ ប្រព័ន្ធទំនាក់ទំនង និងសមត្ថភាពគ្រប់គ្រងទិន្នន័យ។ ប្រព័ន្ធនេះនឹងផ្តល់ព័ត៌មានតាមអេឡិចត្រូនិក និងតាមពេលវេលាជាក់ស្តែងលើគ្រប់វិស័យនៃផលិតកម្មសត្វ និងសុខភាពសត្វ ដើម្បីជូនដំណឹងដល់អ្នកបង្កើតគោលនយោបាយ និងការត្រួតពិនិត្យកម្មវិធី។

(គ). **ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ទីរពិសោធន៍ (LIMS)** ពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធដំណើរការដោយអ៊ីនធឺណែត នៅទូទាំងមន្ទីរពិសោធន៍ដែលជាគោលដៅគម្រោង ហើយប្រព័ន្ធនេះផ្តល់នូវការទទួលសំណាក លំហូរការងារ និងការគាំទ្រដល់ការតាមដានទិន្នន័យ ការផ្លាស់ប្តូរការផ្ទុកទិន្នន័យ និងចំណុចប្រទាក់លទ្ធផល។ ក្រុមការងារបានស្នើឡើងរួចហើយ ហើយអគ្គនាយកដ្ឋាន GDAHP ក៏បានឯកភាពដែរក្នុងការប្រើប្រាស់ប្រព័ន្ធ LIMS ដែលចំណាយទាប និងជាលក្ខណៈបច្ចេកទេសដែលបានបង្កើតឡើងដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)

(ឃ). **ការគាំទ្រចំពោះប្រព័ន្ធគ្រប់គ្រងរោគរាតត្បាតសត្វ និងព័ត៌មានវិទ្យា (LEI) សម្រាប់វិធីសាស្ត្រ "One Health" និងការកាត់បន្ថយហានិភ័យភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR)៖** ដោយមានការសម្របសម្រួលពីក្រសួងសុខាភិបាល (MOH) និងក្រសួងបរិស្ថាន (MOE) ប្រព័ន្ធ LEI នឹងរួមចំណែកដល់ការពង្រឹងកម្មវិធីកាត់បន្ថយហានិភ័យនៃការរាតត្បាតនៅទូទាំងប្រទេស "One Health និង AMR" និងដល់ការធ្វើឱ្យប្រសើរឡើងនូវការរាយការណ៍ទៅកាន់អង្គការពិភពលោកសម្រាប់សុខភាពសត្វ (OIE)។ ប្រព័ន្ធ LEI នឹងកំណត់អត្តសញ្ញាណ និងកំណត់ជាផែនទីលើប្រភេទសត្វជាអាទិភាព និងហានិភ័យ "One Health" តាមរយៈទិន្នន័យឃ្លាំមើលឆ្លងវិស័យស្តីពីការផ្ទុះឡើងនៃជំងឺឆ្លងពីសត្វទៅមនុស្ស និងឆ្លងពីសត្វព្រៃ តាមរយៈការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ។ គម្រោងនេះនឹងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រជាតិ "One Health" និងផែនការផ្តោតលើការចិញ្ចឹមសត្វ និងសុខភាពបរិស្ថាន ដើម្បីដាក់ឱ្យប្រើប្រាស់សាកល្បងនៅក្នុងខេត្តគោលដៅរបស់គម្រោង។ គម្រោងនេះនឹងជួយលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីហានិភ័យជំងឺសត្វ ការកំណត់អត្តសញ្ញាណសត្វ និងការគ្រប់គ្រងឱ្យបានល្អប្រសើរនូវវិធីសាស្ត្រ "One Health" ការគាំទ្រដល់ការចូលរួមរបស់បុគ្គលិក GDAHP ក្នុងកិច្ចប្រជុំថ្នាក់តំបន់ស្តីពី "One Health" និងព្រឹត្តិការណ៍ពង្រឹងសមត្ថភាពដទៃទៀត។ គម្រោងនេះនឹងគាំទ្រដល់ការស៊ើបអង្កេតរួមគ្នាជាមួយក្រសួង MOH និងក្រសួង MOE ដើម្បីរៀបចំគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (SOP) ដើម្បីឆ្លើយតបទៅនឹងការផ្ទុះឡើងនៃជំងឺឆ្លងពីសត្វទៅមនុស្ស និងបញ្ហាដែលកើតឡើងដោយសារសុវត្ថិភាពចំណីអាហារ រួមទាំងការប្រព្រឹត្តល្មើសចំពោះ AMR ផងដែរ។ គម្រោងនេះនឹងពង្រឹងសមត្ថភាពរបស់បុគ្គលិកនៃ GDAHP និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីលើកកម្ពស់ការអនុវត្តតាមវិធីសាស្ត្រ 3R (កាត់បន្ថយ ជំនួស និងកែលម្អ) ដើម្បីផ្តល់ប្រសិទ្ធភាពនូវការគ្រប់គ្រងឱសថប្រឆាំងមេរោគ កាត់បន្ថយការប្រព្រឹត្តល្មើសចំពោះ AMU និងការគ្រប់គ្រងហានិភ័យនៃ AMR ។ គំនិតផ្តួចផ្តើមនៃប្រព័ន្ធ LEI នេះក៏នឹងអាចបង្កើនការយល់ដឹង និងសមត្ថភាពក្នុងការកាត់បន្ថយការឆ្លងមេរោគដែលបណ្តាលមកពីចំណីអាហារ និងសំណល់ និងសារធាតុកខ្វក់ផ្សេងទៀតនៅក្នុងចំណីអាហារ និងបរិស្ថាន។

(២). **សេវាផលិតកម្មសត្វ (LPS)៖** សកម្មភាពសំខាន់ៗរួមមានការលើកកម្ពស់៖ (ក). ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP), (ខ). ការអភិវឌ្ឍន៍ចំណីសត្វដែលផ្តោតលើកសិករខ្នាតតូច ប្រកបដោយនិរន្តរភាព, គ). ការកែលម្អពូជគោ, និង (ឃ). សេវាសុខភាពសត្វឯកជន។ គំនិតផ្តួចផ្តើមនៃ LPS នឹងអាចលើកកម្ពស់គំនិតផ្តួចផ្តើមសុខុមាលភាពសត្វ ដែលស្របតាមយុទ្ធសាស្ត្រសុខុមាលភាពសត្វសកលរបស់អង្គការ OIE ។

(ក). **ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)៖** គម្រោងនេះនឹងគាំទ្រដល់ការអភិវឌ្ឍន៍ និងការអនុវត្ត GAHP អនុលោមតាមស្តង់ដាជាបន្តបន្ទាប់កម្រិតអាស៊ាន ដើម្បីអាចរកបានជាសំណៅឯកសាររឹង និងតាមរយៈទូរសព្ទដៃ រួមទាំងឯកសារជាសំឡេងជាភាសាខ្មែរ ដែលត្រូវចែកចាយតាមរយៈក្រុម

កសិករខ្នាតតូច ដែលបានទទួលការបំពាក់បំប៉នពីបុគ្គលិកការិយាល័យសុខភាពសត្វ និងបសុព្យាបាលខេត្តដែលបានទទួលការបណ្តុះបណ្តាល (POAHP) និងពីមន្ត្រីជំនាញនៃការិយាល័យសុខភាពសត្វ និងបសុព្យាបាលស្រុក (DOAHP)។ GAHP នឹងត្រូវអនុវត្តស្របជាមួយស្តង់ដាជាតិលើប្រភេទសត្វជាក់លាក់ (សត្វគោ ជ្រូក មាន់) ដែលនឹងក្លាយជាផ្នែកមួយនៃគម្រោងបញ្ជាក់ទទួលស្គាល់ជា GAHP កម្រិតជាតិ។ សមត្ថភាពរបស់បុគ្គលិកនៃ GDAHP នឹងត្រូវបានពង្រឹង ដើម្បីប្រតិបត្តិការគម្រោងបញ្ជាក់ទទួលស្គាល់ជា GAHP កម្រិតជាតិ រួមទាំងការទទួលស្គាល់ជាស្តង់ដា ISO17065 ផងដែរ។

(ខ). **គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ចំណីសត្វដែលមានមូលដ្ឋានលើកសិករតូចតាចៈ** នឹងត្រូវអភិវឌ្ឍយ៉ាងតិច លើទំហំ ១៨,០០០ ហិកតានៃវាលចំណីស្មៅ និងចំណីបន្លែនៅក្នុងប្រព័ន្ធកសិកម្មរបស់កសិករតូចតាច និងគាំទ្រដល់ការបង្កើតប្រព័ន្ធចិញ្ចឹមសត្វ ដែលទាក់ទងនឹងការកាត់ និងដឹក ការបន្សុីស្មៅ ឬការរក្សាទុកដីសម្រាប់ជាចំណីសត្វ។ ក្រុមបេសកកម្មបានសម្តែងការព្រួយបារម្ភលើការកំណត់គោលដៅចំនួន ១៨,០០០ ហិកតា នៅពេលដែលកិច្ចខិតខំប្រឹងប្រែងពីមុនបាននាំឱ្យមានការអភិវឌ្ឍផ្ទៃដីចំណីសត្វត្រឹមតែ ២,០០០ ហិកតាប៉ុណ្ណោះនៅក្នុងខេត្តគោលដៅ។ អ្នកចូលរួមពិគ្រោះយោបល់ក៏បានកត់សម្គាល់ពីសម្ពាធនៃប្រកួតប្រជែងលើដីសម្រាប់ជាចំណីសត្វនេះដែរ។ ក្រោមគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ចំណីសត្វ កសិករដែលចូលរួមអាចមានសិទ្ធិទទួលបានជំនួយឥតសំណងខ្នាតតូច តាមលក្ខខណ្ឌលើការបង្កើតផលិតកម្មចំណីសត្វប្រកបដោយជោគជ័យ និងកិច្ចព្រមព្រៀងផ្ទេរការកាត់ និងគ្រាប់ពូជដល់កសិករផ្សេងទៀតក្នុងរយៈពេលពីរឆ្នាំ។ គេរំពឹងថាដំណើរការនេះនឹងនាំទៅរកការលក់ពីកសិករទៅកសិករ ដោយជំនួសការចែកចាយដោយឥតគិតថ្លៃពីគម្រោង។ អ្នកផលិតគ្រាប់ពូជចំណីសត្វជាលក្ខណៈពាណិជ្ជកម្ម នឹងត្រូវបានជ្រោមជ្រែងឱ្យពង្រីកផលិតកម្មរបស់ខ្លួន។

(គ). **ការកែលម្អការបង្កាត់ពូជគោៈ** គម្រោងនេះនឹងផលិតទឹកកាមគោដែលត្រូវទុកឱ្យត្រជាក់កក បានរហូតដល់ចំនួន ៣២០,០០០ ដូស (កូនបំពង់) ចេញពីពូជពង្សគោដែលបានជ្រើសរើស ឬពូជគោបាដែលបានធ្វើតេស្តហ្សែនជារៀងរាល់ឆ្នាំ ដើម្បីទុកឱ្យអ្នកបង្កាត់ពូជសិប្បនិម្មិតដែលបានទទួលការបណ្តុះបណ្តាលរួច អាចប្រើប្រាស់គោបាទាំងនេះបាន។ គម្រោងនេះនឹងផ្តល់ការបណ្តុះបណ្តាលដែលមានការបញ្ជាក់ទទួលស្គាល់ដល់ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) លើវិធីបង្កាត់ពូជរួមទាំងការបង្កាត់ពូចសិប្បនិម្មិត (AI) និងផ្តល់ការគាំទ្រដល់បណ្តាញអ្នកផ្តល់សេវាបង្កាត់ពូជសិប្បនិម្មិតឯកជនផងដែរ។ គម្រោងសកម្មភាពទាំងនេះ នឹងត្រូវបានគាំទ្រដោយយុទ្ធនាការដែលអាចដំណើរការដោយប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ (ICT) ក្នុងចំណោមកសិករលើអត្ថប្រយោជន៍នៃការបង្កាត់ពូជ និងការគ្រប់គ្រងគោប្រកបដោយលក្ខណៈល្អប្រសើរ។

(ឃ). **ការអភិវឌ្ឍន៍សេវាសុខភាពសត្វឯកជន** ពាក់ព័ន្ធនឹង៖ (១). ការបង្កើតសមាគមពេទ្យសត្វ និងក្រុមប្រឹក្សាពេទ្យសត្វ, (២). ការបង្កើតគោលការណ៍ច្បាប់សម្រាប់ការផ្តល់សេវាសាធារណៈ

ល្អដោយមានកិច្ចសន្យាជាមួយអ្នកអនុវត្តសេវាសុខភាពសត្វឯកជនដែលបានទទួលការបណ្តុះបណ្តាល រួមទាំងភ្នាក់ងារសុខភាពសត្វភូមិ ដែលមានការទទួលស្គាល់, (៣). ការអភិវឌ្ឍន៍ជំនាញ និងសមត្ថភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីកែលម្អការផ្តល់សេវានៅតាមតំបន់ជាមួយកម្មវិធីបណ្តុះបណ្តាល ការបញ្ជាក់ទទួលស្គាល់សមត្ថភាព និងការត្រួតពិនិត្យពេទ្យសត្វ, និង (៤). ការគ្រប់គ្រងជំងឺឆ្លង រួមទាំងប៉ារ៉ាស៊ីតភាព និងជំងឺបង្កឡើងដោយបាក់តេរី និងមេរោគទូទៅ ដែលបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើផលិតកម្មសត្វ។

(៣). **ការត្រួតពិនិត្យគុណភាព និងការចេញវិញ្ញាបនបត្រផលិតផលសត្វ (LPQCC)៖** សកម្មភាពសំខាន់ៗរួមមាន ការកសាងសមត្ថភាពលើ៖ (ក). ការអនុវត្តផលិតកម្មល្អ (GMP); និង (ខ). ការត្រួតពិនិត្យសាច់ដោយផ្អែកលើហានិភ័យ និងការធានាសុវត្ថិភាព។ គម្រោងនេះនឹងពង្រឹងសមត្ថភាពរបស់អ្នកពាក់ព័ន្ធលើសុខុមាលភាពសត្វ ការសម្លាប់សត្វបរកបដោយមេត្តាធម៌ សុខភាព និងសុវត្ថិភាពមុខរបរអនាម័យសាច់ ការធ្វើតេស្តសំណល់គីមី និងអង់ទីប៊ីយ៉ូទិក និងការគ្រប់គ្រងគ្រឿងបរិក្ខារត្រជាក់។

(ក). **ការអនុវត្តផលិតកម្មល្អ GMP)៖** គម្រោងនេះនឹងគាំទ្រដល់ការអភិវឌ្ឍន៍ និងការអនុវត្តផលិតកម្មល្អ (GMP) ការសត្តឃាត និងការកែច្នៃសាច់សត្វអនុលោមតាមគោលការណ៍អនុវត្តកម្រិតអាស៊ាន ដើម្បីឱ្យមានជាឯកសាររឹង និងតាមរយៈទូរសព្ទដៃ រួមទាំងឯកសារសំឡេងជាភាសាខ្មែរផងដែរ។ នឹងមានការបណ្តុះបណ្តាលគ្រូបង្គោល និងបុគ្គលិកផ្នែកឧស្សាហកម្មបសុសត្វ និងសាច់សាច់ស្តីពីការអនុវត្ត GMP ។ គម្រោងនេះនឹងគាំទ្រដល់ឱកាសសម្រាប់ការរៀបចំ GMP ក្នុងក្របខ័ណ្ឌ GDAHP ដើម្បីបង្កើតសមត្ថភាពគ្រប់គ្រង និងដំណើរការគម្រោងចេញវិញ្ញាបនបត្រទទួលស្គាល់ ជា GMP កម្រិតជាតិជាមួយនឹងការទទួលស្គាល់ជាស្តង់ដា ISO17065 ។

(ខ). **ការត្រួតពិនិត្យសាច់ដោយផ្អែកលើហានិភ័យ និងការធានាសុវត្ថិភាព៖** គម្រោងនេះនឹងជួយដល់អគ្គនាយកដ្ឋាន GDAHP ដើម្បីបង្កើតការអនុវត្តការត្រួតពិនិត្យសាច់ដោយផ្អែកលើហានិភ័យដោយផ្តោតដំបូងលើទីសត្តឃាតដែលត្រូវបានកែលម្អដោយគម្រោង។ នឹងមានការគាំទ្រដល់៖ (១). ការវាយតម្លៃការអនុវត្តការត្រួតពិនិត្យសាច់ និងការបណ្តុះបណ្តាលពាក់ព័ន្ធ ដើម្បីបំពេញចន្លោះប្រហោងក្នុងកម្មវិធីសិក្សា, (២). សុខដុមមនីយកម្មនៃនីតិវិធី និងកម្មវិធីត្រួតពិនិត្យសាច់ជាមួយនឹងនីតិវិធីនៃការអនុវត្តសុខភាពល្អ (GMP) របស់ GDAHP, និង (៣). ការបណ្តុះបណ្តាលគ្រូបង្គោលអ្នកត្រួតពិនិត្យ និងបុគ្គលិកពេទ្យសត្វ ក្នុងការអនុវត្តកម្មវិធីត្រួតពិនិត្យសាច់ដែលផ្អែកលើហានិភ័យដែលបានធ្វើបច្ចុប្បន្នភាព។ ក្រុមបេសកកម្មបានកត់សម្គាល់ថាស្តង់ដារ ISO 22000 គឺជាស្តង់ដាដ៏ស្មុគស្មាញមួយក្នុងការអនុវត្តឱ្យបាន និងរក្សាឱ្យបាន ហើយវាអាចជាគោលដៅប្រាថ្នាសម្រាប់សហគ្រាសសត្វខ្នាតតូច និងមធ្យមភាគច្រើន រួមទាំងផ្សារក្រមួន កន្លែងសត្តឃាត និងកន្លែងផ្សេងៗទៀត។ ក្រុមការងារបានស្នើឱ្យមានវិធីសាស្ត្រជាជំហានៗទៅកាន់កម្រិត ISO 22000 និងបានសង្កត់ធ្ងន់លើតម្រូវការក្នុងការចូលរួមជាមួយនាយកដ្ឋានវិញ្ញាបនបត្រនៃវិទ្យាស្ថានស្តង់ដាកម្ពុជា។

៧.  **លទ្ធផលទី ៣៖ ការរៀបចំជំរុញការអនុវត្តគោលនយោបាយសម្រាប់ការផ្គត់ផ្គង់ សុខភាព សុវត្ថិភាព និង ពាណិជ្ជកម្ម និងផលិតផលសត្វ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។** សកម្មភាពសំខាន់ៗក្រោម លទ្ធផលទី៣នេះ រួមមាន៖ (១). ការគាំទ្រគោលនយោបាយជាតិស្តីពីបសុសត្វ; (២). គោលនយោបាយ ស្តីពីពាណិជ្ជកម្មសត្វ ឆ្លងកាត់ព្រំដែន; (៣). បទប្បញ្ញត្តិ និងស្តង់ដានានា; (៤) ការអភិវឌ្ឍន៍អនុវិស័យបសុសត្វឯកជន។

(១). **ការគាំទ្រគោលនយោបាយបសុសត្វជាតិ៖** គម្រោងនេះនឹងបង្កើតគោលនយោបាយឆ្លើយតបនឹងគោលការណ៍យេនឌ័រ និងមានមេត្រីភាពចំពោះអាកាសធាតុសម្រាប់អនុវិស័យបសុសត្វ រួមមានគោ ជ្រូក និងមាន់ទា សម្រាប់ការរួមបញ្ចូលម្ចាស់អាជីវកម្មខ្នាតតូចប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់តួនាទីស្ត្រីក្នុងផលិតកម្មសត្វ និងការបន្ថែមតម្លៃ។ គោលនយោបាយ និងវិធានការសម្រាប់ការទទួលស្គាល់សមភាព និងសុខដុមនីយកម្មនៃប្រព័ន្ធគុណភាព និងសុវត្ថិភាពនៅទូទាំងមហាអនុតំបន់ទន្លេមេគង្គ (GMS) និងអាស៊ាន នឹងត្រូវបានពិនិត្យ ដើម្បីសម្រួលដល់ពាណិជ្ជកម្មផ្លូវការ។ គម្រោងនេះនឹងគាំទ្រដល់ក្របខណ្ឌសម្រាប់ការអភិរក្សធនធានហ្សែនសត្វចិញ្ចឹម និងការកែលម្អពូជ និងសម្រាប់ការពង្រឹងសក្តានុពលអាជីវកម្មផ្នែកបង្កាត់ពូជដោយសិប្បនិម្មិត (AI)។ ក្រោមសកម្មភាពនេះ ក៏នឹងមានការគាំទ្រដល់ការបង្កើតគោលនយោបាយពិពិធកម្មការចិញ្ចឹមសត្វ និងប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិក ដើម្បីជួយសម្រួលដល់ការទំនាក់ទំនងពីកសិករទៅកសិករ។ គម្រោងនេះនឹងគាំទ្រដល់ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថ្មី និងផែនទីបង្ហាញផ្លូវសម្រាប់អនុវិស័យបសុសត្វសម្រាប់ឆ្នាំ ២០២៥-២០៣០ និងគោលនយោបាយស្តីពីការកែលម្អផលិតកម្មសាច់គោក្របី។

(២). **គោលនយោបាយពាណិជ្ជកម្មសត្វឆ្លងកាត់ព្រំដែន៖** ដោយមានការគាំទ្រពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), ក្រសួងពាណិជ្ជកម្ម (MOC), ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) គម្រោងនេះនឹងស្វែងរកឱកាសសម្រាប់ការអភិវឌ្ឍ "one-stop-shop" សម្រាប់ចលនាសត្វចិញ្ចឹមក្នុងប្រទេស និងសត្វឆ្លងដែន ដោយប្រើវេទិកាឌីជីថលដែលអាចចូលប្រើបានតាមរយៈទូរសព្ទដៃ។ គម្រោងនេះនឹងណែនាំជម្រើសគោលនយោបាយសម្រាប់ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធច្រកទ្វារតែមួយ និងដំណោះស្រាយព្រំដែនច្រកចេញចូលតែមួយ តាមរយៈការប្រើបុគ្គលិករួមគ្នា (ដោយប្រទេសនាំចេញ និងប្រទេសនាំចូល) នៅតាមប៉ុស្តិ៍ត្រួតពិនិត្យព្រំដែន និងសម្រាប់ការចុះបញ្ជី និងផ្តល់អាជ្ញាប័ណ្ណដល់ពាណិជ្ជករសត្វចិញ្ចឹម។ គម្រោងនេះនឹងគាំទ្រដល់ការអភិវឌ្ឍន៍គោលនយោបាយវេទិកាសត្វបែបឌីជីថល ដើម្បីជួយដល់អគ្គនាយកដ្ឋាន GDAHP ទាញយកអត្ថប្រយោជន៍ពីភាពជឿនលឿននៃប្រព័ន្ធ ICT ចុងក្រោយបង្អស់ក្នុងការគ្រប់គ្រងព័ត៌មាន ការអនុវត្តបទប្បញ្ញត្តិ និងដំណើរការចេញវិញ្ញាបនបត្រ។ អគ្គនាយកដ្ឋាន GDAHP បានកត់សម្គាល់ថាប្រព័ន្ធច្រកទ្វារតែមួយថ្នាក់ជាតិដែលទាក់ទងនឹង GDAHP សម្រាប់ការនាំចេញ នាំចូល និងដឹកជញ្ជូនសត្វរស់ និងផលិតផលសត្វបាននិងកំពុងអនុវត្តរួចហើយ ប៉ុន្តែបានឯកភាពថាឌីជីថលនីយកម្មនឹងបង្កើនប្រសិទ្ធភាពរបស់វា។ គម្រោងនេះនឹងផ្តល់ថវិកាចាំបាច់សម្រាប់សម្ភារៈបរិក្ខារ ចំណាយប្រតិបត្តិការ និងការកសាងសមត្ថភាព។

(៣). **បទប្បញ្ញត្តិ និងស្តង់ដារ៖** គម្រោងនេះនឹងជួយដល់ GDAHP ក្នុងការពិនិត្យមើលចន្លោះប្រហោងក្នុងច្បាប់ទាំងឡាយដែលមានស្រាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ (ឆ្នាំ២០១៦) និងណែនាំឱ្យប្រើវិធានការពង្រឹងនីតិកម្មសម្រាប់ការកំណត់អត្តសញ្ញាណចាំបាច់នៃសត្វចិញ្ចឹមទាំងអស់សម្រាប់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការការពារជំងឺ ការឃ្លាំមើល និងការគ្រប់គ្រង។ លើសពីនេះ ការងារត្រួតពិនិត្យ គ្រឿងបរិក្ខារត្រួពិនិត្យ និងសមត្ថភាពបុគ្គលិក រួមជាមួយនឹងការគាំទ្រពីកន្លែងធ្វើតេស្តរហ័ស និងបទប្បញ្ញត្តិ គឺជាឧបករណ៍ជាមូលដ្ឋាន ចំណែកថវិកា និងជំនួយបច្ចេកទេសនឹងត្រូវបានបែងចែកពីគម្រោងនេះ។ គម្រោងនេះនឹងជួយបង្កើតក្រុមប្រឹក្សាបសុពេទ្យ ដើម្បីធានាបាននូវការអនុលោមតាមអ្នកប្រកបរបរពេទ្យសត្វទាំងរដ្ឋ និងឯកជន និងអ្នកបច្ចេកទេស ព្រមទាំងទទួលយកការអនុវត្តល្អបំផុតជាអន្តរជាតិចំពោះការបង្ការជំងឺ។ ក៏នឹងមានការផ្តល់ការគាំទ្រផងដែរដល់៖ (ក). ការហាមឃាត់សារធាតុជំរុញការលូតលាស់ទាំងអស់នៅក្នុងចំណីសត្វ និងការអនុលោមតាមកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានស្តង់ដាកម្ពុជា, និង (ខ). ការបង្កើត និងការអនុលោមតាមស្តង់ដានៃកម្រិតអតិបរមានៃថ្នាំអង់ទីប៊ីយោទិចសម្រាប់គោលបំណង មេតាហ្វីឡាទិក (metaphylactic) និង ប្រូហ្វីឡាទិក (prophylactic)។

(៤). **ការអភិវឌ្ឍន៍អនុវិស័យបសុសត្វឯកជន៖** ដើម្បីពង្រឹងតួនាទីរបស់វិស័យឯកជនក្នុងការផ្តល់សេវាសុខភាពសត្វ គម្រោងនឹង៖ (១). កំណត់ឱកាសដើម្បីជម្នះឧបសគ្គសម្រាប់ការកៀរគរការវិនិយោគពីវិស័យឯកជនទៅក្នុងវិស័យបសុសត្វ, (២). ជួយបង្កើតសមាគមបសុពេទ្យឯកជនដោយរៀបចំជាបញ្ជីឈ្មោះអ្នកផ្តល់សេវាសុខភាពសត្វឯកជនទាំងអស់ដែលបានទទួលការបណ្តុះបណ្តាលសមស្រប សម្រាប់ការផ្តល់ថ្នាំបង្ការ ការកំណត់អត្តសញ្ញាណសត្វ ការឃ្លាំមើល រោគរាតត្បាត ការប្រមូលសំណាក និងការត្រួតពិនិត្យសាច់ក្នុងស្រុក, និង (៣). គាំទ្រការបង្កើតឱ្យមានភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) ដែលមានការបញ្ជាក់ទទួលស្គាល់ថាជាអ្នកផ្តល់សេវារាយការណ៍អំពីសុខភាព និងជំងឺសត្វ ក្រោមការត្រួតពិនិត្យរបស់ពេទ្យសត្វ ដើម្បីអនុវត្តតាមស្តង់ដាជាតិ និងអន្តរជាតិ។ គម្រោងនេះនឹងគាំទ្រដល់ការបង្កើតក្របខ័ណ្ឌគោលនយោបាយរដ្ឋ-ឯកជន-សហគមន៍ ដើម្បីកៀរគរការវិនិយោគពីវិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ (ឧ. ស្ថានីយ៍ចត្តាឡីស័ក កន្លែងដាក់ចំណី កន្លែងរក្សាទុកដាក់សត្វ កន្លែងផលិតចំណីសត្វ រោងម៉ាស៊ីនកិនចំណីសត្វ កន្លែងសត្តឃាត កន្លែងកែច្នៃសាច់) និងសេវាចែកចាយសុខភាពសត្វ។ មន្ត្រីនៃក្រសួង MISTI បានកត់សម្គាល់ពីភាពជោគជ័យនៃការអនុវត្តគំរូភាពជាដៃគូរវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មខេត្តកំពង់ចាម ក្នុងការបណ្តុះបណ្តាលបុគ្គលិកពេទ្យសត្វ។

## គ. ការចាត់ថ្នាក់ផ្នែកកិច្ចគាំពារ

៨. គម្រោងនេះត្រូវបានចាត់ថ្នាក់ជាប្រភេទ B សម្រាប់ជនជាតិដើមភាគតិច ស្របតាមលក្ខខណ្ឌតម្រូវនៃ SPS-ADB (ឆ្នាំ២០០៩) និងសៀវភៅណែនាំប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB (OM) ត្រង់ផ្នែក F1/OP (ឆ្នាំ២០១៣)។ វាអាចទៅរួចដែលថាក្នុងអំឡុងពេលអនុវត្តគម្រោង អនុគម្រោងមួយចំនួនត្រូវបានជ្រើសរើសដើម្បីរួម

បញ្ចូលគ្រួសារ ឬសហគមន៍ជនជាតិភាគតិច ជាពិសេសអនុគម្រោងក្នុងខេត្តឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង និងខេត្តតាកែវ។

## ឃ. គោលបំណងនៃក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុមជនជាតិភាគតិច

៩. គោលការណ៍ ADB-SPS ឆ្នាំ2009 កំណត់ថា កិច្ចគាំពារជនជាតិដើមភាគតិច ត្រូវយកមកអនុវត្តនៅពេលដែលអនុគម្រោងណាមួយបង្កផលប៉ះពាល់ ដោយផ្ទាល់ ឬដោយប្រយោលដល់សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត ឬវប្បធម៌របស់ជនជាតិ ដើមភាគតិច ឬប៉ះពាល់ដល់ទឹកដី ឬធនធានធម្មជាតិ ឬវប្បធម៌ដែលជនជាតិដើមភាគតិចមានជាកម្មសិទ្ធិ កំពុងប្រើប្រាស់ កាន់កាប់ ឬអះអាងថាជាសម្បត្តិដូនតា ឬជាទ្រព្យសម្បត្តិរបស់ពួកគេ។ ព័ត៌មានប្រជាសាស្ត្រពីខេត្តគោលដៅរបស់គម្រោង បង្ហាញថាមានគ្រួសារជនជាតិភាគតិច (មិនមែនជនជាតិដើមភាគតិច) ហើយទោះបីជាមិនមានជនជាតិដើមភាគតិច ឬគ្រួសារជនជាតិភាគតិចត្រូវបានរកឃើញនៅក្នុងទីតាំងអនុគម្រោងទាំងប្រាំក្នុងអំឡុងពេលសិក្សាសមិទ្ធិលទ្ធភាពក៏ដោយ ក៏អាចទៅរួចដែលថាគ្រួសារជនជាតិភាគតិចមួយចំនួននឹងត្រូវទទួលផលក្រោមក្របខ័ណ្ឌអនុគម្រោង ដែលនឹងត្រូវបានកំណត់អត្តសញ្ញាណក្នុងអំឡុងពេលអនុវត្តគម្រោង CLHVCIP ហើយក្នុងករណីនេះ នឹងតម្រូវឱ្យមានការរៀបចំជាផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP)។

១០. ក្របខ័ណ្ឌអភិវឌ្ឍន៍ក្រុមជនជាតិភាគតិច (EGDF) គួរតែត្រូវបានប្រើប្រាស់ដើម្បីណែនាំការពិនិត្យពិច័យហេតុប៉ះពាល់លើជនជាតិភាគតិច ធ្វើការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) និងក្នុងការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP) ដែលទាក់ទងនឹងអនុគម្រោងជាក់លាក់ណាមួយដែលប៉ះពាល់ដល់ជនជាតិភាគតិច។ ផែនការ EGDP នេះត្រូវបានអនុវត្តស្របជាមួយនឹងអនុគម្រោងជាក់លាក់ដែលពាក់ព័ន្ធ។ លើសពីនេះក្របខ័ណ្ឌ EMDF ក៏ផ្តល់ការណែនាំផងដែរសម្រាប់ការជ្រើសរើសអនុគម្រោង ការបញ្ចេញព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមរបស់ជនជាតិភាគតិច (EM) ការអនុវត្តវិធានការអភិវឌ្ឍន៍ជនជាតិភាគតិច ការត្រួតពិនិត្យ និងរាយការណ៍អំពីផែនការ និងការអនុវត្តផែនការ EMDP ការដោះស្រាយបណ្តឹងតវ៉ា ការរៀបចំស្ថាប័នសម្រាប់ការធ្វើផែនការ និងការអនុវត្ត IP ។ ល។

១១. វិធីសាស្ត្រដែលត្រូវបានយកមកអនុវត្តក្រោមក្របខណ្ឌនេះ គឺដើម្បីធានាបាននូវលទ្ធភាពទទួលបានសកម្មភាពគម្រោង និងអត្ថប្រយោជន៍សម្រាប់ក្រុមគ្រួសារទាំងអស់នៅក្នុងសហគមន៍គោលដៅ ដោយគ្មានការរើសអើង។ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាននៃអនុគម្រោងត្រូវបានកំណត់ និងជៀសវាង - ប្រសិនបើមិនអាចបញ្ចៀសបាន គឺត្រូវតែកាត់បន្ថយ ចំណែកផលជះវិជ្ជមានដែលអាចកើតមានដោយសារអនុគម្រោង ត្រូវបានជំរុញលើកទឹកចិត្ត។ គោលការណ៍ប្រតិបត្តិការរបស់គម្រោង រួមមានយន្តការដើម្បីធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ន ដែលជនជាតិភាគតិចត្រូវបានផ្តល់ឱកាសដូចគ្នាសម្រាប់ការពិគ្រោះយោបល់ជាមុន ការចូលរួម ការសម្រេចចិត្ត និងការចែករំលែកអត្ថប្រយោជន៍ក្នុងនាមជាមហាគ្រួសារខ្មែរតែមួយ។ ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP) ត្រូវបានរៀបចំឡើងដើម្បីណែនាំ និងធានានូវបរិយាប័ន្ន និងការពិគ្រោះយោបល់ពេញលេញជាមួយ

ក្រុមជនជាតិភាគតិច ឬគ្រួសារណាមួយ ប្រសិនបើពួកគេមានវត្តមាននៅក្នុងទីតាំងអនុគម្រោងណាមួយដែលត្រូវបានជ្រើសរើសសម្រាប់ការអនុវត្ត។

## ខ. គោលការណ៍ក្របខ័ណ្ឌ

១២. ក្នុងការស្វែងរកគោលបំណងដែលបានពិពណ៌នាខាងលើ គម្រោង CLHVCIP និងអនុគម្រោងទាំងឡាយរបស់ខ្លួន នឹងត្រូវបានគ្រប់គ្រងដោយគោលការណ៍ទាក់ទងនឹងជនជាតិភាគតិច ដូចខាងក្រោម៖

(១). ពិនិត្យពិច័យឱ្យបានឆាប់ពីដំបូង ដើម្បីកំណត់ឱ្យឃើញច្បាស់ (១). ថាតើមានវត្តមានជនជាតិដើមភាគតិចនៅក្នុងតំបន់គម្រោង ឬពួកគេមានទំនាក់ទំនងរួមជាមួយតំបន់គម្រោង ដែរឬអត់ ក៏ដូចជាថាតើគម្រោងនេះអាចទំនងជាមានផលប៉ះពាល់លើជនជាតិដើមភាគតិចដែរឬទេ។

(២). អនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គមដែលសមស្របតាមវប្បធម៌ និងដែលមានលក្ខណៈរសើបផ្នែកយេនឌ័រ ការពិចារណាពេញលេញចំពោះជម្រើសទាំងឡាយណាដែលបង្កើតដោយជនជាតិភាគតិចទាក់ទងនឹងអត្ថប្រយោជន៍ និងវិធានការកាត់បន្ថយ ត្រូវបានយកមកពិចារណា និងបកប្រែទៅជាផែនការជនជាតិភាគតិច ដែលរួមបញ្ចូលក្របខ័ណ្ឌសម្រាប់ការបន្តការពិគ្រោះយោបល់ និងទម្រង់បែបបទនៃការលាតត្រដាងព័ត៌មានដែលសមស្របតាមវប្បធម៌ក្នុងអំឡុងពេលអនុវត្តគម្រោង បញ្ជាក់វិធានការដើម្បីធានាថាជនជាតិភាគតិចពិតជានឹងទទួលបានអត្ថប្រយោជន៍ដែលស៊ីគ្នានឹងលក្ខណៈវប្បធម៌ កំណត់វិធានការដើម្បីជៀសវាង បន្ធូរបន្ថយ កាត់បន្ថយ ឬទូទាត់សំសងសម្រាប់ផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងរួមបញ្ចូលនីតិវិធីដោះស្រាយបណ្តឹងតវ៉ាដែលអាចទទួលយកបានតាមលក្ខណៈវប្បធម៌ ការរៀបចំការត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំថវិកា និងសកម្មភាពតាមពេលវេលាកំណត់ សម្រាប់ការអនុវត្តវិធានការដែលបានគ្រោងទុក។

(៣). អនុវត្តការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ និងក្រុមគ្រួសារជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដើម្បីបង្កើនចំនួននៃការចូលរួមរបស់ពួកគេក្នុងមួយវដ្តគម្រោង និងដើម្បីបញ្ចៀសផលប៉ះពាល់ដែលអាចកើតមាន និងផ្តល់នូវយន្តការបណ្តឹងតវ៉ាសមស្របតាមវប្បធម៌។

(៤). បញ្ចៀសការរឹតត្បិតលទ្ធភាពការចូលទៅកាន់ និងការបំលាស់ទីជារូបវន្តពីតំបន់ទឹកដីទំនៀមទម្លាប់ និងចៀសវាងការរើបអូស ហើយធានាថាសហគមន៍ជនជាតិភាគតិដែលរងផលប៉ះពាល់អាចចូលរួមក្នុងគ្រប់ទិដ្ឋភាពពេញមួយវដ្តគម្រោង ហើយអត្ថប្រយោជន៍របស់ពួកគេត្រូវបានចែករំលែកដោយសមធម៌។

(៥). រៀបចំផែនការ EMDP ផ្អែកលើ SIA ដោយមានជំនួយពីអ្នកជំនាញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានបទពិសោធន៍ក្នុងការដោះស្រាយតម្រូវការជនជាតិភាគតិច ដើម្បីចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពគម្រោង។ ផែនការ EMDP រួមបញ្ចូលក្របខ័ណ្ឌសម្រាប់ការបន្តការពិគ្រោះយោបល់ និងទម្រង់បែបបទនៃការបញ្ចេញព័ត៌មានដែលសមស្របតាមវប្បធម៌ក្នុងអំឡុងពេលអនុវត្តគម្រោង បញ្ជាក់

វិធានការដើម្បីធានាថាជនជាតិភាគតិចពិតជានឹងទទួលបានអត្ថប្រយោជន៍ដែលស៊ីគ្នានឹងលក្ខណៈវប្បធម៌ កំណត់វិធានការដើម្បីជៀសវាង បន្ធូរបន្ថយ កាត់បន្ថយ ឬទូទាត់សំសងសម្រាប់ផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងរួមបញ្ចូលនីតិវិធីដោះស្រាយបណ្តឹងតវ៉ាដែលអាចទទួលយកបានតាមលក្ខណៈវប្បធម៌ ការរៀបចំការត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំថវិកា និងសកម្មភាពតាមពេលវេលាកំណត់ សម្រាប់ការអនុវត្តវិធានការដែលបានគ្រោងទុក។

៦). លាតត្រដាងសេចក្តីព្រាងផែនការ រួមទាំងឯកសារនៃដំណើរការពិគ្រោះយោបល់ និងលទ្ធផលនៃ SIA ឱ្យបានទាន់ពេលវេលា មុនពេលវាយតម្លៃគម្រោងតាមដែលអាចធ្វើទៅបាន នៅតាមកន្លែងដែលអាចទទួល យកបាន និងក្នុងទម្រង់ និងជាភាសាដែលអាចយល់បានសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលរង ផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ ចំណែកផែនការ EMDP ចុងក្រោយ និងការធ្វើបច្ចុប្បន្នកម្មនៃផែនការនេះ ក៏នឹងត្រូវបង្ហាញផងដែរដល់សហគមន៍ជនជាតិភាគតិចដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

(៧). ត្រួតពិនិត្យការអនុវត្តផែនការ EMDP, អនុម័តវិធីសាស្ត្រត្រួតពិនិត្យដោយមានការចូលរួមនៅគ្រប់ទីកន្លែងដែលអាចធ្វើទៅបាន, វាយតម្លៃថាតើគោលបំណង និងលទ្ធផលដែលចង់បានរបស់ពីផែនការ EMDP ត្រូវបានសម្រេចជោគជ័យដោយការគិតគូរពីលក្ខខណ្ឌជាមូលដ្ឋាន និងលទ្ធផលនៃការត្រួតពិនិត្យផែនការ EMDP ដែរឬទេ។ ត្រូវលាតត្រដាងរបាយការណ៍ត្រួតពិនិត្យ។

## ច. ជាតិសាសន៍នៅក្នុងប្រទេសកម្ពុជា

១៣. ក្រុមជនជាតិភាគតិចច្រើនជាងគេក្នុងប្រទេសកម្ពុជា គឺជាជនជាតិខ្មែរដែលមានប្រមាណ ៩០ នៃចំនួនប្រជាជនសរុប ហើយភាគច្រើនរស់នៅក្នុងតំបន់វាលទំនាបនៃអនុតំបន់ទន្លេមេគង្គ និងតំបន់ទំនាបកណ្តាល។ នៅសល់ ១០% ជាក្រុមជនជាតិដែលមិនមែនជាខ្មែរ រួមមានចាម (ភាគច្រើនជាឥស្លាម និងមានដើមកំណើតមកពីប្រទេសវៀតណាម) ជនជាតិវៀតណាម ជនជាតិចិន និងជនជាតិដើមភាគតិចខ្មែរលើ (កុលសម្ព័ន្ធភ្នំ)។ ជនជាតិភាគតិចដែលមិនមែនជាជនជាតិដើមភាគតិច រួមមានជនអន្តោប្រវេសន៍ និងកូនចៅរបស់ពួកគេ ដែលរស់នៅក្នុងចំណោមជនជាតិខ្មែរ ហើយភាគច្រើនបានអនុវត្តតាមវប្បធម៌ខ្មែរ និងភាសាខ្មែរ។[1,2]

---

[1] សព្វវចនាធិប្បាយបេតិកភណ្ឌពិភពលោក (World Heritage Encyclopedia). *តារាងក្រុមជនជាតិភាគតិច: http://www.gutenberg.us/articles/list_of_ethnic_groups_in_ Cambodia*

[2] ក្រសួងផែនការ ឆ្នាំ២០១៩. *របាយការណ៍អង្កេតចន្លោះជំរឿនប្រជាសាស្ត្រ ឆ្នាំ២០១៩, របាយការណ៍ចុងក្រោយ ភ្នំពេញ។* ការរាប់ចំនួនច្បាស់លាស់បំផុតតាមបែបនរសាស្ត្រនៃជនជាតិភាគតិចចាមនៅក្នុងប្រទេសកម្ពុជាៈ *ដោយ William Collins* (2009), "ប្រជាជនឥស្លាមនៅកម្ពុជា" *នៅក្នុងក្រុមជនជាតិភាគតិចនៅកម្ពុជា,* ភ្នំពេញ៖ មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់, ទំព័រទី២-១១២។ ទោះយ៉ាងណាក៏ដោយ នៅមានការសិក្សាផ្សេងទៀតដែលគួរយកមកពិគ្រោះផងដែរ រួមមាន៖ Yasa Osman. 2002. *Oukoubah:* យុត្តិធម៌សម្រាប់ជនជាតិចាមឥស្លាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និង Federico, Sabeone, 2017, *ជនជាតិឥស្លាមក្នុងប្រទេសកម្ពុជាៈ ជោគវាសនារបស់ជនជាតិចាមមូស្លីម. ទីក្រុងប៉ៃកឡាំង ៖ វិទ្យាស្ថានអ៊ឺរ៉ុបសម្រាប់ការសិក្សាស្រាវជ្រាវតំបន់អាស៊ី។*

១៤. ក្នុងចំណោមក្រុមជនជាតិភាគតិចដែលមិនមែនខ្មែរទាំងនេះ មានតែជាក្រុមកុលសម្ព័ន្ធត្រូវបានចាត់ទុកជាជនជាតិដើមភាគតិច ដោយរាជរដ្ឋាភិបាលកម្ពុជា បើយោងតាមនិយមន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្រុមទាំងនេះរក្សាបាននូវការប្រើប្រាស់ភាសាខុសប្លែកគ្នារៀងៗខ្លួន និងការអនុវត្តតាមវប្បធម៌ផ្សេងៗទៀត។ រាជរដ្ឋាភិបាលបានទទួលស្គាល់ក្រុមជនជាតិភាគតិចចំនួន ២៤ ថាជា "ជនជាតិដើមភាគតិច" ជាផ្លូវការ ហើយការគំណត់និយមន័យស្របគ្នានឹងគោលបំណងរបស់ SPS-ADB (ឆ្នាំ២០០៩) ប៉ុន្តែមិនរាប់បញ្ចូលក្រុមជនជាតិភាគតិចវៀតណាមឡើយ។ ក្រុមជនជាតិជាតិដើមភាគតិចមានចំនួនច្រើន នៅតាមបណ្តាខេត្តតំបន់ភ្នំដាច់ស្រយាលនៃខេត្តរតនគិរី មណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។ ជាមួយគ្នានេះដែរ មានក្រុមកុលសម្ព័ន្ធភ្នំមួយ គឺជនជាតិកួយ ដែលមានចំនួនសរុបប្រមាណ ១៣.០៤៤ នាក់ រស់នៅក្នុងស្រុកមួយចំនួននៃខេត្តកំពង់ធំ និងមានគ្រួសារជនជាតិភាគតិចមួយចំនួន ជាពិសេស កួយ ចំនួន ១៣.០៤៤ គ្រួសារ និងជនជាតិចាមរស់នៅក្នុងសហគមន៍ខ្មែរនៅតាមខេត្តគោលដៅរបស់គម្រោងផងដែរ។ លើកលែងតែកុលសម្ព័ន្ធភ្នំ ជាទូទៅក្រុមជនជាតិភាគតិចមិនមែនខ្មែរ ត្រូវបានសមាហរណកម្មយ៉ាងល្អនៅក្នុងសង្គមខ្មែរ។[8] ជនជាតិភាគតិចចាម ត្រូវបានគេចាត់ទុកថាជាជនជាតិខ្មែរ និងមានលទ្ធភាពទទួលបានសញ្ជាតិ។

១៥. ក្រុមជនជាតិភាគតិចអាចនឹងរស់នៅក្នុងសហគមន៍របស់ពួកគេក្នុងសហគមន៍ខ្មែរកាន់តែច្រើនឡើង ឬត្រូវបានបញ្ចូលពេញលេញទៅក្នុងសហគមន៍ខ្មែរ ប៉ុន្តែពួកគាត់នៅតែប្រកាន់ខ្ជាប់ចរិតលក្ខណៈជនជាតិភាគតិចរបស់ខ្លួន ហើយជួនកាលនៅប្រើភាសារបស់ខ្លួនថែមទៀតផង។ នៅក្នុងតំបន់គម្រោងនេះ ជាពិសេសគឺជនជាតិចាមចំនួន ២០,៩៩៤ នាក់កំពុងរស់នៅក្នុងខេត្តកំពង់ចាមគឺនៅប្រកាន់ខ្ជាប់បែបនេះ បើទោះបីជាជនជាតិចាមស្ទើរតែទាំងអស់ លើកលែងតែជនជាតិចាមវ័យចំណាស់មួយចំនួនចេះអានអក្សរជាភាសាខ្មែរ ហើយមិនមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយសហគមន៍ខ្មែរភាគច្រើនក៏ដោយ។ ជាការពិត ពួកគេចាត់ទុកខ្លួនឯងជាជនជាតិចាម មិនថាជាឥស្លាម ឬមិនមែនជាពលរដ្ឋកម្ពុជាដែលមានសញ្ជាតិដូចខ្មែរនោះទេ។

១៦. របាយការណ៍អង្កេតចន្លោះជំរឿនប្រជាសាស្ត្រឆ្នាំ២០១៩ បានបង្ហាញថា ក្រុមកុលសម្ព័ន្ធតំបន់ភ្នំ និងក្រុមសាសនាជនជាតិភាគតិច មានចំនួន ០៦% នៃចំនួនប្រជាជនសរុប។ ទោះជាយ៉ាងនេះក្តី បើផ្អែកលើភាសាកំណើតអ្នកដែលនិយាយភាសាជនជាតិភាគតិច (រួមទាំងជនជាតិភាគតិច និងជនជាតិដើមភាគតិច និងមិនមែនជនជាតិភាគតិច) មានចំនួន ២.២៦% នៃចំនួនប្រជាជនសរុប។ ផែនទីខាងក្រោម បង្ហាញពីតំបន់សំខាន់ៗដែលប្រមូលផ្តុំដោយជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច។

## រូបភាពទី 1. ទីតាំងជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច




ប្រភព៖ សន្តិសុខសកលលោក ឆ្នាំ១៩៧២ (Global Security. 1972): ក្រុមជនជាតិភាគតិច
https://www.globalsecurity.org/jhtml/jframe. HTML HTTP://www. globalsecurity.org/military/world/cambodia/images/map-cambodia-ethnic-1972.jpg

## II. គោលបំណង និងក្របខ័ណ្ឌគោលនយោបាយ

### ក. គោលនយោបាយការការពារជនជាតិដើមភាគតិចនៃធនាគារអភិវឌ្ឍន៍អាស៊ី

១៧. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទទួលស្គាល់សិទ្ធិរបស់ជនជាតិភាគតិចក្នុងការដឹកនាំដំណើរនៃការអភិវឌ្ឍរបស់ខ្លួន។ ជារឿងៗ ក្រុមជនជាតិភាគតិចមិនទទួលបានអត្ថប្រយោជន៍ដោយស្វ័យប្រវត្តិពីការអភិវឌ្ឍន៍ ដែលបានរៀបចំ និងអនុវត្តធៀបទៅនឹងអ្នកដែលត្រូវបានដាក់បញ្ចូលនៅក្នុងចំណោមប្រជាជនភាគច្រើននៅក្នុងប្រទេសដែលពួកគេរស់នៅ។ ជាការចាំបាច់ណាស់ក្នុងកិច្ចខិតខំប្រឹងប្រែងជាពិសេស ដើម្បីអនុញ្ញាតឱ្យជនជាតិភាគតិចបានចូលរួមក្នុងការធ្វើផែនការនៃកម្មវិធីអភិវឌ្ឍន៍ដែលប៉ះពាល់ដល់ពួកគេ ជាពិសេសកម្មវិធីអភិវឌ្ឍន៍ដែលត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការ និងសេចក្តីប្រាថ្នាជាក់លាក់របស់ពួកគេ។ នៅក្នុងប្រទេសមួយចំនួន ក្រុមជនជាតិភាគតិចត្រូវបានគំរាមកំហែងកាន់តែខ្លាំងឡើង នៅពេលដែលកម្មវិធីអភិវឌ្ឍន៍បានរំលោភបំពានលើតំបន់ដែលពួកគេធ្លាប់កាន់កាប់ ប្រើប្រាស់ជាលក្ខណៈប្រពៃណី ឬចាត់ទុកជាដែនដីដូនតារបស់ពួកគេ។

១៨. សេចក្តីថ្លែងគោលនយោបាយការពារ (SPS-ADB ឆ្នាំ២០០៩) មានគោលបំណងដើម្បី៖

(១). បញ្ចៀស ផលប៉ះពាល់អវិជ្ជមានរបស់គម្រោងទៅលើបរិស្ថាន និងប្រជាជនដែលរងផលប៉ះពាល់ ប្រសិនបើអាចធ្វើទៅបាន។

(២). បន្ធូរបន្ថយ កាត់បន្ថយ និង/ឬទូទាត់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមានរបស់គម្រោងលើបរិស្ថាន និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ប្រសិនបើបើមិនអាចជៀសវាងបាន។

(៣). ជួយក្នុងការពង្រឹងប្រព័ន្ធការពាររបស់ប្រទេស និងអភិវឌ្ឍសមត្ថភាពគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម។

១៩. គោលបំណងនៃ SPS-ADB (ឆ្នាំ២០០៩) ត្រង់ចំណុចទាក់ទងនឹងជនជាតិដើមភាគតិច ឬជនជាតិភាគតិច គឺដើម្បីរៀបចំ និងអនុវត្តគម្រោងក្នុងទម្រង់មួយដែលជំរុញឱ្យមានការគោរពយ៉ាងពេញលេញចំពោះអត្តសញ្ញាណ សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត និងលក្ខណៈខុសប្លែកនៃវប្បធម៌របស់ជនជាតិដើមភាគតិច ឬជនជាតិភាគតិច ដូចដែលបានកំណត់ដោយជនជាតិដើមភាគតិចខ្លួនឯង ក្នុងនោះរួមមាន៖

(១). ការទទួលបាននូវអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចស្របតាមវប្បធម៌។
(២). មិនឱ្យទទួលរងផលប៉ះពាល់អវិជ្ជមានដែលជាលទ្ធផលដោយសារគម្រោង ។
(៣). អាចចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងដែលបង្កផលប៉ះពាល់ដល់ពួកគេ។

២០. ការការពារចំពោះជនជាតិដើមភាគតិច ត្រូវបានអនុវត្តដោយស្មើភាពគ្នាចំពោះជនជាតិដើមភាគតិច ហើយនឹងត្រូវបានជំរុញឱ្យមានការការពារប្រសិនអនុគម្រោងធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ ឬប្រយោលលើសេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត ឬវប្បធម៌របស់ជនជាតិ ដើមភាគតិច ឬប៉ះពាល់ដល់ទឹកដី ឬធនធានធម្មជាតិ ឬវប្បធម៌ដែលជនជាតិដើមភាគតិចមានជាកម្មសិទ្ធិ កំពុងប្រើប្រាស់ កាន់កាប់ ឬអះអាងថាជាសម្បត្តិដូនតា ឬជាទ្រព្យសម្បត្តិរបស់ពួកគេ។

២១. ពាក្យថា "ជនជាតិដើមភាគតិច" ត្រូវបានប្រើប្រាស់ក្នុងន័យទូទៅដើម្បីសំដៅទៅលើក្រុមប្រជាជន ដែលមានលក្ខណៈខុសប្លែកគេ ក្រុមងាយរងគ្រោះ ក្រុមសង្គម និងវប្បធម៌ ដែលមានបុគ្គលិកលក្ខណៈក្នុងកម្រិតផ្សេងៗគ្នាជាអាទិ៍៖ (១). ការកំណត់អត្តសញ្ញាណខ្លួនឯងជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមខុសប្លែកគេ និងការទទួលស្គាល់អត្តសញ្ញាណនេះពីអ្នកដទៃ, (២). ការភ្ជាប់ជាសមូហភាពទៅនឹងទីជម្រកខុសប្លែកគេ តាមភូមិសាស្ត្រ ឬទឹកដីដូនតាក្នុងតំបន់គម្រោង និងធនធានធម្មជាតិនៅក្នុងទីជម្រក និងទឹកដីទាំងនេះ, (៣). វប្បធម៌ប្រពៃណី សេដ្ឋកិច្ច សង្គម ឬនយោបាយ មានលក្ខណៈដាច់ដោយឡែកពីសង្គម និងវប្បធម៌ជារួម, និង (៤). ភាសាខុសប្លែកពីគ្នា ដែលខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។ ដោយយល់ឃើញពីបុគ្គលិកលក្ខណៈទាំងនេះ ច្បាប់ជាតិ ច្បាប់ទំនៀមទម្លាប់ និងអនុសញ្ញាអន្តរជាតិទាំងឡាយ ដែលប្រទេសកម្ពុជាជាភាគីហត្ថលេខីនោះ គួរលើកយកមកពិចារណាផងដែរ។ ក្រុមដែលបានបាត់បង់ការរស់នៅជាសមូហភាពនៅក្នុងជម្រកទីតាំងភូមិសាស្ត្ររបស់ខ្លួន ឬទឹក

ដីដូនតារបស់ខ្លួន នៅក្នុងទីតាំងគម្រោងដោយសារតែការបំបែកដោយបង្ខំ នៅតែមានសិទ្ធិទទួលបានការធានារ៉ាប់រង ក្រោមគោលនយោបាយនេះ។

## ខ. គោលនយោបាយពាក់ព័ន្ធរបស់ប្រទេសកម្ពុជា

២២. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ធានាដល់ប្រជាពលរដ្ឋទាំងអស់នូវសិទ្ធិស្មើៗគ្នា ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា និងជំនឿសាសនា។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានធ្វើការលើកឡើង ច្រើន ពីក្រុមជនជាតិដើមភាគតិច (ឬហៅថា ជនជាតិភាគតិច) នៅក្នុងច្បាប់ និងគោលនយោបាយផ្សេងៗទៀត។

២៣. ច្បាប់ភូមិបាល ឆ្នាំ២០០១ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការផ្តល់កម្មសិទ្ធិដីសហគមន៍នៅតាមសហគមន៍ ជនជាតិដើមភាគតិច ហើយក្របខ័ណ្ឌច្បាប់នេះ ត្រូវបានពង្រឹងបន្ថែមដោយគោលនយោបាយ ឆ្នាំ២០០៩ ស្តីពីការ ចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

២៤. សហគមន៍ជនជាតិដើមភាគតិច មានសិទ្ធិកាន់កាប់ដីសមូហភាពរបស់ខ្លួន ដែលផ្តល់ឱ្យពួកគេនូវសិទ្ធិ និងការការពារកម្មសិទ្ធិទាំងអស់ ដូចដែលកម្មសិទ្ធិករដីឯកជនទទួលបានដូច្នេះដែរ។ ដីរបស់សហគមន៍ជនជាតិដើមភាគតិច រួមមានដីលំនៅឋាន និងដីកសិកម្ម ហើយមានផ្ទៃដីដាំដុះដាក់ស្តែង និងដីបម្រុងទុកសម្រាប់ធ្វើស្រែចម្ការ។ សហគមន៍ជនជាតិដើមភាគតិច អាចបន្តគ្រប់គ្រងដីសហគមន៍របស់ខ្លួនតាមទំនៀមទម្លាប់ប្រពៃណី ដោយរង់ចាំការសម្រេចតាមការកំណត់ដោយស្ថានភាពផ្លូវច្បាប់។ នៅពេលដែលពួកគេត្រូវបានចុះបញ្ជីជានីតិបុគ្គលរួចមក សហគមន៍អាចស្នើសុំចុះបញ្ជីកម្មសិទ្ធិសមូហភាពរបស់ខ្លួនបាន។ (ច្បាប់ភូមិបាល ឆ្នាំ២០០១ ត្រង់មាត្រា ២៣ ដល់ ២៥)។

២៥. យោងតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងច្បាប់ភូមិបាល ឆ្នាំ២០០១ ទ្រព្យសម្បត្តិជាដីធ្លី ត្រូវបានបែងចែកជា ប្រាំប្រភេទធំៗ៖

(១). ដីឯកជន;
(២). ដីសាធារណៈរបស់រដ្ឋ (គ្រប់តំបន់ទាំងអស់ដែលត្រូវការប្រើសម្រាប់សេវាសាធារណៈ ដូចជាផ្លូវថ្នល់ ប្រាំងទន្លេ។ល។);
(៣). ដីឯកជនរបស់រដ្ឋ (តំបន់ផ្សេងទៀតទាំងអស់ដែលជាកម្មសិទ្ធិរបស់រដ្ឋ);
(៤). ដីសហគមន៍; និង
(៥). ដីជនជាតិដើមភាគតិច។

២៦. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ មានចែងយ៉ាងច្បាស់អំពីការការពារសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេក្នុងការអនុវត្តការដាំដុះដោយផ្លាស់ប្តូរវេន។ គោលនយោបាយជាតិឆ្នាំ ២០០៩ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច កំណត់នូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាក់ទងនឹងជនជាតិ

ដើមភាគតិចក្នុងវិស័យវប្បធម៌ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល និងស្របតាម ច្បាប់ភូមិបាល ឆ្នាំ២០០១ និងច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២។

២៧. ប្រទេសកម្ពុជា គឺជាប្រទេសហត្ថលេខីនៃលិខិតុបករណ៍អន្តរជាតិមួយចំនួន ដែលត្រូវបានតាក់តែងឡើង ដើម្បីការពារសិទ្ធិជនជាតិដើមភាគតិច រួមមាន៖ (១). កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, (២). កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, (៣). អនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, និង (៤). អនុសញ្ញាលេខ ១១១ ស្តីពីការរើសអើង ក្នុងការងារ និងមុខរបរ នៃការិយាល័យពលកម្មអន្តរជាតិ។ ក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រចំពោះ ការអនុម័តសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ប៉ុន្តែនៅតែមិនទាន់បានផ្តល់ សច្ចាប័នលើអនុសញ្ញាលេខ ១៦៩ នៃការិយាល័យពលកម្មអន្តរជាតិនៅឡើយទេ។

២៨. នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ក្រោមក្រសួងអភិវឌ្ឍន៍ជនបទ គឺជាភ្នាក់ងារនាំមុខរបស់ រាជរដ្ឋាភិបាលដែលធ្វើការលើបញ្ហាជនជាតិដើមភាគតិច ឬក្រុមជនជាតិភាគតិច។ នាយកដ្ឋាននេះ ត្រូវបានបង្កើត ឡើងក្នុងឆ្នាំ ១៩៩៩ បន្ទាប់ពីគណៈកម្មាធិការអន្តរក្រសួង (IMC) ត្រូវបានរំលាយចោល។ នាយកដ្ឋាននេះ ធ្វើការងារជាចម្បង ដើម្បីរក្សាវប្បធម៌ ជំនឿ និងទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច តាមរយៈដំណើរការផ្លូវការនៃការបង្កើតអត្តសញ្ញាណ និងលក្ខខណ្ឌនៃក្រុមជនជាតិដើមនៅក្នុងប្រទេសកម្ពុជា (ក្រុមជនជាតិដើមភាគតិចសរុបចំនួន ២៤ ក្រុម ត្រូវបានទទួលស្គាល់ថាជាក្រុមជនជាតិដើមភាគតិចស្របច្បាប់)។ នាយកដ្ឋាននេះ ប្រតិបត្តិការតាមរយៈការិយាល័យជនជាតិដើមភាគតិចនៅតាមបណ្តាខេត្តក្រុងនីមួយៗ។ ជនជាតិដើមភាគតិចត្រូវបានតំណាងនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចផ្លូវការក្នុងប្រទេសកម្ពុជាចាប់ពីកម្រិតភូមិ ឃុំ-សង្កាត់ និងរហូត ដល់ថ្នាក់ស្រុក-ខណ្ឌ/ខេត្ត-ក្រុង។ តួនាទីរបស់ភ្នាក់ងារនេះ គឺផ្តោតការងារលើបញ្ហាគោលនយោបាយ និងការអនុវត្ត កម្មវិធីរបស់រាជរដ្ឋាភិបាល ជាពិសេសផ្តោតលើជនជាតិដើមភាគតិច។

## គ. គម្លាតផ្នែកគោលនយោបាយរវាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងរាជរដ្ឋាភិបាលកម្ពុជា

២៩. មានផ្នែកជាច្រើនដែលបានបង្ហាញពីភាពខុសគ្នាផ្នែកគោលនយោបាយរបស់ ADB និងរបស់ រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាទាក់ទងនឹងជនជាតិដើមភាគតិច និងជនជាតិភាគតិច។ ចំណុចសំខាន់មួយនោះគឺនិយមន័យនៃជនជាតិដើមភាគតិច ដែលផ្ទុយពីជនជាតិភាគតិច ដែលបង្ហាញអំពីសញ្ជាតិរបស់ជនជាតិភាគតិចមួយចំនួនដែលកើតក្នុងប្រទេសកម្ពុជា ជាពិសេសជនជាតិវៀតណាមមួយចំនួន បើទោះបីជាបានចូលរួមនៅក្នុងការបោះឆ្នោតជាតិក្រោមការឃ្លាំមើលដោយអាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា ឬហៅថាអ៊ុនតាក់ (UNTAC) កាលពីខែឧសភា ឆ្នាំ១៩៩៣ ក៏ដោយ។ ជនជាតិវៀតណាមជាច្រើនត្រូវបានចេញឱ្យនូវអត្តសញ្ញាណប័ណ្ណដែលមានសុពលភាព។ ការបដិសេធមិនទទួលបានសញ្ជាតិប៉ះពាល់ដល់សិទ្ធិដូចជា ការកំណត់អត្តសញ្ញាណស្របច្បាប់ ការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានអប់រំ គុណវុឌ្ឍិសម្រាប់អត្ថប្រយោជន៍ និងកម្មវិធីអភិវឌ្ឍន៍ពីរដ្ឋាភិបាល កម្មសិទ្ធិដីធ្លី

លទ្ធភាពខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុក្នុងចំណោមអ្នកដទៃ។ គម្រោង CLHVCIP គឺជាគម្រោងមួយដែលផ្តោតលើខ្សែច្រវាក់តម្លៃ ហើយការកសាងសមត្ថភាពណាមួយនៅក្រោមក្របខ័ណ្ឌគម្រោងនេះ ត្រូវបានតម្រង់ឆ្ពោះទៅរកខ្សែច្រវាក់តម្លៃ និងការកែលម្អភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រព័ន្ធខ្សែច្រវាក់តម្លៃ។ នៅកន្លែងណាដែលមានវិវាទរវាងគោលការណ៍ណែនាំរបស់ ADB និងគោលនយោបាយប្រតិបត្តិការរបស់រាជរដ្ឋាភិបាល នោះគោលការណ៍ណែនាំរបស់ ADB នៅតែមានអាទិភាពអាចអនុវត្តបាននៅពេលណាក៏បាន ឱ្យតែស្របតាមច្បាប់ជាធរមានរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងនេះ នឹងធានាថាការពិគ្រោះយោបល់ប្រកបដោយអត្ថន័យនឹងត្រូវបានអនុវត្តចំពោះជនជាតិចាម និងជនជាតិវៀតណាម ប្រសិនបើពួកគេស្ថិតនៅក្នុងតំបន់គម្រោង។

## តារាងទី 1. ម៉ាទ្រិចនៃភាពខុសគ្នាផ្នែកគោលនយោបាយ

| ADB-SPS ឆ្នាំ២០០៩ | លក្ខខណ្ឌតម្រូវរបស់រាជរដ្ឋាភិបាល | ការអនុវត្តគម្រោង CLHVCIP |
|---|---|---|
| ១. ពិនិត្យឱ្យបានឆាប់ពីដំបូងដើម្បីកំណត់ (១). ថាតើជនជាតិដើមភាគតិចមានវត្តមាននៅក្នុង ឬមានការភ្ជាប់សមូហភាពក្នុងតំបន់គម្រោងដែរឬទេ។ និង (២). ថាតើផលប៉ះពាល់ដោយសារគម្រោងលើជនជាតិដើមភាគតិចទំនងជាកើតមានឬអត់។ | គ្មានដំណើរការពិនិត្យពិច័យ ត្រូវបានទាមទារឱ្យមាននៅក្នុងក្របខ័ណ្ឌច្បាប់កម្ពុជាទេ។ | ការពិនិត្យពិច័យសម្រាប់ការជ្រើសរើសអនុគម្រោង នឹងត្រូវអនុវត្តនៅដំណាក់កាលដំបូងបំផុតដោយផ្អែកលើបញ្ជីត្រួតពិនិត្យផលប៉ះពាល់លើជនជាតិដើមភាគតិចរបស់ ADB (ឧបសម្ព័ន្ធទី 3)។ នេះនឹងកំណត់អត្តសញ្ញាណផលប៉ះពាល់ដែលអាចកើតមាន និងកំណត់តម្រូវការក្រោមលក្ខខណ្ឌតម្រូវនៃ ADB SPS ។ |
| ២. អនុវត្ត SIA ដែលសមស្របតាមលក្ខណៈវប្បធម៌ និងយេនឌ័រ ឬប្រើវិធីសាស្ត្រស្រដៀងគ្នានេះ ដើម្បីវាយតម្លៃផលប៉ះពាល់គម្រោងដែលអាចកើតមាន ទាំងវិជ្ជមាន និងអវិជ្ជមានលើជនជាតិដើមភាគតិច។ ផ្តល់ការពិចារណាពេញលេញចំពោះជម្រើសនៃចំណង់ចំណូលចិត្តរបស់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ទាក់ទងនឹងការផ្តល់អត្ថប្រយោជន៍ពីគម្រោង និងការរៀបចំវិធានការកាត់បន្ថយ។ កំណត់អត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចសម្រាប់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដែលមានលក្ខណៈវប្បធម៌សមរម្យ និងយេនឌ័រ ប្រកបដោយបរិយាបន្ន និងបង្កើតវិធានការដើម្បីបញ្ចៀស បន្ធូរបន្ថយ និង/ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច។ | | ការវាយតម្លៃហេតុប៉ះពាល់សង្គម នឹងត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នកម្មសម្រាប់អនុគម្រោងទាំងអស់នៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិច ឬជនជាតិភាគតិចក្រោមក្របខ័ន្ឋនៃគម្រោង CLHVCIP។ ការវាយតម្លៃនេះនឹងគ្របដណ្តប់ទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានលើជនជាតិភាគតិចក្នុងតំបន់ ក៏ដូចជាដើម្បីបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ដោយមានការចូលរួមយ៉ាងពេញលេញពីជនជាតិដើមភាគតិចក្នុងតំបន់។ |
| (៣). រៀបចំការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ និងអង្គការសមាគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធ ដើម្បីសុំឱ្យមានការចូលរួម របស់ពួកគេៈ (១). ក្នុងការរៀបចំ ការអនុវត្ត និងវិធានការត្រួតពិនិត្យ ដើម្បីបញ្ចៀសផលប៉ះពាល់ អវិជ្ជមាន ឬប្រសិនបើមិនអាចជៀសវាងបាន ដើម្បីបន្ធូរបន្ថយ កាត់បន្ថយ ឬទូទាត់សំណងចំពោះ ផលប៉ះពាល់ទាំងនេះ; និង | | គម្រោង CLHVCIP នឹងតម្រូវឱ្យមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយសហគមន៍ជនជាតិភាគតិច រួមទាំងជនជាតិមានដើមកំណើតចាម និងវៀតណាម ប្រសិនបើមាន និងឬគ្រួសារដែលទទួលផល ឬផលប៉ះពាល់ដោយសារអនុគម្រោង ដែលបានជ្រើសរើសណាមួយ ដើម្បីជានាឱ្យមានការចូលរួម និងការដាក់បញ្ចូលក្នុងសកម្មភាពគម្រោង រួមទាំងការរចនា ក្នុងការរៀបចំ ការអនុវត្ត និងវិធានការត្រួត |

| ADB-SPS ឆ្នាំ២០០៩ | លក្ខខណ្ឌតម្រូវរបស់រាជរដ្ឋាភិបាល | ការអនុវត្តគម្រោង CLHVCIP |
|---|---|---|
| (២). ក្នុងការគ្រោងផ្តល់អត្ថប្រយោជន៍ពីគម្រោង សម្រាប់សហគមន៍ ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ក្នុងលក្ខណៈសមស្របតាមវប្បធម៌របស់ពួកគេ។ ដើម្បីបង្កើនការចូលរួមឱ្យបាន សកម្មពីជនជាតិដើមភាគតិច គម្រោងណាមួយដែលជះឥទ្ធិពលដល់ពួកគេ គួរផ្តល់នូវការអភិវឌ្ឍ សមត្ថភាពសមស្របតាមវប្បធម៌ និងប្រកបដោយបរិយាបន្នផ្នែកយេនឌ័រ។ បង្កើតយន្តការបណ្តឹងតវ៉ា ដោយសមស្របតាម វប្បធម៌ និងប្រកបដោយបរិយាបន្នផ្នែកយេនឌ័រ ដើម្បីទទួលបាននិងសម្រួលដល់ ការដោះស្រាយទុក្ខកង្វល់ទាំងឡាយរបស់ជនជាតិដើមភាគតិច។ | | ពិនិត្យ ដើម្បីបញ្ចៀសផលប៉ះពាល់ អវិជ្ជមាន ឬប្រសិនបើមិនអាចជៀសវាងបាន ដើម្បីបន្ធូរបន្ថយកាត់បន្ថយ ឬទូទាត់សំណងចំពោះផលប៉ះពាល់ទាំងនេះបានទេ ក្របខ័ណ្ឌគម្រោង CLHVCIP នឹងតម្រូវឱ្យមានភាពប្រែប្រួលនៃវប្បធម៌ និងភាសានៅក្នុងការពិគ្រោះយោបល់ទាំងនេះ។ |
| ៤. បញ្ជាក់ឱ្យប្រាកដពីការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ចំពោះសកម្មភាពគម្រោងដូជា៖ (១). ការអភិវឌ្ឍជាលក្ខណៈពាណិជ្ជកម្មនៃធនធានវប្បធម៌ និងចំណេះដឹងរបស់ជនជាតិដើមភាគតិច។ (២). ការផ្លាស់ប្តូរទីតាំងជារូបវន្ត ពីទឹកដីដែលធ្លាប់មានជាប្រពៃណី ឬជាទំនៀមទម្លាប់, និង (៣). ការអភិវឌ្ឍជាលក្ខណៈពាណិជ្ជកម្មនៃធនធានធម្មជាតិនៅក្នុងទឹកដីជាទំនៀមទម្លាប់ ដែលកំពុងប្រើប្រាស់ ដែលនឹងប៉ះពាល់ដល់ការរស់នៅ ឬការប្រតិបត្តិវប្បធម៌ ពិធីគោរពបូជា ឬការគោរពខាងព្រលឹងវិញ្ញាណ ដែលកំណត់អត្តសញ្ញាណ និងសហគមន៍របស់ជនជាតិដើមភាគតិច។ សម្រាប់គោលបំណងនៃការអនុវត្តគោលនយោបាយ ការយល់ព្រមពីសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ សំដៅលើការបញ្ចេញមតិរួមដោយសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ឬតាមរយៈបុគ្គល និង/ឬតំណាងដែលទទួលស្គាល់របស់ពួកគេ ចំពោះការគាំទ្រសហគមន៍ទូលំទូលាយសម្រាប់ | | យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង ហើយនឹងត្រូវបានពិភាក្សា និងប្រកាសជាសាធារណៈនៅក្នុងសហគមន៍ ហើយក្នុងករណីជនជាតិភាគតិចនឹងរួមបញ្ចូលតំណាងមកពីនាយកដ្ឋានជនជាតិដើមភាគតិចមកពីការិយាល័យ POAHP នៅថ្នាក់ខេត្ត។<br><br>គ្មានការអន្តរាគមន៍បែបនេះនឹងកើតឡើងក្រោមក្របខ័ណ្ឌ CLHVCIP ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ជាគោលការណ៍ គម្រោងនឹងធានាឱ្យបាននូវការពិគ្រោះយោបល់ពេញលេញ និងការយល់ព្រមពីជនជាតិភាគតិចក្នុងមូលដ្ឋាន ដើម្បីទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ធនធានវប្បធម៌ និងចំណេះដឹងរបស់ពួកគេប្រសិនបើវាកើតឡើង។ ការយល់ព្រមតាមរយៈការគាំទ្រសហគមន៍ទូលំទូលាយ នឹងត្រូវស្ថិតក្រោមការសង្កេតតាមដាន។ |

| ADB-SPS ឆ្នាំ២០០៩ | លក្ខខណ្ឌតម្រូវរបស់រាជរដ្ឋាភិបាល | ការអនុវត្តគម្រោង CLHVCIP |
|---|---|---|
| សកម្មភាពគម្រោងបែបនេះ។ ការគាំទ្រសហគមន៍ទូលំទូលាយអាចមាន ទោះបីជាបុគ្គល ឬក្រុមមួយចំនួនជំទាស់នឹងសកម្មភាពគម្រោងក៏ដោយ។ អនុក្រឹត្យសម្បទានដីសេដ្ឋកិច្ចចែងអំពីលក្ខខណ្ឌតម្រូវ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានបញ្ចប់ ដោយយោងតាមការប្រើប្រាស់ដី និងផែនការអភិវឌ្ឍន៍។ ការពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើងជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋក្នុងតំបន់ ទាក់ទងនឹងគម្រោង ឬសំណើសម្បទានដីសេដ្ឋកិច្ច។ | | |
| (៥). បញ្ចៀសតាមដែលអាចធ្វើទៅបានឱ្យនៅក្នុងកម្រិតមួយជាអតិបរមា ចំពោះការរឹតត្បិតលើលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងការផ្លាស់ទីជារូបវន្តពីតំបន់ការពារធម្មជាតិ។ ក្នុងករណីដែលមិនអាចជៀសវាងបាន ត្រូវប្រាកដថាសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ អាចចូលរួម ពាក់ព័ន្ធក្នុងការរចនាប្លង់ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃលើការរៀបចំគ្រប់គ្រងសម្រាប់តំបន់ទាំងនេះ និងធនធានធម្មជាតិ និងត្រូវចែករំលែកអត្ថប្រយោជន៍របស់ពួកគេ ប្រកបដោយសមធម៌។ | អនុក្រិត្យស្តីពី ELC ចែងពីតម្រូវការដែលត្រូវបំពេញក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត៖ (អនុក្រឹត្យលេខ ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច មាត្រា ៤ និងទី៥)៖ មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិកាន់កាប់ដីឯកជន។ | មិនមានបញ្ហាចំពោះការរឹតត្បិតលើ លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងការផ្លាស់ទីជារូបវន្តពីតំបន់ការពារធម្មជាតិ ដែលរំពឹងទុកក្រោមគម្រោង CLHVCIP នោះទេ។ |

| ADB-SPS ឆ្នាំ២០០៩ | លក្ខខណ្ឌតម្រូវរបស់រាជរដ្ឋាភិបាល | ការអនុវត្តគម្រោង CLHVCIP |
| --- | --- | --- |
| ៦. រៀបចំផែនការ EMDP ដែលផ្អែកលើការវាយតម្លៃហេតុប៉ះពាល់សង្គម ដោយមានជំនួយពីអ្នកជំនាញ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានបទពិសោធន៍ ហើយដែលអាចទាញយកចំណេះដឹង និងការចូលរួមពីសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់។ ផែនការ EMDP រួមបញ្ចូលក្របខ័ណ្ឌសម្រាប់ការបន្តការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ ក្នុងអំឡុងពេលអនុវត្តគម្រោង, កំណត់វិធានការដើម្បីធានាថាជនជាតិដើមភាគតិច អាចទទួលបានអត្ថប្រយោជន៍សមស្របខាងវប្បធម៌, កំណត់វិធានការដើម្បីបញ្ចៀស បន្ធូរបន្ថយ កាត់បន្ថយ ឬទូទាត់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង ព្រមទាំងរួមបញ្ចូលនីតិវិធីបណ្ដឹងតវ៉ា សមស្របតាមវប្បធម៌ ការរៀបចំការត្រួតពិនិត្យ និងការវាយតម្លៃ និងការរៀបចំថវិកា និងសកម្មភាព តាមពេលវេលាកំណត់សម្រាប់ការអនុវត្តវិធានការដែលបានគ្រោងទុក។ | គ្មានបញ្ញត្តិរបស់រដ្ឋាភិបាលលើការរៀបចំ EMDP នេះទេ។ | នៅកន្លែងដែលមានគ្រួសារ និងសហគមន៍ជនជាតិភាគតិចក្នុងចំណោមអ្នកទទួលផលអនុគម្រោង ដែលបានរងផលប៉ះពាល់ដោយអនុគម្រោងដែលបានស្នើឡើង នឹងតម្រូវឱ្យមានការរៀបចំ EMDP ដោយផ្អែកលើការអនុវត្តក្របខ័ណ្ឌនេះ។ នៅក្រោមគម្រោង CLHVCIP អ្នកប្រឹក្សានឹងត្រូវបានជ្រើសរើសដើម្បីជួយដល់ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យ EMDP ។ |
| ៧. លាតត្រដាងសេចក្ដីព្រាងផែនការ EMDP រួមទាំងឯកសារនៃដំណើរការពិគ្រោះយោបល់ឱ្យបានទាន់ពេលវេលា មុនពេលវាយតម្លៃគម្រោង តាមដែលអាចធ្វើទៅបាន នៅតាមកន្លែងដែលអាចទទួលយកបាន និងក្នុងទម្រង់ និងជាភាសាដែលអាចយល់បានសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ លាតត្រដាងផែនការ EMDP ចុងក្រោយ និងធ្វើបច្ចុប្បន្នកម្មផែនការនេះជូនដល់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ | គ្មានបញ្ញត្តិរបស់រដ្ឋាភិបាលលើការបញ្ចេញព័ត៌មានអំពី EMDP នេះទេ។ | ផែនការ EMDP ណាមួយដែលបានរៀបចំរួច នឹងត្រូវបានក្រកាសផ្សាយ មុនពេលវាយតម្លៃអនុគម្រោង និងជាភាសារបស់ជនជាតិភាគតិចក្នុងតំបន់នៅក្នុងសហគមន៍។ បច្ចុប្បន្នភាព ឬការផ្លាស់ប្តូរណាមួយចំពោះផែនការ EMDP ចុងក្រោយ ត្រូវតែបង្ហាញ និងទទួលយកដោយសហគមន៍។ |

| ADB-SPS ឆ្នាំ២០០៩ | លក្ខខណ្ឌតម្រូវរបស់រាជរដ្ឋាភិបាល | ការអនុវត្តគម្រោង CLHVCIP |
|---|---|---|
| ៨. ត្រូវរៀបចំផែនការសកម្មភាពសម្រាប់ការទទួលស្គាល់ស្របច្បាប់នៃសិទ្ធិជាទំនៀមទម្លាប់លើការប្រើ ប្រាស់ដីធ្លី និងទឹកដី ឬដែនដីដូនតា ប្រសិនបើគម្រោងនេះពាក់ព័ន្ធនឹង (១). សកម្មភាព ដែលពាក់ព័ន្ធនឹងការបង្កើតសិទ្ធិស្របច្បាប់លើដីធ្លី និងទឹកដីដែលជនជាតិដើមភាគតិចមានជាកម្មសិទ្ធិ ឬកំពុងប្រើប្រាស់តាមទំនៀមទម្លាប់ ឬកំពុងកាន់កាប់ ឬ (២). ការទទួលបានដីដោយមិនស្ម័គ្រចិត្ត។ | ការទទួលស្គាល់ និងការបញ្ជាក់កម្មសិទ្ធិដីធ្លីក្នុងចំណោមជនជាតិដើមភាគតិចកំពុងដំណើរការជាមួយនឹងការចេញអនុក្រឹត្យឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ | គម្រោង CLHVCIP ផ្តោតលើការពង្រឹងខ្សែច្រវាក់តម្លៃ និងនៅក្នុងតំបន់ដែលប្រើប្រាស់សម្រាប់កសិកម្មមានលក្ខណៈពាណិជ្ជកម្មដោយសហគមន៍ខ្មែរដែលអាចមានគ្រួសារជនជាតិភាគតិចមួយចំនួនកំពុងរស់នៅ។ គម្រោង CLHVCIP មិនពាក់ព័ន្ធនឹងការកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬការធ្វើផែនការដីធ្លីនៅក្នុងតំបន់ដែលជាកម្មសិទ្ធិ កំពុងប្រើប្រាស់ ឬកំពុងកាន់កាប់ដោយជនជាតិភាគតិច។ មិនមានការប៉ះពាល់ដល់សិទ្ធិជាទំនៀមទម្លាប់លើដីនោះទេ។ |
| ៩. ត្រួតពិនិត្យការអនុវត្តផែនការ EMDP ដោយមានអ្នកជំនាញដែលមានសមត្ថភាព និងមានបទពិសោធន៍។ អនុម័តវិធីសាស្ត្រត្រួតពិនិត្យដោយមានការចូលរួមតាមដែលអាចធ្វើទៅបាន និងវាយតម្លៃថាតើគោលបំណង និងលទ្ធផលដែលចង់បានពីផែនការ EMDP ត្រូវបានសម្រេចជោគជ័យ ដោយពិនិត្យពិច័យលើលក្ខខណ្ឌជាមូលដ្ឋាន និងលទ្ធផលនៃការត្រួតពិនិត្យផែនការ EMDP ដែរឬទេ។ ត្រូវលាតត្រដាងផែនការ EMDP នេះ។ | គ្មានបញ្ញត្តិរបស់រដ្ឋាភិបាលលើការរៀបចំ ឬត្រួតពិនិត្យការអនុវត្តផែនការ EMDP នេះទេ។ | ដោយសារផលប៉ះពាល់ដែលរំពឹងទុកលើជនជាតិភាគតិច មានកម្រិត នោះគម្រោង CLHVCIP នឹងធ្វើការត្រួតពិនិត្យផ្ទៃក្នុងនៃការអនុវត្តផែនការ EMDP ណាមួយ ដោយអនុលោមតាមសូចនាករដែលបានកំណត់ក្រោម EGDF និងក្របខ័ណ្ឌនៃការរចនា និងការត្រួតពិនិត្យគម្រោងដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាសរបស់គម្រោង។ |

៣០. គោលនយោបាយដែលមានស្រាប់មិនតម្រូវឱ្យមានការយល់ព្រមពីជនជាតិដើមភាគតិច សម្រាប់ការជួញដូរពាណិជ្ជកម្មនៃវប្បធម៌ និងចំណេះដឹងរបស់ពួកគេទេ (ទោះបីជាកម្ពុជាត្រូវបង្កើតវិញ្ញាបនបត្រទទួលស្គាល់ស្តង់ដាគុណភាពហាឡាល់ (HALAL) សម្រាប់ផលិតផលសត្វរបស់ខ្លួនដោយមិនរាប់បញ្ចូលសាច់ជ្រូកក៏ដោយ ក៏នៅមានកម្រិតនៃការប្រកាន់ខ្ជាប់យ៉ាងតឹងរឹងផ្នែកវប្បធម៌ និងសាសនា តាមរយៈអ្វីដែលត្រូវបានយោងនៅក្នុងវិន័យសាសនាឥស្លាមជា "dahabeah" ទាក់ទងនឹងរបៀបដែលសត្វពាហនៈត្រូវបានសម្លាប់ដោយសមស្រប) ការបំលាស់ទីជារូបវន្ត របស់ពួកគេពីទឹកដីដែលធ្លាប់រស់នៅជាប្រពៃណី ឬការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិនៅលើទឹកដីប្រពៃណីរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ ក្នុងនាមជាប្រទេសហត្ថលេខីនៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលនៅក្នុងបរិបទនេះសំដៅទៅលើក្រុមជនជាតិភាគតិចដូចជាជនជាតិចាម អាចនឹងលើកឡើងពីបញ្ហាបែបនេះ ដែលជារឿយៗពិបាកសម្រាប់អ្នកជំនាញបច្ចេកទេសក្នុងការយល់ឱ្យបានស៊ីជម្រៅ ហើយនីតិវិធីដោះស្រាយបណ្តឹងតវ៉ា គឺចាំបាច់អាចនឹងអនុវត្ត។

## III. ការកំណត់វិសាលភាព និងការពិនិត្យពិច័យអនុគម្រោង

៣១. ក្នុងអំឡុងពេលនៃការរៀបចំគម្រោង និងនៅក្រោមលទ្ធផលទី ១, អនុគម្រោងទាំង ៥ ត្រូវបានពិនិត្យពិច័យ និងសម្រិតសម្រាំងសម្រាប់ការសិក្សាយ៉ាងលម្អិតលើសមិទ្ធិលទ្ធភាព ដែលក្នុងនោះរួមមាន៖

១). មណ្ឌលចត្តាឡីស័ក នៅខេត្តឧត្តរមានជ័យ,

២). មជ្ឈមណ្ឌលជាតិផលិតថ្នាំបង្ការបសុសត្វ (NVVC) នៅខេត្តកណ្តាល (មិនរាប់បញ្ចូលជាខេត្តមួយនៃគម្រោង),

៣) មជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ (NCBC) នៅខេត្តកំពង់ធំ,

៤). ផ្សារលក់មាន់ទារស់ដូនកែវ នៅខេត្តតាកែវ

៥). វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលតកម្មសត្វ (NAHPRI) នៅរាជធានីភ្នំពេញ។

ការសិក្សាមួយត្រូវបានធ្វើឡើងដើម្បីរៀបចំឱ្យមានជាទីសត្តឃាតមួយទំនើបនៅក្នុងខេត្តសៀមរាប ប៉ុន្តែអនុគម្រោងនេះត្រូវបានផ្អាកទៅវិញ ដោយសារបញ្ហាពាក់ព័ន្ធនឹងបរិស្ថានជុំវិញបេតិកភណ្ឌជាតិ ប៉ុន្តែមិនមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ក្រុមជនជាតិភាគតិចដោយសារអនុគម្រោងនោះទេ។ ដោយផ្អែកលើការចុះទៅសិក្សាផ្ទាល់នៅតាមសហគមន៍គោលដៅ និងក្រុមអ្នកទទួលផល និងរួមជាមួយការជួបពិភាក្សាជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំ ការសិក្សាសមិទ្ធិលទ្ធភាពក៏ត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ឱ្យដឹងថា គ្មានជនជាតិភាគតិចណាមានវត្តមាននៅក្នុងតំបន់អនុគម្រោងណាមួយឡើយ។ ទោះជាយ៉ាងណាក៏ដោយ LSMGF ក៏នឹងកំណត់គោលដៅលើសហគមន៍ជនជាតិភាគតិច និងបញ្ហាការពារបរិស្ថាន និងសង្គម ដែលអាចប៉ះពាល់លើក្រុមជនជាតិភាគតិច ដោយសារអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុនឹងធ្វើការជាមួយគម្រោងដើម្បីផ្តល់ជំនួយដល់ការរៀបចំផែនការអាជីវកម្មប្រកបដោយបច្ចេកទេស និងហិរញ្ញវត្ថុរបស់អ្នក

ទទួលជំនួយដែលទទួលបានជោគជ័យក្នុងការទទួលបានជំនួយ។ ការរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ត្រូវបានរៀបចំជាឯកសារដាច់ដោយឡែកមួយ។

៣២. ទោះបីជាមិនមានគ្រួសារជនជាតិភាគតិច ត្រូវបានគេរកឃើញថារស់នៅក្នុងសហគមន៍តំបន់អនុគម្រោងដែលបានសិក្សាហើយក៏ដោយ ការចាត់ចំណាត់ថ្នាក់ប្រភេទនេះ ត្រូវបានធ្វើឡើងដោយសារតែវត្តមានរបស់គ្រួសារនិងសហគមន៍ជនជាតិភាគតិចមួយចំនួននៅក្នុងខេត្តគម្រោង ហើយដោយសារវាជាគម្រោងមួយផ្អែកតាមវិស័យដូច្នេះអាចទៅរួចដែលថាអនុគម្រោងនេះអាចកំណត់អត្តសញ្ញាណឃើញ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង និងអាចរួមបញ្ចូលគ្រួសារជនជាតិភាគតិចទាំងនោះផងដែរ។ បញ្ជីត្រួតពិនិត្យការវាយតម្លៃលើប្រភេទផលប៉ះពាល់លើជនជាតិដើមភាគតិច ដែលប្រើក្នុងការត្រួតពិនិត្យអនុគម្រោងក្នុងអំឡុងពេលរៀបចំគម្រោងនេះ ត្រូវបានពិពណ៌នាលម្អិតនៅក្នុងឧបសម្ព័ន្ធទី 1 ហើយបញ្ជីត្រួតពិនិត្យនេះនឹងត្រូវបានប្រើបន្ថែមទៀតក្នុងអំឡុងពេលអនុវត្តគម្រោង និងការពិនិត្យមើលលើអនុគម្រោងបន្ថែមទៀត។ នៅពេលដែលគ្រួសារជនជាតិភាគតិច ត្រូវបានរកឃើញថារងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដោយសារអនុគម្រោងណាមួយ ដែលត្រូវបានកំណត់ឃើញក្នុងអំឡុងពេលអនុវត្ត នោះគម្រោង CLHVCIP ចាំបាច់តម្រូវឱ្យមានការរៀបចំផែនការ EMDP ដោយអ្នកជំនាញផ្នែកកិច្ចគាំពារសង្គមរបស់គម្រោង។

៣៣. នៅពេលការអនុវត្តដំណើរការក្រោមគម្រោង CLHVCIP អនុគម្រោងបន្ថែមទៀតនឹងត្រូវបានកំណត់ និងធ្វើការសិក្សាសមិទ្ធិលទ្ធភាព។ បញ្ជីត្រួតពិនិត្យចំណាត់ថ្នាក់ផលប៉ះពាល់លើក្រុមជនជាតិដើមភាគតិច គួរត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារសិក្សាសមិទ្ធិលទ្ធភាពដែលបានរៀបចំរួច។ ការជ្រើសរើសអនុគម្រោងត្រូវតែបញ្ជាក់លើចំណុចដូចខាងក្រោម៖

(១). អនុគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ជាក់លាក់ដល់ជនជាតិភាគតិច ដែលក្នុងនោះពួកគាត់គឺជាផ្នែកមួយនៃសហគមន៍គោលដៅរបស់អនុគម្រោង និងពាក់ព័ន្ធនឹងសកម្មភាពខ្សែច្រវាក់តម្លៃដែលត្រូវពង្រឹង។

(២). អនុគម្រោងនេះនឹងមិនប៉ះពាល់ដល់ការប្រកាន់ខ្ជាប់ចំពោះសង្គមវប្បធម៌ ប្រពៃណី និងជំនឿរបស់ក្រុមជនជាតិភាគតិច (ឧ. ការចិញ្ចឹមបីបាច់កូន សុខភាព អប់រំ សិល្បៈ និងអភិបាលកិច្ច)។

(៣). អនុគម្រោងនេះនឹងមិនប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិតរបស់ជនជាតិភាគតិច ប្រព័ន្ធផលិតកម្មស្បៀងអាហារ ការគ្រប់គ្រងធនធានធម្មជាតិ សិប្បកម្ម និងពាណិជ្ជកម្ម ស្ថានភាពការងារ)។

(៤). អនុគម្រោងនេះនឹងមាននៅក្នុងតំបន់ណាមួយ (ដី ឬទឹកដី) ដែលជាកម្មសិទ្ធិ កំពុងកាន់កាប់ ឬប្រើប្រាស់ជាចំណែក ឬទាំងស្រុង ដោយជនជាតិភាគតិច។

(៥). អនុគម្រោងនេះនឹងមិនជំរុញឱ្យមានសកម្មភាពណាមួយខាងក្រោម ដោយគ្មានការគាំទ្រពីសហគមន៍ទូលំទូលាយ ដូចជា៖

(ក). ការអភិវឌ្ឍជាលក្ខណៈពាណិជ្ជកម្មនៃធនធានវប្បធម៌ និងចំណេះដឹងរបស់ជនជាតិដើមភាគតិច។

(ខ). ការផ្លាស់ប្តូរទីតាំងជារូបវន្ត ពីទឹកដីដែលធ្លាប់មានជាលក្ខណៈប្រពៃណី ឬជាទំនៀមទម្លាប់។

(គ). ការអភិវឌ្ឍជាលក្ខណៈធ្វើពាណិជ្ជកម្មលើធនធានធម្មជាតិ និងចំណេះដឹងរបស់ជនជាតិភាគតិច (ដូចជា រ៉ែ អ៊ីដ្រូកាបូន ព្រៃឈើ ទឹក ការបរបាញ់ ឬកន្លែងនេសាទ) នៅក្នុងដីជាទំនៀមទម្លាប់ដែលកំពុងប្រើប្រាស់ ហើយដែលនឹងអាចប៉ះពាល់ដល់ការចិញ្ចឹមជីវិត ឬការប្រើប្រាស់ជាវប្បធម៌ ពិធីសាសនា ការគោរពដល់ព្រលឹងវិញ្ញាណ ដែលអាចកំណត់លើអត្តសញ្ញាណ និងសហគមន៍ជនជាតិដើមភាគតិច។

(៦). អនុគម្រោងនេះនឹងមិនជំរុញឱ្យមានសកម្មភាពណាមួយខាងក្រោម ដោយគ្មានផែនការសកម្មភាពដែលត្រូវរៀបចំដោយអនុលោមតាមលក្ខខណ្ឌតម្រូវជាពិសេសនៃគោលការណ៍ ADB SPS ដូចជា៖

ក. ការបង្កើតឱ្យមានការទទួលស្គាល់ស្របច្បាប់លើសិទ្ធិទទួលបានដីធ្លី និងទឹកដីដែលធ្លាប់មានជាលក្ខណៈប្រពៃណី ឬធ្លាប់ប្រើប្រាស់ជាលក្ខណៈទំនៀមទម្លាប់ កាន់កាប់ ឬទាមទារដោយជនជាតិភាគតិច។

ខ. ការទទួលបានដីដែលធ្លាប់មានជាលក្ខណៈប្រពៃណី ឬធ្លាប់ប្រើប្រាស់ជាលក្ខណៈទំនៀមទម្លាប់ កាន់កាប់ ឬទាមទារដោយជនជាតិភាគតិច។

## ក. ការវាយតម្លៃហេតុប៉ះពាល់សង្គម

៣៤. ប្រសិនបើអនុគម្រោងនឹងបង្កផលប៉ះពាល់លើជនជាតិភាគតិច នោះតម្រូវឱ្យអនុវត្តការវាយតម្លៃផលប៉ះពាល់សង្គម (SIA) ព្រោះថាវានឹងជួយក្នុងការណែនាំឱ្យមានវិធីសាស្ត្រអនុវត្ត និងធ្វើឱ្យប្រសើរឡើងនូវការកំណត់គោលដៅ និងការត្រួតពិនិត្យផលប៉ះពាល់ផងដែរ។ តាមរយៈ SIA ក្នុងអនុគម្រោងនីមួយៗនឹងកំណត់អ្នកពាក់ព័ន្ធគម្រោងសំខាន់ៗ អ្នកទទួលផល និងក្រុមជនជាតិភាគតិច ហើយអនុវត្តដំណើរការដែលសមស្របតាមវប្បធម៌ និងយេនឌ័រសម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ បុគ្គលិកផ្នែកការពារសង្គមរបស់គម្រោង នឹងអនុវត្តការវាយតម្លៃ SIA សម្រាប់អនុគម្រោងនីមួយៗ ដើម្បីកំណត់ផលប៉ះពាល់លើជនជាតិភាគតិច និងរៀបចំផែនការ EMDP រួមជាមួយនឹងការសិក្សាសមិទ្ធិលទ្ធភាពផងដែរ។ ផលប៉ះពាល់ និងហានិភ័យសង្គមដែលអាចកើតមានដោយសារអនុគម្រោង នឹងត្រូវបានវាយតម្លៃដើម្បីរួមបញ្ចូលកត្តាចាំបាច់នានាសម្រាប់កិច្ចគាំពារដល់ជនជាតិភាគតិច។ ការវាយតម្លៃផលប៉ះពាល់សង្គម និងការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិភាគតិច គួរតែត្រូវបានអនុវត្ត មុនពេលការរៀបចំគម្រោងត្រូវបានបញ្ចប់។

៣៥. ការវាយតម្លៃផលប៉ះពាល់សង្គម (SIA) នឹងធ្វើឡើងក្នុងលក្ខណៈគិតគូរពីយេនឌ័រ ក្នុងការពិគ្រោះយោបល់ជាមួយជនជាតិភាគតិច តាមរយៈការប្រើប្រាស់ការចូលរួមទាំងបុរស និងស្ត្រី ដោយប្រើភាសាក្នុងតំបន់ នៅពេលដែលចាំបាច់ ដើម្បីធានាបាននូវការសម្ភាសន៍តាមគ្រួសារ ដែលត្រូវបានធ្វើឡើងជាមួយប្តី និងប្រព័ន្ធ និងការប្រើប្រាស់ក្រុមពិភាក្សាផ្តោតលើស្ត្រី និងដោយអ្នកសម្របសម្រួលជាស្ត្រី។ ក្នុងការប្រជុំ និងពេលសម្ភាសន៍ គេត្រូវតែធ្វើឡើងនៅពេលណាមួយងាយស្រួលសម្រាប់ស្ត្រី និងបុរសអាចចូលរួមបាន ហើយគម្រោងនឹងកំណត់ពេលវេលាតាមសហគមន៍។ វាក៏ចាំបាច់ផងដែរ ដើម្បីចូលរួមទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ ដោយប្រកាន់ខ្ជាប់នូវវិធានការនានា រួមទាំងការចាក់វ៉ាក់សាំងឱ្យបានគ្រប់ចំនួន ការពាក់ម៉ាស់ ការរក្សាគម្លាតសង្គម ការប្រើប្រាស់បន្ទប់ប្រជុំដែលមានខ្យល់ចេញចូលគ្រប់គ្រាន់ ឬគួរប្រជុំនៅខាងក្រៅ ការមិនប្រើប្រាស់គ្រឿងឧបភោគបរិភោគ និងភេសជ្ជៈដែលជះក្លិន ស្របតាមពិធីសារសុខាភិបាល។ ចំណុចសំខាន់មួយទៀត គឺការទទួលស្គាល់ថាជនជាតិភាគតិច ក៏ដូចជាប្រជាជនទាំងអស់ត្រូវមានសិទ្ធិបដិសេធមិនចូលរួមក្នុងការពិភាក្សាជាក្រុម (FGD) ឬសកម្មភាពរៀបចំគម្រោងផ្សេងទៀត ហើយទីកន្លែងណាដែលពួកគេយល់ព្រមឱ្យពិភាក្សា គម្រោងត្រូវតែទទួលបន្ទុកលើការចំណាយទាំងអស់។ លើសពីនេះ ការពិគ្រោះយោបល់តាមអនឡាញ ទំនងជាមិនទទួលបានជោគជ័យប៉ុន្មានទេ ហើយទំនងជានឹងបំពានលើគោលការណ៍ព្រមព្រៀងដោយសេរីជាមុន និងផ្អែកលើព័ត៌មានពេញលេញ (FPIC)។

៣៦. ការវាយតម្លៃ SIA នឹងបង្កើតជាព័ត៌មានបឋមបញ្ជាក់ពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ជនជាតិភាគតិចនៅតាមទីតាំងគម្រោង និងតំបន់រងផលប៉ះពាល់ពីគម្រោង៖ (១). វាយតម្លៃឱកាស និងលទ្ធភាពទទួល ដើម្បីអាចទទួលបានសេវាសេដ្ឋកិច្ចសង្គមជាមូលដ្ឋាន, (២). កំណត់ផលប៉ះពាល់របស់គម្រោងទាំងរយៈពេលខ្លី រយៈពេលវែង ដោយផ្ទាល់ និងដោយប្រយោល វិជ្ជមាន និងអវិជ្ជមានលើស្ថានភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ចរបស់ក្រុមនីមួយៗ, (៤). វាយតម្លៃ និងកំណត់ថាតើមានក្រុមជនជាតិដើមភាគតិចណាខ្លះនឹងអនុវត្តស្របតាមគោលការណ៍ SPS របស់ ADB, និង (៥). វាយតម្លៃវិធីសាស្ត្រ និងតម្រូវការធនធានបន្តបន្ទាប់សម្រាប់ដោះស្រាយក្តីកង្វល់ និងបញ្ហានានារបស់គម្រោងដែលប៉ះពាល់ដល់ពួកគាត់។ ប្រសិនបើមានផលប៉ះពាល់លើក្រុមជនជាតិភាគតិច ត្រូវចាំបាច់តម្រូវឱ្យមានការរៀបចំផែនការ EMDP ស្របតាមការសិក្សាសមិទ្ធិលទ្ធភាពរបស់អនុគម្រោង។

៣៧. ទោះជាផលប៉ះពាល់ដែលអាចកើតមាននោះ មានលក្ខណៈវិជ្ជមាន ឬអវិជ្ជមានក៏ដោយ អនុគម្រោងនីមួយៗនឹងត្រូវរៀបចំការវាយតម្លៃ SIA ដែលនឹង៖

(១). កំណត់ និងបញ្ជាក់ច្បាស់លាស់អំពីផលប្រយោជន៍វិជ្ជមាន និងអវិជ្ជមានដែលក្រុមជនជាតិភាគតិចត្រូវទទួលបាន ដែលជាលទ្ធផលនៃការចូលរួមក្នុងអនុគម្រោង។

(២). ផ្តល់ព័ត៌មានបឋមអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ក្រុមជនជាតិភាគតិចក្នុងទីតាំងអនុគម្រោង។ ព័ត៌មានទិន្នន័យបឋមដែលមានការបែងចែកទៅតាមប្រភេទជនជាតិភាគតិច និងភេទ អំពីស្ថានភាពប្រជាសាស្ត្រ សង្គម វប្បធម៌ និងទ្រព្យសម្បត្តិ (កម្រិតភាពក្រីក្រ និងចរិតលក្ខណៈរបស់ក្រុមសហគមន៍ជនជាតិភាគតិច ដែលរងផលប៉ះពាល់។

(៣). កំណត់ដី និងទឹកដីដែលក្រុមជនជាតិភាគតិចធ្លាប់មាន ឬប្រើប្រាស់ ឬកាន់កាប់ជាលក្ខណៈប្រពៃណី និងធនធានធម្មជាតិដែលពួកគាត់ពឹងអាស្រ័យ។

(៤). វាយតម្លៃលទ្ធភាពទទួលបាន និងឱកាស ដើម្បីឱ្យពួកគាត់អាចទទួលបានសេវាសង្គម និងសេដ្ឋកិច្ចជាមូលដ្ឋាន ជាពិសេសផ្តោតលើវិសមភាពយេនឌ័រ និងរបៀបដែលសេវាទាំងនេះជះឥទ្ធិពលដល់អត្ថប្រយោជន៍ដែលត្រូវទទួលបានពីគម្រោង។

(៥). រួមបញ្ចូលឱ្យមានការវាយតម្លៃបញ្ហារសើបផ្នែកយេនឌ័ររបស់ជនជាតិភាគតិចដែលរងផលប៉ះពាល់ដោយសារគម្រោង និងផលប៉ះពាល់របស់គម្រោងលើស្ថានភាពសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ការវិភាគលើបញ្ហាយេនឌ័រ គឺមានសារៈសំខាន់ក្នុងការកំណត់ផលប៉ះពាល់ជាអវិជ្ជមាន ភាពងាយរងគ្រោះដែលពាក់ព័ន្ធ និងហានិភ័យដែលកើតឡើងចំពោះសហគមន៍ជនជាតិភាគតិចដែលរងផលប៉ះពាល់ ក្នុងស្ថានភាពជាក់ស្តែងរបស់ពួកគាត់ និងកង្វះការទទួលបានឱកាសដោយយោងទៅតាមឱកាសដែលមានសម្រាប់ក្រុមក្នុងសង្គមផ្សេងទៀត។

(៦). វាយតម្លៃឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានធ្ងន់ធ្ងរដោយសារអនុគម្រោង។ ក្នុងនោះត្រូវវាយតម្លៃផលប៉ះពាល់រយៈពេលខ្លី និងវែងដោយផ្ទាល់ និងដោយប្រយោល និងវិជ្ជមាន និងអវិជ្ជមានរបស់គម្រោងលើស្ថានភាពសង្គមវប្បធម៌ និងសេដ្ឋកិច្ចរបស់ក្រុមនីមួយៗ។

(៧). វាយតម្លៃ និងកំណត់ក្រុមជនជាតិភាគតិចណាខ្លះដែលនឹងបំពេញតាមលក្ខខណ្ឌតម្រូវដើម្បីទទួលបានកិច្ចគាំពារដល់ជនជាតិភាគតិច។

(៨). ស្វែងរក និងណែនាំឱ្យមានវិធានការចាំបាច់ ដើម្បីបញ្ចៀសឥទ្ធិពលជាអវិជ្ជមាន ប្រសិនបើមិនអាចបញ្ចៀសបាន ត្រូវស្វែងរកវិធានការបន្ធូរបន្ថយ កាត់បន្ថយ និង/ឬផ្តល់សំណងចំពោះឥទ្ធិពលនោះ។ វិធានការទាំងនោះត្រូវធានាថា ក្រុមជនជាតិដើមភាគតិចទទួលបានផលប្រយោជន៍សមស្របតាមវប្បធម៌ ក្រៅសកម្មភាពគម្រោង។

៣៨. ខ្លឹមសារដែលលើកឡើង ទិន្នន័យដែលត្រូវការ និងវិធីសាស្ត្រដែលបានស្នើឡើងក្នុងការរៀបចំ SIA សម្រាប់អនុគម្រោង មានបង្ហាញក្នុងឧបសម្ព័ន្ធទី ២។

៣៩. សរុបមក លក្ខណៈវិនិច្ឆ័យក្នុងការពិនិត្យពិច័យ នឹងអាចដកចេញនូវអនុគម្រោងណាមួយដែលមានផលប៉ះពាល់ចម្បងៗលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងលើជនជាតិភាគតិច។ អំឡុងពេលអនុវត្តគម្រោង អនុគម្រោងណាមួយបន្ថែមទៀតដែលបានកំណត់ នឹងត្រូវពិនិត្យឡើងវិញលើផលប៉ះពាល់ជនជាតិភាគតិច។ ការពិនិត្យឡើងវិញនេះ នឹងធ្វើឡើងតាមរយៈដំណើរចុះពិនិត្យផ្ទាល់ទៅកាន់ទីតាំងអនុគម្រោង និងតាមរយៈកិច្ចប្រជុំដែលធ្វើឡើងជាមួយក្រុមអ្នកទទួលផលពីអនុគម្រោង និងប្រជាសហគមន៍ (សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់វិធីសាស្ត្រ និងតម្រូវការទិន្នន័យលម្អិត)។ ផលប៉ះពាល់ជាអវិជ្ជមានទាំងអស់ (បណ្តោះអាសន្ន និងអចិន្ត្រៃយ៍) នឹង

ត្រូវកាត់បន្ថយ តាមរយៈការរៀបចំអនុគម្រោង និងការពិគ្រោះយោបល់ជាមួយសហគមន៍ក្នុងតំបន់គោលដៅ និងភាគីពាក់ព័ន្ធផ្សេងទៀត។ ដូចបានបង្ហាញនៅក្នុងបញ្ជីត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធទី ១ គម្រោងនេះនឹងត្រូវចាត់ថ្នាក់ជាប្រភេទ B សម្រាប់ជនជាតិភាគតិច ដោយសារមានវត្តមានរបស់សហគមន៍ជនជាតិភាគតិចនៅក្នុងខេត្តគោលដៅ និងមានលទ្ធភាពអាចបញ្ចូលគ្រួសារជនជាតិភាគតិចដែលជាអ្នកទទួលផលពីគម្រោង សម្រាប់អនុគម្រោងនាពេលអនាគត។

## IV. ការរៀបចំផែនការសម្រាប់ជនជាតិភាគតិច

៤០. តាមរយៈការពិនិត្យពិច័យពីដំបូង ប្រសិនបើអនុគម្រោងមានផលប៉ះពាល់ចម្បងៗលើជនជាតិភាគតិច ផែនការ EMDP នេះនឹងឆ្លើយតបចំពោះបញ្ហាដែលបានកំណត់នៅក្នុង SIA និងតាមរយៈការពិគ្រោះយោបល់នានា ហើយនឹងដាក់ចេញនូវវិធានការដែលការអនុវត្តគម្រោងនេះ នឹងធានាថា៖

(១). ជនជាតិភាគតិចដែលរងផលប៉ះពាល់ នឹងទទួលផលប្រយោជន៍សង្គម និងសេដ្ឋកិច្ច ស្របតាមវប្បធម៌។

(២). នៅពេលដែលផលប៉ះពាល់អវិជ្ជមានលើជនជាតិភាគតិចត្រូវបានកំណត់ឃើញហើយ គម្រោងនឹងត្រូវបញ្ចៀសផលប៉ះពាល់ទាំងនោះឱ្យបានច្រើនបំផុត តាមលទ្ធភាពដែលអាចធ្វើបាន។

(៣). ក្នុងករណីបង្ហាញថាផលប៉ះពាល់នេះមិនអាចបញ្ចៀសរួច ផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ជនជាតិភាគតិចទេនោះ ផែនការ EMDP នឹងរំលេចវិធានការដើម្បីបន្ធូរបន្ថយ កាត់បន្ថយ និងផ្តល់សំណងចំពោះផលប៉ះពាល់អវិជ្ជមាននោះ ហើយជនជាតិភាគតិចដែលរងផលប៉ះពាល់អាចចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងដែលប៉ះពាល់ដល់ពួកគេ។

៤១. អ្នកជំនាញផ្នែកការពារសង្គមរបស់គម្រោង CFAVCP នឹងរៀបចំឯកសារធ្វើផែនការនេះ តាមរយៈការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយក្រុមដែលរងផលប៉ះពាល់ ដើម្បីជួយរដ្ឋាភិបាលក្នុងការបំពេញកិច្ចការខាងលើ។

៤២. កម្រិតនៃសេចក្តីលម្អិត និងភាពពេញលេញនៃផែនការ EMDP នេះនឹងប្រែប្រួលអាស្រ័យលើអនុគម្រោងជាក់លាក់ និងលក្ខណៈនៃផលប៉ះពាល់ដែលត្រូវដោះស្រាយ។ ចំណុចសំខាន់នោះ គឺការកំណត់ឱ្យឃើញនូវផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន និងធានាឱ្យមានការចូលរួមពេញលេញ និងមានវិធានការកាត់បន្ថយដែលមានប្រសិទ្ធភាព។

៤៣. ប្រសិនបើជនជាតិភាគតិច គឺជាក្រុមមានតែឯង ឬជាក្រុមភាគច្រើនជាងគេក្នុងចំណោមអ្នកទទួលផលពីអនុគម្រោងដោយផ្ទាល់ ហើយនៅពេលដែលផលប៉ះពាល់ជាវិជ្ជមានត្រូវបានរកឃើញនោះ ចំណុចនានានៅក្នុងផែនការ EMDP អាចយកមកដាក់បញ្ចូលនៅក្នុងការរៀបចំអនុគម្រោង ប្រសើរជាងការរៀបចំ EMDP ដាច់ដោយឡែកមួយ។ ក្នុងករណីបែបនេះ ឯកសារអនុគម្រោងនឹងត្រូវរបញ្ចូលសេចក្តីសង្ខេបនៃរបៀបដែលអនុគម្រោងត្រូវអនុវត្តតាមដើម្បីផ្តល់កិច្ចគាំពារដល់ជនជាតិដើមភាគតិច។ ជាពិសេស នឹងមានពន្យល់អំពីរបៀបដែលត្រូវបំពេញ

ទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងរបៀបបញ្ចូលផលប្រយោជន៍បន្ថែមទៅក្នុងការរៀបចំអនុគម្រោងនេះ។ ប្រសិនបើអនុគម្រោងបង្កផលប៉ះពាល់ទៅលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងទៅលើជនជាតិភាគតិច ចាំបាច់ត្រូវរៀបចំផែនការរួមគ្នាទាំងការតាំងទីលំនៅជាថ្មី និងជនជាតិភាគតិច។ ជាងនេះទៅទៀត ការរំលេចដែលបានណែនាំឱ្យធ្វើសម្រាប់ផែនការ EMDP ត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៤ ។

៤៤. ជាពិសេសទាក់ទងនឹង ឬ ទោះបីជាមិនបានកំណត់ចំពោះអនុគម្រោងសាងសង់ទីសត្តឃាត និងផ្សារក៏ដោយ នៅពេលបញ្ចប់ការរៀបចំប្លង់វិស្វកម្មលម្អិត និងការអង្កេតដោយវាស់វែងលម្អិត ចាំបាច់ត្រូវកែសម្រួលជាថ្មីលើផែនការ EMDP និងបញ្ចូលគ្រោងពេលវេលាអនុវត្តដែលត្រូវបានសម្របសម្រួលជាមួយនឹងការអនុវត្តការវិនិយោគ។ ត្រូវទាមទារឱ្យមានការកែតម្រូវវិធានការកាត់បន្ថយដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើជនជាតិភាគតិច និងវិធានការដើម្បីលើកកម្ពស់អត្ថប្រយោជន៍អភិវឌ្ឍន៍សមស្របតាមវប្បធម៌ ប៉ុន្តែលទ្ធផលដែលបានឯកភាពគ្នារួចហើយ ដូចបានបញ្ជាក់នៅក្នុងសេចក្តីព្រាងផែនការ EMDP នឹងមិនត្រូវបានបន្ថយចំនួនឱ្យនៅតិចជាងមុន ឬកាត់បន្ថយឱ្យនៅតិចជាងមុនបានឡើយ។ ប្រសិនបើកំណត់ឃើញថាមានក្រុមជនជាតិភាគតិចថ្មីៗទៀត មុនពេលដាក់ស្នើសុំកាតយល់ព្រមលើផែនការ EMDP ចុងក្រោយ ចាំបាច់ត្រូវរៀបចំឱ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយក្រុមជនជាតិភាគតិចទាំងនោះផងដែរ។

## ក. គារាខផលប៉ះពាល់ដោយសារគម្រោខ

៤៥. គ្រួសារជនជាតិភាគតិច អាចនឹងទទួលផលប៉ះពាល់ដោយសារអនុគម្រោង CLHVCIP នៅក្នុងទម្រង់ផ្សេងៗគ្នាជាច្រើនដូចជា៖ (១). ម្ចាស់ដីដែលរស់នៅជិតមណ្ឌលចត្តាឡីស័ក និងតំបន់គ្រប់គ្រងជំងឺដែលបានស្នើឡើងសម្រាប់ខេត្តត្បូងឃ្មុំ ដែលមានច្រកព្រំដែនសំខាន់ឆ្លងទៅកាន់ប្រទេសវៀតណាម និងបណ្តាស្រុកជាប់ៗគ្នា ដែលមានជនជាតិចាមក្នុងខេត្តសរុបចំនួន ៨៦.៤៨១ នាក់ ទោះបីជាខេត្តទាំងមូលមិនត្រូវបានរាប់បញ្ចូលក្នុងគម្រោងក៏ដោយ, (២). ការធ្វើឱ្យប្រសើរឡើងនូវទីសត្តឃាត និងតម្រូវការដែលសត្វពាហនៈធំៗទាំងអស់ត្រូវបញ្ជូនទៅកាន់ទីសត្តឃាតនោះ ប៉ុន្តែកន្លែងណាដែលបច្ចេកទេសសត្តឃាតហាឡាល់ (Halal) ត្រូវបានប្រានចោលដោយផ្អែកលើមូលដ្ឋានថាជាសកម្មភាពគ្មានមេត្តាធម៌។, (៣). មិនត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកម្មវិធី "One Health" ដើម្បីកំណត់គោលដៅនៅគ្រប់ភូមិទាំងអស់នៅក្នុងតំបន់គម្រោង, (៤). លទ្ធភាពទទួលតិចតួចជាងក្នុងការទទួលបានវ៉ាក់សាំងដែលត្រូវបានផលិតដោយមជ្ឈមណ្ឌលជាតិ NVVC, និង (៥) ការចូលរួមក្នុងកម្មវិធីបង្កាត់ពូជសត្វ ដូចជាការទទួលបានទឹកកាមដែលបង្កើតដោយ AI ។

៤៥. ផ្អែកលើការរៀបចំគម្រោង CLHVCIP និងប្រភេទនៃអនុគម្រោងដែលបានកំណត់ ផលប៉ះពាល់ទាំងឡាយលើគ្រួសារជនជាតិភាគតិច ត្រូវបានកំណត់ឃើញ ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។

## តារាងទី 2. ផលប៉ះពាល់ដោយសារគម្រោង

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| លទ្ធផលទី ១៖ ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វនិងខ្សែប្រវាក់តម្លៃសត្វត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ។ | សកម្មភាព ១.១៖ តំបន់គ្រប់គ្រងជំងឺសត្វ<br><br>សកម្មភាព ១.២៖ ការកែលម្អពូជសត្វ<br><br>សកម្មភាព ១.៣៖ ហេដ្ឋារចនាសម្ព័ន្ធខ្សែប្រវាក់តម្លៃសត្វ<br><br>សកម្មភាព ១.៤៖ មន្ទីរពិសោធន៍រោគវិនិច្ឆ័យ និងការផលិតវ៉ាក់សាំង | ▪ បច្ចេកវិទ្យា និងការអនុវត្តរបស់ DCZ ត្រូវបានពង្រីកទៅតំបន់ដែលមានផ្ទុះជំងឺអុតក្តាម ជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺផ្សេងទៀត និងតំបន់ងាយរងគ្រោះ<br>▪ ការផលិត សារៈសំខាន់ ការស្តុក និងការចែកចាយទឹកកាមកកគោពូជ<br>▪ មជ្ឈមណ្ឌលជាតិបណ្តុះបណ្តាលស្តីពី AI និងអគ្គនាយកដ្ឋាន GAHP<br>▪ ស្ថានីយ៍ផលិតអាសូតរាវ និងកន្លែងគ្រប់គ្រងសំណល់សត្វ<br>▪ ការទិញមេពូជដើមកំណើតក្រៅប្រទេស និងពូជដែលល្អសម្រាប់ផលិតទឹកកាម<br>▪ ការកែលម្អការអនុវត្តការបង្កាត់ពូជសម្រាប់បសុបក្សី រួមទាំងវិធីសាស្ត្រនៃការផ្សាំ និងការជ្រើសរើសពូជ។<br>▪ ការសាងសង់ផ្សារសត្វ ទីសត្តឃាត កន្លែងលក់សាច់ និងកែច្នៃសាច់<br>▪ លទ្ធភាពនៃការបង្កើតកម្មវិធីគាំទ្រផែនការអាជីវកម្ម ដើម្បីជំរុញសហគ្រិន "អ្នកជំរុញដំបូង" ឱ្យវិនិយោគលើផ្សារសត្វ ទីសត្តឃាត កន្លែងស្តុកត្រជាក់ ផ្សារលក់សាច់ និងការកែច្នៃផលិតផលសត្វ។ | ▪ លទ្ធភាព គឺថាមិនមែនគ្រួសារក្រីក្រទាំងអស់ដែលចិញ្ចឹមសត្វនឹងទទួលបានអត្ថប្រយោជន៍ពីសកម្មភាពដែលបានរៀបចំឡើងដើម្បីជួយសម្រួលដល់ការដាក់បញ្ចូលបច្ចេកវិទ្យាថ្មីៗ និងទម្រង់បែបបទផលិតកម្ម ឬអាជីវកម្មការនាំសត្វចេញ សុវត្ថិភាពផលិតផលសាច់ និងភាពសម្បូរបែប ដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេដែលបានមកពីប្រព័ន្ធគ្រប់គ្រងបសុសត្វដែលត្រូវផ្លាស់ប្តូរ។ | ▪ ជនជាតិភាគតិចដែលចិញ្ចឹមសត្វភាគច្រើនត្រូវបានកំណត់ឃើញ គឺត្រូវបានទទួលឥទ្ធិពលពីវប្បធម៌ និងជំនឿសាសនាខុសគ្នាខ្លះ ជាងជនជាតិភាគតិចខ្មែរ ដែលចិញ្ចឹមសត្វភាគច្រើន។<br>▪ ខណៈដែលមានភាពលំអៀង និងការរើសអើងតិចតួចចំពោះក្រុមជនជាតិភាគតិចសំខាន់ៗ នៅក្នុងគម្រោងតាមខេត្ត បើប្រៀបធៀបទៅនឹងជនជាតិវៀតណាមមួយចំនួន មិនមានការរឹតត្បិតណាមួយជាផ្លូវការលើលទ្ធភាពទទួលបានសេវាពីរាជរដ្ឋាភិបាល ដែលនឹងប៉ះពាល់ដល់ការចូលរួមរបស់ពួកគេនៅក្នុងគម្រោងនោះទេ។ |

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| | | ▪ ការសាងសង់ទីសត្តឃាតគំរូមួយដែលមានបំពាក់ដោយម៉ាស៊ីនត្រជាក់ និងបរិក្ខារគ្រប់គ្រងសំណល់ផ្សារក្រមួន និងមន្ទីរពិសោធន៍ដែលពាក់ព័ន្ធសម្រាប់ធ្វើតេស្តសំណល់រហ័ស។<br>▪ ទីសត្តឃាតគំរូនឹងបំពេញតាមតម្រូវការនៃការបញ្ជាក់ទទួលស្គាល់សម្រាប់ GMP និង HACCP<br>▪ ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនៅ NAHPRI ដើម្បីបំពេញតាមស្តង់ដាជីវសុវត្ថិភាពកម្រិត ២ និង ISO 17025<br>▪ ការផ្តល់បរិក្ខារអនុលោមតាមស្តង់ដារ ISO សម្រាប់ការវិនិច្ឆ័យរក និងតាមដានជំងឺសត្វ ជំងឺឆ្លងពីសត្វទៅមនុស្ស ចំណីសត្វ និងផលិតផលពេទ្យសត្វ<br>▪ ការបង្កើតមជ្ឈមណ្ឌលជាតិផលិតវ៉ាក់សាំង ដែលមានសមត្ថភាពផលិតវ៉ាក់សាំងតាមស្តង់ដា GMP និង ISO<br>▪ ការគាំទ្រការធ្វើផែនការវិនិយោគអាជីវកម្មសម្រាប់អ្នកចិញ្ចឹម ឬផលិតខ្នាតតូច អាជីវកម្មកសិឧស្សាហកម្មខ្នាតតូច និងមធ្យម និងកសិពាណិជ្ជកម្មខ្នាតធំ<br>▪ ការផ្តល់ឱកាសកាន់តែច្រើនសម្រាប់អ្នកចិញ្ចឹមសត្វខ្នាតតូចដើម្បីទទួលបានតម្លៃលក់កាន់តែ | | ▪ ទោះបីជាមានចំណុចដូចខាងលើក៏ដោយ ដោយសារតែមានទិដ្ឋភាពមួយចំនួននៃគម្រោងដែលទាក់ទងនឹងការសាងសង់ NVVC, NCBCR និង NAHPRI វាអាចទៅរួចដែលថាក្រុមជនជាតិមួយចំនួនផ្សេងទៀត ជាពិសេសជនជាតិវៀតណាមអាចប្រឈមមុខនឹងការរឹតត្បិតមួយចំនួនក្នុងការទទួលបានសេវាបែបនេះ ទោះបីជាក្រុមនេះជាពិសេសនៅតំបន់ជនបទមានការពាក់ព័ន្ធក៏ដោយ។ សកម្មភាពនៃការនេសាទ និងការជួញដូរច្រើនជាងការចិញ្ចឹមសត្វ |

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| | | ប្រសើរ តាមរយៈការចូលរួមក្នុងប្រព័ន្ធខ្សែច្រវាក់តម្លៃ<br>▪ ការការពារបរិស្ថាន និងសង្គម ដែលធានាថាប្រជាពលរដ្ឋដែលពាក់ព័ន្ធ នឹងមិនរងផលប៉ះពាល់ជាអវិជ្ជមានដោយសារអនុគម្រោង<br>▪ ការរួមចំណែកដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការកែលម្អភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | | |
| លទ្ធផលទី ២៖ សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលសត្វ ត្រូវបានពង្រឹង។ | សកម្មភាព ២.១៖ សេវាកម្មផលិតកម្មសត្វ<br><br>សកម្មភាព ២.២៖ សេវាសុខភាពសត្វ និងសុវត្ថិភាពចំណីអាហារ ដែលគាំទ្រដោយប្រព័ន្ធ ICT<br><br>សកម្មភាព ២.៣៖ សេវាកែលម្អខ្សែច្រវាក់តម្លៃសត្វ | ▪ ការអនុវត្តការចិញ្ចឹមសត្វល្អដែលអនុលោមតាមអាស៊ាន តាមរយៈក្រុមកសិករខ្នាតតូច<br>▪ ការបង្កើតកម្មវិធីអភិវឌ្ឍន៍ចំណីសត្វប្រកបដោយនិរន្តរភាព ដើម្បីលើកកម្ពស់ផលិតកម្មសត្វ និងបង្កើនប្រាក់ចំណូល<br>▪ ការបង្កើតបណ្តាញអ្នកផ្តល់សេវា AI ឯកជន រួមទាំង ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs)<br>▪ ការផ្តល់ការបណ្តុះបណ្តាលការកែលម្អពូជសត្វ រួមទាំងការគ្រប់គ្រងព័ត៌មានវិទ្យា<br>▪ ការបង្កើតសេវាសុខភាពសត្វឯកជន រួមទាំងការចេញវិញ្ញាបនបត្របញ្ជាក់ទទួលសម្រាប់ VAHWs<br>▪ ការអនុវត្តកម្មវិធីត្រួតពិនិត្យសុខភាពសត្វ<br>▪ ការបង្កើតកម្មវិធីកំណត់អត្តសញ្ញាណសត្វ តាមរយៈប្រព័ន្ធកំណត់អត្តសញ្ញាណសត្វតាមទូរសព្ទដៃ | ▪ មិនមានផលប៉ះពាល់អវិជ្ជមានជាទូទៅទេ ទោះបីជាសកម្មភាពដែលពាក់ព័ន្ធជាមួយកម្មវិធីអភិវឌ្ឍន៍ចំណីសត្វ អាចបង្កើតភាពតានតឹងខ្លះ ប្រសិនបើដីដែលត្រូវបានបម្រុងទុកសម្រាប់ការចូលប្រើប្រាស់តាមភូមិទូទៅត្រូវរងផលប៉ះពាល់។ | ជនជាតិភាគតិចដែលចិញ្ចឹមសត្វភាគច្រើនត្រូវបានកំណត់ឃើញ គឺត្រូវបានទទួលឥទ្ធិពលពីវប្បធម៌ និងជំនឿសាសនាខុសគ្នាខ្លះ ជាងជនជាតិភាគតិចខ្មែរដែលចិញ្ចឹមសត្វភាគច្រើន។<br><br>▪ ការអភិវឌ្ឍន៍សេវាគាំទ្រ ICT ជាទូទៅ គឺជាគំនិតដ៏ល្អមួយ ប៉ុន្តែគម្រោងត្រូវតែយល់ដឹងពីការពិតដែលថាគ្រួសារជនជាតិភាគតិចចំនួនតិចតួចតែប៉ុណ្ណោះ ដែលមានទូរសព្ទស្មាតហ្វូនប្រើ។ |

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| | | ▪ ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ទីរពិសោធន៍ដែលដំណើរការបានតាមអ៊ីនធឺណិតដែលទាក់ទងជាមួយ AHIS ដើម្បីតាមដាន និងកត់ត្រាសត្វចិញ្ចឹម<br>▪ ការពង្រីកកម្មវិធីវិនិច្ឆ័យរោគរាតត្បាត ដើម្បីបង្កើនសមត្ថភាពតាមដានជំងឺ និងជំងឺឆ្លងកាត់ព្រំដែន ជំងឺឆ្លងពីសត្វទៅមនុស្ស និងជំងឺឆ្លងរាលដាលតាមតំបន់ DCZs ការធ្វើពាណិជ្ជកម្ម និងកម្មវិធី "One Health"<br>▪ កម្មវិធីកសាងសមត្ថភាពដើម្បីគាំទ្រការវិនិយោគហេដ្ឋារចនាសម្ព័ន្ធក្រោមលទ្ធផល ១, ការបណ្តុះបណ្តាលស្តីពីរបៀបសម្លាប់សត្វប្រកបដោយមេត្តាធម៌ ការកែច្នៃសាច់សត្វ និងអនាម័យផលិតផល ការត្រួតពិនិត្យសាច់ ការគ្រប់គ្រងបរិក្ខារត្រជាក់ GMP និង HACCP និងការចាប់យកទិន្នន័យស្តីពីការកំណត់អត្តសញ្ញាណសត្វ និងការសម្លាប់សត្វ។<br>▪ លើកកម្ពស់សុវត្ថិភាពចំណីអាហារសម្រាប់អ្នកប្រើប្រាស់ផលិតផលសត្វ<br>▪ គោលការណ៍ SOP សម្រាប់បរិស្ថាន សុខភាព និងសុវត្ថិភាព | | |

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| | | ▪ ការបណ្តុះបណ្តាលស្តីពីការរៀបចំផែនការអាជីវកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ទីផ្សារ និងសហគ្រិនភាព<br>▪ ការបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាព និងបរិស្ថាន ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ | | |
| លទ្ធផលទី ៣៖ ការរៀបចំជំរុញការអនុវត្តគោលនយោបាយសម្រាប់ការផ្គត់ផ្គង់សុខភាព សុវត្ថិភាព និងពាណិជ្ជកម្ម និងផលិតផលសត្វ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។ | សកម្មភាព ៣.១៖ ការគាំទ្រគោលនយោបាយបសុសត្វជាតិ<br><br>សកម្មភាព ៣.២៖ គោលនយោបាយពាណិជ្ជកម្មសត្វឆ្លងកាត់ព្រំដែន<br><br>សកម្មភាព ៣.៣៖ បទប្បញ្ញត្តិនិងស្តង់ដា<br><br>សកម្មភាព ៣.៤ | ▪ ការគាំទ្រគោលនយោបាយឆ្លើយតបនឹងយេនឌ័រ និងមានមេត្រីភាពចំពោះអាកាសធាតុសម្រាប់ការរួមបញ្ចូលម្ចាស់អាជីវកម្មខ្នាតតូច និងការលើកកម្ពស់<br>តួនាទីរបស់ស្ត្រីក្នុងវិស័យផលិតសត្វ និងការបន្ថែមតម្លៃ<br>▪ គោលនយោបាយធនធានហ្សែនសម្រាប់ការអភិរក្សធនធានហ្សែនសត្វចិញ្ចឹម<br>▪ គោលនយោបាយលើកកម្ពស់សក្តានុពលអាជីវកម្មផ្នែក AI<br>▪ គោលនយោបាយពិពិធកម្មដើម្បីណែនាំការវិនិយោគក្រោមលទ្ធផលទី ២<br>▪ ប្រព័ន្ធពិពិធកម្មការចិញ្ចឹមសត្វ ដើម្បីចូលរួមជាមួយ VAWHs និងកសិករសំខាន់ៗ | ▪ មិនមានផលប៉ះពាល់អវិជ្ជមាននោះទេ។ | ▪ ផ្តល់ការធានាថាគោលនយោបាយទាំងឡាយដែលអនុញ្ញាតឱ្យអនុវត្តបាន ក៏ត្រូវតែធ្វើការផ្សព្វផ្សាយទៅដល់ក្រុមជនជាតិភាគតិចផងដែរ និងជាទម្រង់ទាំងឡាយណាដែលងាយយល់សម្រាប់ពួកគេ។ |

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| | វិស័យអភិវឌ្ឍន៍បសុសត្វឯកជន | ▪ គោលនយោបាយសម្រាប់ការអភិវឌ្ឍន៍ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីសម្រួលដល់ការទំនាក់ទំនងរវាងកសិករនិងកសិករ<br>▪ កម្មវិធី "One Stop Shop" សម្រាប់ចលនាសត្វក្នុងស្រុក និងឆ្លងកាត់ព្រំដែន និងការបង់ពន្ធដោយប្រើទម្រង់ឌីជីថលដែលអាចចូលប្រើបានតាមទូរសព្ទដៃ<br>▪ ការគ្រប់គ្រងព័ត៌មាន ការអនុវត្តបទប្បញ្ញត្តិ និងដំណើរការចេញវិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់ តាមរយៈការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសត្វឌីជីថល។<br>▪ ច្បាប់ស្តីពីការកំណត់អត្តសញ្ញាណបសុសត្វ ការការពារជំងឺ ការតាមដាន និងការត្រួតពិនិត្យ។<br>▪ ការអនុវត្តស្តង់ដាជាតិ និងអន្តរជាតិសម្រាប់ការបង្កើត និងការអនុលោមតាមស្តង់ដាស្តីពីកំណត់កម្រិតអតិបរមានៃការប្រើប្រាស់ថ្នាំអង់ទីប៊ីយោទិក និងការហាមឃាត់ការប្រើប្រាស់សារធាតុជំរុញការលូតលាស់ក្នុងចំណីសត្វ។<br>▪ ការអភិវឌ្ឍន៍ និងការផ្សារភ្ជាប់តួនាទីទំនាក់ទំនងរវាងវិស័យរដ្ឋនិងឯកជន ក្នុងការផ្តល់សេវាសុខភាពសត្វ | | |

| លទ្ធផល | សកម្មភាព | ផលប៉ះពាល់វិជ្ជមានទៅលើអ្នកទទួលផលគម្រោង | ផលប៉ះពាល់អវិជ្ជមាន | បញ្ហាដែលប៉ះពាល់ ដល់ក្រុមជនជាតិភាគតិច |
|---|---|---|---|---|
| | | ▪ រៀបចំក្របខណ្ឌច្បាប់ថ្មីសម្រាប់ការធ្វើកសិកម្មតាមកិច្ចសន្យាចំពោះផលិតកម្មចំណី និងផលិតកម្មសត្វសត្វ ដែលកំណត់ពីការរៀបចំកិច្ចសន្យាជាក់លាក់ និងការចែកចាយប្រកបដោយសមធម៌បន្ថែមទៀត រវាងអ្នកម៉ៅការ និងអ្នកផលិតខ្នាតតូច<br>▪ ការកៀរគរការវិនិយោគរបស់វិស័យឯកជន តាមរយៈក្របខ័ណ្ឌគោលនយោបាយ PPCP | | |

## ខ. គោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌអភិវឌ្ឍន៍ជនជាតិភាគតិច

៤៧. ដូចបានបញ្ជាក់ក្នុងលទ្ធផល និងសកម្មភាពរបស់គម្រោង CLHVCIP និងយោងតាមផលប៉ះពាល់ដែលបានកំណត់ឃើញខាងលើ គម្រោងសង្ឃឹមថាតម្រូវការចម្បងនៃផែនការអភិវឌ្ឍន៍ជនជាតិភាពតិច (EMDP) នឹងអាចដោះស្រាយបញ្ហាទាក់ទងនឹងបរិយាប័ន្ន និងការចូលរួម និងជាពិសេសការពិគ្រោះយោបល់ និងការចែករំលែកព័ត៌មាន។ ដូច្នេះ គម្រោងរំពឹងថាសកម្មភាព និងការណែនាំខាងក្រោម នឹងក្លាយជាកត្តារួមទូទៅនៅក្នុង EMDPដែលបានរៀបចំសម្រាប់អនុគម្រោងទាំងអស់នៃគម្រោង CLHVCIP ។ សកម្មភាពចង្អុលបង្ហាញដូចខាងក្រោមនេះគឺជាចំណុចសំខាន់ចាំបាច់ក្នុងគម្រោងផ្សេងទៀត ដែលពាក់ព័ន្ធនឹងជនជាតិភាគតិច ហើយការស្នើសុំរបស់ពួកគេនឹងត្រូវបានបញ្ជាក់ និងពន្យល់ក្នុងអំឡុងពេលរៀបចំផែនការ EMDP ។

**តារាងទី 3. សកម្មភាពនានាក្រោមផែនការអភិវឌ្ឍន៍ជនជាតិភាគតិច**

| លទ្ធផលគម្រោង | សកម្មភាព | ការណែនាំ |
|---|---|---|
| លទ្ធផលទី ១៖ ហេដ្ឋារចនាសម្ព័ន្ធសុខភាពសត្វនិងខ្សែច្រវាក់តម្លៃសត្វ ត្រូវបានពង្រីក និងធ្វើឱ្យប្រសើរឡើងក្នុងលក្ខណៈសមស្របទៅនឹងអាកាសធាតុ។<br><br>លទ្ធផលទី ២៖ សមត្ថភាពក្នុងការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ និងផលិតផលសត្វត្រូវបានពង្រឹង។ | សកម្មភាព ១.១៖ តំបន់គ្រប់គ្រងជំងឺសត្វ<br><br>សកម្មភាព ១.២៖ ការកែលម្អពូជសត្វ<br><br>សកម្មភាព ១.៣៖ ហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃសត្វ<br><br>សកម្មភាព ១.៤៖ មន្ទីរពិសោធន៍រោគវិនិច្ឆ័យ និងការផលិតវ៉ាក់សាំង<br><br>សកម្មភាព ២.១៖ សេវាកម្មផលិតកម្មសត្វ<br><br>សកម្មភាព ២.២៖ សេវាសុខភាពសត្វ និងសុវត្ថិភាពចំណីអាហារដែលគាំទ្រដោយប្រព័ន្ធ ICT | ▪ ពិនិត្យជាមួយក្រុមប្រឹក្សាឃុំ ថាតើក្រុមជនជាតិជាក់លាក់ អាចទំនាក់ទំនងជាភាសាខ្មែរបានដែរឬទេ។<br>▪ បញ្ជាក់ឱ្យបានច្បាស់នៅកម្រិតសហគមន៍ ថាតើមនុស្សទាំងអស់ដែលត្រូវពិគ្រោះយោបល់ មានភាពងាយស្រួលក្នុងការប្រើប្រាស់ភាសាខ្មែរដែរឬទេ។<br>▪ ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះមនុស្សវ័យចំណាស់ ជាពិសេសស្ត្រីដែលមិនសូវយល់ភាសាខ្មែរ។<br>▪ ត្រូវប្រាកដថាសមាជិកទាំងអស់ក្នុងក្រុមគម្រោងអាចយល់ច្បាស់លាស់ពីពិធីសារវប្បធម៌ទាក់ទងនឹងការពិគ្រោះយោបល់។<br>▪ ក្នុងករណីដែលអាចធ្វើទៅបាន និងតាមជាក់ស្តែង យ៉ាងហោចណាស់អ្នកសម្របសម្រួលម្នាក់គួរតែជាអ្នកដឹកនាំក្រុមជនជាតិភាគតិចដែលកំពុងត្រូវបានពិគ្រោះយោបល់។<br>▪ ប្រសិនបើជំងឺរាតត្បាតកូវីដ-១៩ នៅតែជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់ ត្រូវតែអនុវត្តវិធានការចាំបាច់ទាំងអស់ដើម្បីបញ្ចៀសការឆ្លង។<br>▪ ប្រើប្រាស់ការពិភាក្សាក្រុមជនជាតិដាច់ដោយឡែក ប្រសិនបើជនជាតិភាគតិចពេញចិត្តនៅក្នុងការពិភាក្សាចម្រុះជនជាតិ។<br>▪ ប្រើប្រាស់ការពិភាក្សាជាក្រុមតាមភេទបុរស និងស្ត្រីដាច់ដោយឡែក ដើម្បីកំណត់សកម្មភាពអាទិភាពដែលត្រូវបានណែនាំដោយគម្រោង។<br>▪ ត្រូវប្រាកដថាសកម្មភាពទាំងអស់ តួយ៉ាងដូចជាសកម្មភាពដែលបានគិតគូរតាមរយៈកម្មវិធី "One Health" ត្រូវបាន |

| លទ្ធផលគម្រោង | សកម្មភាព | ការណែនាំ |
|---|---|---|
| លទ្ធផលទី ៣៖ ការរៀបចំជំរុញការអនុវត្តគោលនយោបាយសម្រាប់ការផ្គត់ផ្គង់ សុខភាព សុវត្ថិភាព និង ពាណិជ្ជកម្ម និងផលិតផលសត្វ ត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។ | សកម្មភាព ២.៣៖ សេវាកែលម្អខ្សែច្រវាក់តម្លៃសត្វ<br><br>សកម្មភាព ៣.១៖ ការគាំទ្រគោលនយោបាយបសុសត្វជាតិ<br><br>សកម្មភាព ៣.២៖ គោលនយោបាយពាណិជ្ជកម្មសត្វឆ្លងកាត់ព្រំដែន<br><br>សកម្មភាព ៣.៣៖ បទប្បញ្ញត្តិនិងស្តង់ដា<br><br>សកម្មភាព ៣.៤ វិស័យអភិវឌ្ឍន៍បសុសត្វឯកជន | កំណត់គោលដៅ និងផ្តល់អត្ថប្រយោជន៍ដល់សមាជិកទាំងអស់នៃក្រុមជនជាតិនីមួយៗ។<br>▪ ធានាថាជនជាតិភាគតិចត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលដោយស្មើៗគ្នា ជាពិសេសតាមរយៈគោលនយោបាយផ្សព្វផ្សាយបន្តក្នុងនាមជាជនជាតិខ្មែរ។<br>▪ ធានាថាជាជនជាតិភាគតិចដែលកំពុងស្នើសុំការគាំទ្រផែនការវិនិយោគអាជីវកម្ម ត្រូវបានផ្តល់ជូនក្នុងកម្រិតដូចគ្នាលើការបង្វឹក និងការណែនាំដើម្បីរៀបចំ EOI និង BP ក្នុងនាមជាជនជាតិខ្មែរ។<br>▪ ធានាថាគោលនយោបាយដែលអាចអនុញ្ញាតបានទាំងអស់ និងរបៀបដែលពួកគេអាចជះឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានលើជនជាតិភាគតិច ត្រូវបានផ្សព្វផ្សាយ និងយល់ជ្រួតជ្រាបយ៉ាងពេញលេញ។<br>▪ សង្កត់ធ្ងន់ថាជនជាតិភាគតិចទាំងអស់ សុទ្ធតែមានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន និងពន្យល់ពីគោលការណ៍របស់ FPIC ដើម្បីធានាថា ជនជាតិភាគតិចមានសិទ្ធិបដិសេធមិនចូលរួមក្នុងការពិគ្រោះយោបល់ ប្រសិនបើពួកគេមិនចាប់អារម្មណ៍។ |

## គ. ការពិគ្រោះយោបល់ និងការចូលរួមពីភាគីពាក់ព័ន្ធ

៤៨. ការពិគ្រោះប្រកបដោយអត្ថន័យជាមួយជនជាតិភាគតិច នឹងត្រូវបានធានាតាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រទំនាក់ទំនងសមស្របតាមវប្បធម៌ និងការប្រើប្រាស់ភាសាក្នុងតំបន់តាមជាក់ស្តែង។ ទោះបីជាជនជាតិភាគតិចភាគច្រើននៅក្នុងខេត្តគោលដៅគម្រោង អាចមានសមត្ថភាពប្រើប្រាស់ភាសាខ្មែរខ្លះក៏ដោយ ក៏អាចត្រូវបានកំណត់ថាជនជាតិភាគតិចនៅក្នុងតំបន់គោលដៅជាក់លាក់ត្រូវការជំនួយផ្នែកបកប្រែ។ ធនធានគ្រប់គ្រាន់ (ធនធានមនុស្ស និងហិរញ្ញវត្ថុ) នឹងត្រូវដាក់បញ្ចូលក្នុងផែនការ EMDP ដើម្បីធានាបាននូវការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ជនជាតិភាគតិចដែលរងផលប៉ះពាល់។

៤៩. តារាងខាងក្រោមបង្ហាញពីចំណុចច្បាស់លាស់សម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅទូទាំងវដ្តគម្រោងក្រោម CLHVCIP ផែនការពិគ្រោះយោបល់នេះនឹងត្រូវអនុវត្តដើម្បីធានាឱ្យមានការចូលរួមដោយជូនដំណឹងជាមុនគ្រប់ដំណាក់កាលនៃវដ្តគម្រោង។ គម្រោងនឹងផ្តល់ព័ត៌មានដែលពាក់ព័ន្ធឱ្យបានទាន់ពេលវេលា និងគ្រប់គ្រាន់ ដែលអាចងាយយល់ និងអាចរកបានសម្រាប់ក្រុមមនុស្ស និងបែងចែកទៅតាមភេទ ដែលរងផលប៉ះពាល់ ក្នុងបរិយាកាស

ដែលគ្មានការបំភិតបំភ័យ ឬការបង្ខិតបង្ខំឡើយ។ គម្រោងលើកទឹកចិត្តឱ្យប្រើប្រាស់ក្រុមពិភាក្សាដាច់ដោយឡែក ដោយបែងចែកទៅតាមភេទ និងជនជាតិ ក្នុងករណីដែលអនុគម្រោងកំពុងអនុវត្តនៅក្នុងសហគមន៍ដែលមានចម្រុះជនជាតិ។

**តារាងទី 4. ផែនការពិគ្រោះយោបល់**

| ដំណាក់កាល | អ្នកពាក់ព័ន្ធ | សកម្មភាព | លទ្ធផលរយៈពេលវែង |
|---|---|---|---|
| ១. ការកំណត់អត្តសញ្ញាណអនុគម្រោង | ▪ ភ្នាក់ងារប្រតិបត្តិគម្រោង<br>▪ ថ្នាក់ក្រសួង<br>▪ ថ្នាក់ខេត្ត និងស្រុក<br>▪ ភ្នាក់ងារអនុវត្តគម្រោងនៅថ្នាក់ខេត្ត និងស្រុក<br>▪ អាជ្ញាធរឃុំ និងភូមិ<br>▪ គ្រួសារគោលដៅដែលទទួលផលទទួលផលពីគម្រោង<br>▪ សមាជិកនៃក្រុមងាយរងគ្រោះ ឬជនជាតិភាគតិច<br>▪ ជំនួយបច្ចេកទេសគម្រោង | ▪ ការប្រជុំរវាងរដ្ឋាភិបាល និងទីភ្នាក់ងារដើម្បីពន្យល់ពីតម្រូវការសម្រាប់កិច្ចគាំពារ យល់ព្រមលើលក្ខខណ្ឌជ្រើសរើស។<br>▪ ការកំណត់វិសាលភាព - ដំណើរចុះពិនិត្យទីតាំងសំខាន់ៗ និងការត្រួតពិនិត្យស្ថានភាពរូបវន្ត។<br>▪ ការប្រជុំ និងផ្តល់ព័ត៌មានខ្លីជាមួយភ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្ត និងស្រុក។<br>▪ ការប្រជុំជាមួយអាជ្ញាធរឃុំ និងភូមិ។<br>▪ ការប្រជុំជាមួយអ្នកទទួលផលគោលដៅ។ | ▪ ការព្រមព្រៀងលើ<br>▪ គោលបំណង អាទិភាព<br>▪ ការព្រមព្រៀងលក្ខខណ្ឌជ្រើសរើសអនុគម្រោង<br>▪ ការបង្ហាញសូចនាករអាទិភាពលើការអភិវឌ្ឍន៍សហគមន៍<br>▪ ការកំណត់ឱ្យឃើញរឿងរ៉ាង និងបញ្ហាផ្សេងៗ<br>▪ តម្រូវកាជាមូលដ្ឋាននៃការរៀបចំគម្រោង<br>▪ ការកត់ត្រាការចូលរួមរបស់ប្រជាសហគមន៍ ដោយបែងចែកទៅតាមភេទ និងជនជាតិ |
| ២. ការរៀបចំអនុគម្រោង | ▪ ភ្នាក់ងារប្រតិបត្តិគម្រោង<br>▪ ថ្នាក់ក្រសួង<br>▪ ថ្នាក់ខេត្ត និងស្រុក<br>▪ ភ្នាក់ងារអនុវត្តគម្រោងនៅថ្នាក់ខេត្ត និងស្រុក<br>▪ អាជ្ញាធរឃុំ និងភូមិ<br>▪ គ្រួសារគោលដៅដែលទទួលផលទទួលផលពីគម្រោង<br>▪ សមាជិកនៃក្រុមងាយរងគ្រោះ ឬជនជាតិភាគតិច<br>▪ ជំនួយបច្ចេកទេសគម្រោង | ▪ កិច្ចប្រជុំជាមួយមន្ត្រីថ្នាក់ខេត្ត ស្រុក ឃុំ ភូមិ ដើម្បីពន្យល់ពីដំណើរការរៀបចំគម្រោង តម្រូវការទិន្នន័យ វិធីសាស្ត្រចូលរួម ដំណើរការពិគ្រោះយោបល់ និងតម្រូវការផ្នែកកិច្ចគាំពារសម្រាប់ជនជាតិដើមភាគតិច/ជនជាតិភាគតិច។<br>▪ បើកកិច្ចប្រជុំនៅភូមិដើម្បីពន្យល់ពីគោលបំណង និងដំណើរការនៃកិច្ចពិគ្រោះយោបល់។<br>▪ ការប្រមូលទិន្នន័យនៅតាមមូលដ្ឋាន – ទិន្នន័យសេដ្ឋកិច្ចសង្គម និងការធ្វើអង្កេត។ | ▪ ទិន្នន័យសម្រាប់ការរៀបចំប្រវត្តិស្ថានភាពសង្គម និងសេដ្ឋកិច្ច។<br>▪ ការកំណត់តម្រូវការ និបញ្ហាប្រឈម។<br>▪ ការកំណត់ការពិចារណាជាពិសេស។<br>▪ ការព្រមព្រៀងលើការយកចិត្តទុកដាក់របស់គម្រោង គោលបំណង និងសកម្មភាពចង្អុលបង្ហាញ។<br>▪ ការកំណត់បញ្ហាយេនឌ័រ តម្រូវការរបស់ស្ត្រី និងអាទិភាព។<br>▪ ការកំណត់តម្រូវការលើផ្នែកកិច្ចគាំពារ |

| ដំណាក់កាល | អ្នកពាក់ព័ន្ធ | សកម្មភាព | លទ្ធផលរយៈពេលវែង |
|---|---|---|---|
| | | ▪ ការប្រជុំជាមួយក្រុមគ្រួសារ និងក្រុមពិភាក្សាដើម្បីកំណត់ពីតម្រូវការចាំបាច់ – រួមមានការជួបប្រជុំជាមួយជនជាតិដើមភាគតិច/ គ្រួសារជនជាតិភាគតិច និងផ្អែកតាមយេនឌ័រ<br>▪ បែងចែកក្រុមពិភាក្សាដាច់ដោយឡែក។<br>▪ ការប្រមូលទិន្នន័យពីជនជាតិដើមភាគតិច / គ្រួសារជនជាតិភាគតិច។<br>▪ ការពិភាក្សាអំពីការរៀបចំគម្រោងដែលបានស្នើឡើង។ ទទួលមតិកែលម្អត្រឡប់ កំណត់កម្រិតនៃការគាំទ្រ។<br>▪ ការធ្វើបច្ចុប្បន្នកម្មការរាយការណ៍សង្ខេបសម្រាប់ភ្នាក់ងារខេត្ត និងស្រុក។ | ▪ ការកំណត់តម្រូវការផ្នែកសម្ភារៈផ្តល់ព័ត៌មានដែលត្រូវផលិតចងក្រងជាភាសាជនជាតិភាគតិច។<br>▪ ការកត់ត្រារបាយការណ៍នៃការចូលរួមរបស់ប្រជាសហគមន៍ដោយបែងចែកទៅតាមភេទ និងជនជាតិ។ |
| ៣. ការវាយតម្លៃអណុគម្រោង | ▪ ភ្នាក់ងារប្រតិបត្តិគម្រោងនៅថ្នាក់ក្រសួង<br>▪ ភ្នាក់ងារប្រតិបត្តិគម្រោងនៅនៅថ្នាក់ខេត្ត និងស្រុក<br>▪ ភ្នាក់ងារអនុវត្តគម្រោងនៅថ្នាក់ខេត្ត និងស្រុក<br>▪ អាជ្ញាធរឃុំ និងភូមិ<br>▪ គ្រួសារគោលដៅដែលទទួលផលទទួលផលពីគម្រោង<br>▪ សមាជិកនៃក្រុមងាយរងគ្រោះ ឬជនជាតិភាគតិច<br>▪ ជំនួយបច្ចេកទេសគម្រោង | ▪ ការបង្ហាញការរៀបចំគម្រោងសម្រាប់សហគមន៍។<br>▪ ការបង្ហាញសំណើបែងចែកក្រុមពិភាក្សាបង្គោលជាបុរស និងស្ត្រីសម្រាប់ការពិភាក្សា។<br>▪ ការជួបប្រជុំដាច់ដោយឡែកជាមួយគ្រួសារដែលរងផលប៉ះពាល់ និងសមាជិកនៃជនជាតិដើមភាគតិច ឬគ្រួសារជនជាតិភាគតិច។<br>▪ ការពិភាក្សាលើបញ្ហាកិច្ចគាំពារ និងវិធានការកាត់បន្ថយ ដែលបានស្នើឡើង។<br>▪ ការប្រជុំផ្សព្វផ្សាយ និងការពិគ្រោះយោបល់ជាមួយគ្រួសារដែលរងផលប៉ះពាល់ ដើម្បី | ▪ ការព្រមព្រៀងលើការរៀបចំគម្រោងចុងក្រោយ។<br>▪ ការព្រមព្រៀងលើកិច្ចគាំពារ និងវិធានការកាត់បន្ថយ។<br>▪ ការទទួលយកគម្រោងជាផ្លូវការ និងការចុះហត្ថលេខាលើឯកសារព្រមព្រៀងតាមតម្រូវការ។<br>▪ ការព្រមព្រៀងលើតម្រូវការចាំបាច់របស់ស្ត្រី និងអាទិភាពដែលត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពយេនឌ័រ។<br>▪ ការកត់ត្រារបាយការណ៍នៃការចូលរួមរបស់ប្រជាសហគមន៍ |

| ដំណាក់កាល | អ្នកពាក់ព័ន្ធ | សកម្មភាព | លទ្ធផលរយៈពេលវែង |
|---|---|---|---|
| | | ពិភាក្សាអំពីលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សង្គម។ | ដោយបែងចែកទៅតាមភេទ និងជនជាតិ។ |
| ៤. ការអនុវត្ត និង ការត្រួតពិនិត្យ តាមដានអនុគម្រោង | ▪ ភ្នាក់ងារប្រតិបត្តិគម្រោងនៅថ្នាក់ក្រសួង<br>▪ ភ្នាក់ងារប្រតិបត្តិគម្រោងនៅនៅថ្នាក់ខេត្ត និងស្រុក<br>▪ ភ្នាក់ងារអនុវត្តគម្រោងនៅថ្នាក់ខេត្ត និងស្រុក<br>▪ អាជ្ញាធរឃុំ និងភូមិ<br>▪ គ្រួសារគោលដៅដែលទទួលផលទទួលផលពីគម្រោង<br>▪ សមាជិកនៃក្រុមងាយរងគ្រោះ ឬជនជាតិភាគតិច<br>▪ ជំនួយបច្ចេកទេសគម្រោង | ▪ ការប្រជុំដើម្បីរៀបចំការរចនាប្លង់វិស្វកម្មលម្អិតចុងក្រោយ។<br>▪ ការបញ្ចូលមតិយោបល់របស់សហគមន៍ និងកែប្រែតាមការចាំបាច់។<br>▪ ការបង្ហាញដល់សហគមន៍ និងការទទួលយកដោយសហគមន៍លើការរចនាប្លង់លម្អិត និងការធ្វើបច្ចុប្បន្នកម្ម IPPs និងផែនការបែងចែកដីធ្លី និងការតាំងលំនៅជាថ្មី។<br>▪ ការជួបប្រជុំជាមួយសហគមន៍ដើម្បីរួមបញ្ចូលការប្រជុំដាច់ដោយឡែកជាមួយជនជាតិដើមភាគតិច/គ្រួសារជនជាតិភាគតិច និងក្រុមបង្គោល។<br>▪ ការប្រជុំជាបន្តជាមួយក្រុមបង្គោល ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្ត – ការប្រជុំដាច់ដោយឡែកជាមួយជនជាតិដើមភាគតិច/ក្រុមជនជាតិភាគតិច តាមការចាំបាច់។ | ▪ ការរៀបចំចងក្រង និងចែកចាយនូវរាល់សម្ភារៈផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ជាអក្សរ និងជាភាសាជនជាតិភាគតិច តាមតម្រូវការ។<br>▪ ការបញ្ចប់លើការរៀបចំឯកសារទាំងអស់ដែលបានព្រមព្រៀង។<br>▪ ការបញ្ចប់លើការរៀបចំរចនាប្លង់វិស្វកម្មលម្អិត។<br>▪ ការបញ្ចប់លើការរៀបចំផែនការ EMDP ផែនការបែងចែកដីធ្លី និងការតាំងទីលំនៅជាថ្មី។<br>▪ ការប្រមូលផ្តុំមតិកែលម្អត្រឡប់លើវឌ្ឍនភាពនៃការអនុវត្ត បញ្ហានានា និងកត្តាប្រឈម។<br>▪ ការកំណត់ឃើញពីតម្រូវលើការកសាងសមត្ថភាពបន្ថែម។<br>▪ ការកត់ត្រារបាយការណ៍ នៃការចូលរួមរបស់សហគមន៍ ដោយបែងចែកទៅតាមភេទ និងជនជាតិ។ |
| ៥. ការបញ្ចប់ និង ការវាយតម្លៃអនុគម្រោង | ▪ ភ្នាក់ងារប្រតិបត្តិគម្រោងនៅថ្នាក់ក្រសួង<br>▪ ភ្នាក់ងារប្រតិបត្តិគម្រោងនៅនៅថ្នាក់ខេត្ត និងស្រុក<br>▪ ភ្នាក់ងារអនុវត្តគម្រោងនៅថ្នាក់ខេត្ត និងស្រុក<br>▪ អាជ្ញាធរឃុំ និងភូមិ<br>▪ គ្រួសារគោលដៅដែលទទួលផលទទួលផលពីគម្រោង | ▪ ការប្រជុំជាមួយមន្ត្រីឃុំ និង ភូមិ ដើម្បីពិភាក្សាអំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមនានា។<br>▪ ការប្រជុំជាមួយក្រុមបង្គោល ដើម្បីកំណត់ឱ្យឃើញពីអត្ថប្រយោជន៍ដែលទទួលបានបញ្ហានៃការអនុវត្ត និងការកែលម្អតាមការចាំបាច់។ | ▪ មតិយោបល់សម្រាប់កែលម្អឱ្យកាន់តែប្រសើរឡើងទៅអនាគត។<br>▪ ការកត់ត្រារបាយការណ៍ នៃការចូលរួមរបស់សហគមន៍ ដោយបែងចែកទៅតាមភេទ និងជនជាតិ។ |

| ដំណាក់កាល | អ្នកពាក់ព័ន្ធ | សកម្មភាព | លទ្ធផលរយៈពេលវែង |
|---|---|---|---|
| | ▪ សមាជិកនៃក្រុមងាយរងគ្រោះ ឬជនជាតិភាគតិច<br>▪ ជំនួយបច្ចេកទេសគម្រោង | ▪ ការបែងចែកដាច់ដោយឡែកនូវការប្រជុំជាមួយក្រុមបង្គោលជនជាតិដើមភាគតិច ឬក្រុមបង្គោលជនជាតិភាគតិច តាមការចាំបាច់។ | |

## ឃ. ការចងក្រងឯកសារនៃដំណើរការពិគ្រោះយោបល់

៥០. ឯកសារនៃកិច្ចប្រជុំពិគ្រោះយោបល់ គឺមានសារសំខាន់ណាស់ និងត្រូវបង្ហាញពីការចូលរួមរបស់អ្នកពាក់ព័ន្ធជាដាច់ខាត ហើយត្រូវកត់ត្រាទិន្នន័យខាងក្រោមដែលជាទិន្នន័យត្រូវមានជាអប្បបរមា៖

(១). បរិបទនៃការជួបជុំគ្នា (ការពិគ្រោះយោបល់ ឬសកម្មភាពណាមួយដែលបានផ្តួចផ្តើមឡើងដោយ ពីគម្រោង CLHVCIP ដោយមានគោលបំណងនៃការធ្វើសកម្មភាព ធ្វើនៅទីណា ពេលណា នរណាខ្លះបានចូលរួម។

(២). កត់ត្រាខ្លឹមសារដែលបានជជែកពិភាក្សា សំណួរដែលបានចោទសួរ បញ្ហាដែលបានលើកឡើង និងដោយនរណា ព្រមទាំងការឆ្លើយតបរបស់បុគ្គលិកគម្រោងផងដែរ និងដោយបែងចែកទៅតាមភេទ និងជនជាតិ។

(៣). កត់សម្គាល់មើលប្រសិនបើក្រុមដែលចាប់អារម្មណ៍ណាមួយ មានប្រៀបលើការពិភាក្សា។

(៤). ប្រសិនបើចាំបាច់ ត្រូវបែងចែកដាច់ដោយឡែករវាកការពិភាក្សាជាមួយថ្នាក់ដឹកនាំ ឬមនុស្សដែលមានឥទ្ធិពល ចេញពីការពិភាក្សសំខាន់ៗ និងពិចារណាបង្កើតជាក្រុមពិភាក្សាមួយដាក់លាក់ "សម្រាប់ថ្នាក់ដឹកនាំ" ក្នុងក្នុងបំណងដើម្បីកាត់បន្ថយឥទ្ធិពលលើអ្នកចូលរួមផ្សេងទៀតអំឡុងពេលកិច្ចពិភាក្សា។

(៥). ធានាថាមានការកត់ត្រា ឬកំណត់ហេតុនៃកិច្ចពិភាក្សា ដោយមានកាលបរិច្ឆេទ និងបញ្ជីឈ្មោះអ្នកអ្នកចូលរួម និងបែងចែកអ្នកចូលរួមទៅតាមភេទ និងជនជាតិ។

៥១. សេចក្តីសង្ខេបនៃលទ្ធផលការពិភាក្សាជាក្រុម (FGD) ដោយមានការសម្របសម្រួលជាមួយជនជាតិចាម (ឬឥស្លាម) នៅក្នុងខេត្តកំពង់ចាម កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានបញ្ចូលជាឧបសម្ព័ន្ធ (ឧបសម្ព័ន្ធទី 1)។ លទ្ធផលនេះការពិភាក្សានេះ ផ្តោតជាពិសេសលើក្របខ័ណ្ឌ LSMGF ដែលអាចធ្វើជាឧទាហរណ៍នៃរបៀបចងក្រងឯកសារកិច្ចប្រជុំពិគ្រោះយោបល់បែបនេះបាន។

## ខ. ដំណោះស្រាយចំពោះគម្លាតយេនឌ័រ

៥២. ភាពខុសគ្នាដ៏សំខាន់រវាងតួនាទីស្ត្រី និងបុរស ឬបទដ្ឋានយេនឌ័រផ្សេងទៀត អាចមានឥទ្ធិពលជំផងទៅលើការអនុវត្តអនុគម្រោងនេះ។ ដោយសារតែគម្លាតយេនឌ័រ ជាធម្មតាបានបណ្តាលឱ្យស្ត្រី និងបុរសមានតម្រូវការ ការទាមទារចង់បាន និងឧបសគ្គខុសគ្នារៀងៗខ្លួន ដូច្នេះគេចាំបាច់ត្រូវកំណត់ឱ្យឃើញពីភាពខុសគ្នាទាំងនោះជាមុនក្នុងអំឡុងដំណើរការរៀបចំគម្រោង មុនពេលធ្វើការសម្រេចចិត្តសំខាន់។ ប្រសិនបើមិនយកចិត្តទុកដាក់លើភាពខុសគ្នាទាំងនោះទេ នោះការរំពឹងទុកក្នុងសម្រេចជោគជ័យលើការអនុវត្តគម្រោងនេះ អាចនឹងត្រូវរងផលប៉ះពាល់ ជាអវិជ្ជមាន ហើយស្ត្រីនឹងមិនអាចមានឱកាសទទួលបានអត្ថប្រយោជន៍អ្វីពីគម្រោងនេះដោយស្មើភាពជាមួយបុរសបានឡើយ។ ប្រពៃណីសង្គមដែលទាក់ទងទៅនឹងតួនាទីយេនឌ័រ ជាញឹកញាប់បណ្តាលឱ្យកើតមានមានបញ្ហាជាអាទិ៍៖

(១). វិសមភាពយេនឌ័រក្នុងការទទួលបាន និងការគ្រប់គ្រងធនធានសំខាន់ៗ

(២). វិសមភាពនៃឱកាសដែលត្រូវទទួលបានរវាងបុរស និងស្ត្រីនៅក្នុងវិស័យនានា ដូចជា ការអប់រំ ការដើរហើរ និងការធ្វើសេចក្តីសម្រេចជាសាធារណៈ។

(៣). មានការរើសអើងជាផ្លូវការ ឬមិនផ្លូវការប្រឆាំងនឹងស្ត្រីភេទនៅក្នុងវិស័យនានា ដូចជាការទទួកកេរមរតក (ឬមត៌កសម្បត្តិ) ការចុះបញ្ជីដីធ្លី ការទទួលបានកម្ចីឥណទាន និងឱកាសការងារ។

៥៣. ផែនការពិគ្រោះយោបល់ដែលបានបង្ហាញខាងលើនេះ រួមបញ្ចូលទាំងការពិភាក្សាដាច់ដោយឡែកជាមួយក្រុមស្ត្រី ព្រមទាំងការពិគ្រោះយោបល់ជាមួយនឹងស្ត្រីនៅកម្រិតគ្រួសារ ក្នុងគោលបំណងដើម្បីកំណត់ឱ្យឃើញពីតម្រូវការចាំបាច់ និងអាទិភាពជាក់លាក់របស់ស្ត្រីនៅក្នុងសហគមន៍នីមួយៗ។ ព័ត៌មានទាំងនេះ នឹងត្រូវប្រើប្រាស់ព្រមគ្នាជាមួយនឹងផែនការសកម្មភាពយេនឌ័ររបស់គម្រោង ដើម្បីបំពេញតម្រូវការសកម្មភាព និងការកាត់បន្ថយឧបសគ្គទាំងឡាយ។

## V. យន្តការដោះស្រាយបណ្តឹងតវ៉ា (ឬបណ្តឹងសាទុក្ខ)

៥៤. យន្តការនេះ សំដៅផ្តល់ឱ្យ និងសម្របសម្រួលសម្រាប់រកដំណោះស្រាយចំពោះការក្តីកង្វល់ ការតវ៉ា និងការប្តឹងផ្តល់ណាមួយរបស់ជនជាតិដើមភាគតិច ឬក្រុមជនជាតិភាគតិច ហើយពួកគេក៏នឹងត្រូវបានជូនដំណឹងយ៉ាងសមស្របអំពីយន្តការនេះផងដែរ។ ចំពោះ GRM កម្រិតគម្រោងនឹងត្រូវបានពិគ្រោះយោបល់ និងពិភាក្សាជាមួយក្រុមជនជាតិភាគតិច ក្នុងអំឡុងពេលរៀបចំ ផែនការ EMDP និងព័ត៌មានលម្អិត ឬផ្តល់លេខទំនាក់ទំនងរបស់អ្នកទទួលខុសត្រូវផ្នែក GRM ទៅដល់អ្នកដែលរងផលប៉ះពាល់ និងរួមបញ្ចូលក្នុង PIB ដែលនឹងត្រូវបញ្ជូនទៅ APs ។ យន្តការនេះទៀតសោត មានលក្ខណៈសមស្របទៅតាមវប្បធម៌ ជាលក្ខណៈឆ្លើយតបនឹងបញ្ហាយេនឌ័រ ដែលអាចចូលរួមបានដោយសេរី ប៉ុន្តែមិនមែនមានន័យថារារាំងចំពោះដំណោះស្រាយដែលសម្រេចដោយអំណាចតុលាការក្នុងប្រទេស ឬដំណោះស្រាយផ្នែករដ្ឋបាលនោះ។ មេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលដោះស្រាយវិវាទ ព្រមទាំងផ្សព្វផ្សាយអំពីច្បាប់ និងគោលនយោបាយនានាដែលពាក់ព័ន្ធ។ ព្រឹទ្ធាចារ្យក្នុងសហគមន៍ក៏ស្ថិតក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធជាក់លាក់ក្នុងសហគមន៍ជនជាតិភាគតិចផងដែរ ចំណែកក្នុងករណីសហគមន៍ចាមមូស្លីមវិញ គឺមានមេដឹកនាំវិហារឥស្លាមដែលជាអ្នកជួយសម្របសម្រួល (សូមមើលត្រង់ឧបសម្ព័ន្ធដែលមានរួមបញ្ចូលសេចក្តីសង្ខេបនៃការពិគ្រោះយោបល់ជាមួយប្រធានសហគមន៍ចាម ដែលបានធ្វើឡើងដោយទីប្រឹក្សាទទួលបន្ទុកផ្នែកការពារសង្គម TRTA ដែលបានធ្វើឡើងនៅដើមខែធ្នូ ឆ្នាំ២០២១។ របនាសម្ព័ន្ធជនជាតិដើមភាគតិចទាំងនេះ នឹងត្រូវបានទាញយកដោយគម្រោងសម្រាប់ការដោះស្រាយបណ្តឹងតវ៉ា។

៥៥. ដំណើរការដោះស្រាយបណ្តឹងតវ៉ា រួមមាន ៥ ដំណាក់កាល ដូចខាងក្រោម៖

(១). **ដំណាក់កាលទីមួយ៖** ការតវ៉ា និងបណ្តឹងនឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរទៅប្រធានភូមិ និងព្រឹទ្ធាចារ្យក្នុងភូមិ។ ប្រសិនបើមិនអាចដោះស្រាយបញ្ហាបានក្រោយមានការពិភាក្សាដែលបានកំណត់នៅថ្នាក់ភូមិ ក្នុងរយៈពេល ១០ ថ្ងៃ ទេនោះ បណ្តឹងនោះនឹងក្លាយជាបណ្តឹងផ្លូវការ។ ប្រសិនបើមានបណ្តឹងធ្វើឡើងដោយដើមបណ្តឹងជាស្ត្រី ក្រុមតំណាងរបស់ចាស់ព្រឹទ្ធាចារ្យត្រូវមានស្ត្រីផ្សេងទៀត។

(២). **ដំណាក់កាលទីពីរ៖** "បណ្តឹងជាលាយល័ក្ខអក្សរនេះ នឹងត្រូវរៀបចំឡើងដោយប្រធានភូមិ រួចបញ្ជូនទៅមេឃុំ។ ភ្នាក់ងារទទួលបណ្តឹងនេះ នឹងផ្តល់ការបញ្ជាក់ភ្លាមៗជាលាយលក្ខ័អក្សរថាបានទទួលពាក្យបណ្តឹងនេះ។ ប្រសិនបើ ក្រោយរយៈពេល ១៥ថ្ងៃហើយ ដើមបណ្តឹងនេះមិនបានទទួលដំណឹងអ្វីសោះពីមេភូមិ និងមេឃុំ ឬបុគ្គលិកអង្គភាពអនុវត្តគម្រោងឬ ប្រសិនបើគាត់មិនពេញចិត្តនឹងការសម្រេចចិត្តដែលធ្វើឡើងក្នុងដំណាក់កាលដំបូងទេ នោះគាត់អាចប្តឹងបន្តទៅការិយាល័យស្រុក។

(៣). **ដំណាក់កាលទីបី៖** ការិយាល័យស្រុកមានរយៈពេល ១៥ សម្រាប់ដោះស្រាយពាក្យបណ្តឹងក្នុងលក្ខណៈដែលអាចទទួលយកបានដោយពេញចិត្តពីអ្នកពាក់ព័ន្ធទាំងអស់។ ប្រសិនបើមិនអាចដោះស្រាយបណ្តឹងនៅក្នុងដំណាក់កាលនេះទេ ការិយាល័យស្រុកនឹងបញ្ជូនសំណុំរឿងនេះទៅគណៈកម្មការដោះស្រាយបណ្តឹងថ្នាក់ខេត្ត (PGRC) ។

(៤). **ដំណាក់កាលទីបួន៖** គណៈកម្មការដោះស្រាយបណ្តឹងថ្នាក់ខេត្ត (PGRC) ត្រូវជួបជាមួយភាគីដែលមិនសុខចិត្ត និងព្យាយាមដោះស្រាយស្ថានភាពនេះ។ PGRC ត្រូវតែធានាថាមានការបកប្រែជាភាសាមូលដ្ឋានប្រសិនបើករណីនេះពាក់ព័ន្ធនឹងក្រុមជនជាតិដើមភាគតិច ឬជនជាតិភាគតិចដែលមិនយល់ដឹងពីភាសាខ្មែរគ្រប់គ្រាន់។ ក្នុងរយៈពេល ៣០ថ្ងៃនៃការដាក់ពាក្យបណ្តឹង គណៈកម្មការនេះ នឹងធ្វើការសម្រេចជាលាយល័ក្ខអក្សរ និងបញ្ជូនច្បាប់ចម្លងទៅកាន់ភ្នាក់ងារប្រតិបត្តិ រួមមានគណៈកម្មការអន្តរក្រសួងទទួលបន្ទុកដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅជាថ្មី ប្រសិនបើករណីនេះពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងភ្នាក់ងារអនុវត្ត។

(៥). **ដំណាក់កាលទីប្រាំ៖** ប្រសិនបើគ្រួសារដែលរងផលប៉ះពាល់ ហើយមិនសុខចិត្ត មិនបានទទួលដំណឹងអ្វីសោះពីគណៈកម្មការដោះស្រាយបណ្តឹងថ្នាក់ខេត្ត (PGRC) ឬគណៈកម្មការអន្តរក្រសួងទទួលបន្ទុកដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅ ឬប្រសិនបើពួកគាត់មិនពេញចិត្ត ពួកគាត់អាចប្តឹងទៅអយ្យការអមសាលាដំបូងខេត្ត (តុលាការខេត្ត)។ ពេលនោះ តុលាការនឹងធ្វើការសម្រេចជាលាយល័ក្ខអក្សរ (ចេញដីកា) និងបញ្ជូនច្បាប់ចម្លងទៅកាន់ភ្នាក់ងារប្រតិបត្តិ និងភ្នាក់ងារអនុវត្ត។ ប្រសិនបើមានភាគីណាមួយមិនពេញចិត្តនឹងសាលក្រមរបស់តុលាការខេត្ត ពួកគាត់អាចយកសំណុំរឿងនេះប្តឹងបន្តទៅតុលាការថ្នាក់ខ្ពស់ជាងនេះមួយទៀត (ឬសាលាឧទ្ធរណ៍)។

៥៦. គួរបញ្ជាក់ផងដែរថា យ៉ាងហោចណាស់ក្នុងចំណោមជនជាតិចាមឥស្លាម មានអ្នកខ្លះបានបញ្ជាក់ថាប្រសើនបើមានបញ្ហាណាមួយ ពួកគាត់មានបំណងចង់ដោះស្រាយបញ្ហានោះនៅថ្នាក់ភូមិ ឬកម្រិតមូលដ្ឋាន ប៉ុន្តែរាល់បញ្ហាទាំងអស់ដែលបានកើតឡើងទាក់ទងនឹងគម្រោងនេះ មិនមែនសុទ្ធតែអាចដោះស្រាយបាននៅត្រឹមភូមិ ឬកម្រិតមូលដ្ឋាននោះទេ។ ចំណុចនេះធ្វើឲ្យអ្នកភូមិមួយចំនួនព្រួយបារម្ភ ដោយសារពួកគាត់មិនសូវមានទំនុកចិត្តទៅលើប្រព័ន្ធរដ្ឋបាលគ្រប់គ្រង និងប្រព័ន្ធតុលាការ ឬច្បាប់។

៥៧. រាល់ការចំណាយក្នុងការដោះស្រាយបណ្តឹង (កិច្ចប្រជុំ ការពិគ្រោះយោបល់ ការទំនាក់ទំនង និងការរាយការណ៍ ឬផ្សព្វផ្សាយព័ត៌មាន) គឺជាបន្ទុកទទួលខុសត្រូវរបស់គម្រោង។

៥៨. របាយការណ៍ការត្រួតពិនិត្យផ្នែកកិច្ចគាំពារ នឹងត្រូវរួមបញ្ចូលទាំងទិដ្ឋភាពដូចខាងក្រោម ទាក់ទងនឹងស្ថានភាពនៃបណ្តឹង៖ (១). ចំនួនបណ្តឹង និងប្រភេទនៃសំណុំរឿង ដែលបានកត់ត្រាក្នុងបញ្ជីរបស់គណៈកម្មការដោះស្រាយបណ្តឹង (កម្រិតនៃយុត្តាធិការថ្នាក់ទី១ ទី២ ទី៣ ទី៤ និងទី ៥) ចំនួនសវនាការដែលបានធ្វើ ដីចំនួនដីកាសម្រេចដែលបានចេញ និងចំនួនសំណុំរឿងមិនចាត់ការ និង (២). បញ្ជីសំណុំរឿងកំពុងដំណើរការជម្រះ និង

សំណុំរឿងដែលបានសម្រេចរួច អាចនឹងត្រូវរៀបចំដោយមានព័ត៌មានលម្អិត ដូចជាឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ កាលបរិច្ឆេទជូនដំណឹង កាលបរិច្ឆេទដាក់ពាក្យបណ្តឹង កាលបរិច្ឆេទសវនាការ ដីកាសម្រេច កំណត់សម្គាល់ចំណាត់ការដើម្បីដោះស្រាយបញ្ហា និងស្ថានភាពនៃបណ្តឹង (បើកការជំនុំជម្រះ បិតការជំនុំជម្រះ ទុកសំណុំរឿងមិនចាត់ការ)។ ដំណោះស្រាយនៃបណ្តឹងតវ៉ាដែលបានកត់ត្រាចូលក្នុងបញ្ជី ក៏គួរតែត្រូវបានចងក្រងទុកជាឯកសារ និងរាយការណ៍ផងដែរ។

៥៩. ប្រសិនបើកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយវិវាទ តាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ានេះ នៅតែមិនអាចដោះស្រាយបាន ឬនៅតែមិនពេញចិត្ត គ្រួសារដែលរងផលប៉ះពាល់មានសិទ្ធិពិភាក្សាដោយផ្ទាល់អំពីកង្វល់ ឬបញ្ហារបស់ពួកគេជាមួយអ្នកជំនាញផ្នែកបរិស្ថាន ធនធានធម្មជាតិ និងកសិកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំតំបន់អាស៊ីអាគ្នេយ៍ តាមរយៈនិវាសនដ្ឋានបេសកកម្មប្រចាំនៅប្រទេសកម្ពុជា។ ប្រសិនបើគ្រួសារនោះនៅតែមិនពេញចិត្តនឹងការឆ្លើយតបរបស់ ADB ប្រចាំនៅកម្ពុជា ពួកគាត់អាចទាក់ទងដោយផ្ទាល់ទៅការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីជួបពិភាក្សាផ្ទាល់ជាមួយអ្នកសម្របសម្រួលគម្រោងពិសេស។ ការិយាល័យនៃអ្នកសម្របសម្រួលគម្រោងពិសេសអាចអនុវត្តនីតិវិធីរបស់ខ្លួនបាន ដោយផ្អែកលើយន្តការគណនេយ្យភាពក្នុងលក្ខណៈស្របគ្នាជាមួយនឹងការអនុវត្តគម្រោងនេះ។

## VI. ការរៀបចំស្ថាប័នរបស់គម្រោង CLHVCIP

### ក. ថ្នាក់ជាតិ

៦០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) គឺជាស្ថាប័នតំណាងផ្លូវការរបស់រាជរដ្ឋាភិបាលដែលជាអ្នកខ្ចី និងជាអ្នកទទួលមូលនិធិ។ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវ៖ (១). បំពេញតួនាទីក្នុងការខ្ចីក្នុងនាមរាជរដ្ឋាភិបាល និងត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញវត្ថុ, (២). ផ្តល់ការចូលរួមចំណែកក្នុងនាមជាសមភាគីឱ្យបានគ្រប់គ្រាន់សម្រាប់សកម្មភាពគម្រោងឱ្យបានទាន់ពេលវេលា និង, (៣). ធានាថាគ្មានការពន្យារពេលក្នុងការធ្វើលទ្ធកម្មគម្រោង។ ការទម្លាក់ថវិកា គឺជាទំនួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយភ្នាក់ងារប្រតិបត្តិគម្រោង។

៦១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាភ្នាក់ងារប្រតិបត្តិគម្រោង ហើយទទួលខុសត្រូវលើការងារគ្រប់គ្រងរួម ការសម្របសម្រួល និងការធ្វើរបាយការណ៍របស់គម្រោង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងត្រូវបង្កើតអង្គភាពគ្រប់គ្រងគម្រោង (PMU) ដែលធ្លាប់បានស្នើឡើងថា អង្គភាពគ្រប់គ្រងគម្រោងនេះអាចជាអង្គភាពគ្រប់គ្រងគម្រោងរបស់គម្រោងសម្របសម្រួលពាណិជ្ជកម្មនៃមហាអនុតំបន់មេគង្គ SPS GMS ដែលមានស្រាប់ ដោយប្រើប្រាស់បុគ្គលិក និងធនធានដែលមានស្រាប់ ប៉ុន្តែត្រូវជ្រើសរើសបុគ្គលិកបន្ថែមទៀតចំពោះមុខតំណែងសំខាន់ៗ ដូចជាមន្ត្រីមួយចំនួនដែលនឹងត្រូវទទួលខុសត្រូវលើការងារត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធកម្ម កិច្ចគាំពារ និងការងារគណនេយ្យ។

៦២. អង្គភាពគ្រប់គ្រងគម្រោង (PMU) ត្រូវទំនួលខុសត្រូវលើការងារគ្រប់គ្រង ការសម្របសម្រួល និងការត្រួតពិនិត្យការអនុវត្តគម្រោងប្រចាំថ្ងៃ ព្រមទាំងការជ្រើសរើសទីប្រឹក្សាទទួលបន្ទុកការងារផ្តល់ហិរញ្ញវត្ថុ និងទម្លាក់ថវិកា និងត្រួតពិនិត្យលើបញ្ហានានា និងវិធានការក្នុងការការពារ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងទម្លាក់ថវិកាទៅគណនីរបស់អង្គភាពគ្រប់គ្រងគម្រោងសម្រាប់ចំណាយប្រចាំថ្ងៃ ហើយអង្គភាពគ្រប់គ្រងគម្រោងនេះ នឹងត្រូវផ្ទេរថវិកាចូលក្នុងគណនីរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរៀងៗខ្លួន។ បន្ទាប់មក ក្រសួងសាម៉ីនីមួយៗ នឹងទម្លាប់ថវិកាបន្តទៅគណនីរបស់មន្ទីរពាក់ព័ន្ធសម្រាប់ចំណាយលើការអនុវត្តគម្រោង។ អង្គភាពគ្រប់គ្រងគម្រោង (PMU) ក៏នឹងទទួលខុសត្រូវផងដែរក្នុងការដាក់បញ្ជូនរបាយការណ៍ត្រួតពិនិត្យសុវត្ថិភាពសង្គមប្រចាំឆមាស ទៅកាន់ ADB ក៏ដូចជាលើការអនុវត្ត និងការគ្រប់គ្រងយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង។ ការរៀបចំរបាយការណ៍ ការអនុវត្ត និងការគ្រប់គ្រងយន្តការ GRM នឹងត្រូវបានគាំទ្រដោយភ្នាក់ងារអនុវត្តគម្រោង និងទីប្រឹក្សាគម្រោង។

៦៣. ការសម្របសម្រួលថ្នាក់ជាតិ នឹងត្រូវរៀបចំឱ្យមានផងដែរ តាមរយៈគណៈកម្មការត្រួតពិនិត្យគម្រោងមួយដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន និងជាភ្នាក់ងារប្រតិបត្តិគម្រោង (EA) និងមានអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) ជាភ្នាក់ងារអនុវត្តគម្រោង (IA) និងគណៈកម្មការអចិន្ត្រៃយ៍គម្រោង ដែលមានសមាសភាពតំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ តំណាងថ្នាក់ខេត្ត នឹងត្រូវអញ្ជើញទៅប្រជុំគណៈកម្មការអចិន្ត្រៃយ៍ ដើម្បីពិភាក្សាពីបញ្ហាពាក់ព័ន្ធនឹងខេត្តដែលចូលរួម។ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានឆាប់ គម្រោងត្រូវបានណែនាំថាសមាសភាពសមាជិកគណៈកម្មការនេះ គួរតែជាមន្ត្រីដែលមានឋានៈត្រឹមអនុរដ្ឋលេខាធិការ ឬខ្ពស់ជាងនេះ។ គណៈកម្មការអចិន្ត្រៃយ៍ អាចអញ្ជើញសមាជិកទាំងនេះ និងភ្នាក់ងារគម្រោងដើម្បីពិភាក្សាអំពីរបៀបវារៈជាក់លាក់តាមការចាំបាច់។ សម្រាប់ការសម្រេចចិត្តដែលមានប្រសិទ្ធិភាព ត្រូវធ្វើឡើងដោយ មនុស្សមិនលើសពី ២០ នាក់ ដែលត្រូវចូលរួមនៅក្នុងកិច្ចប្រជុំនោះ។

៦៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែងតាំងជនបង្គោលដែលមានតួនាទីសម្របសម្រួលនៅថ្នាក់កណ្តាល។

៦៥. គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន នឹងត្រូវបានបង្កើតឡើង ហើយដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានតំណាងមិនលើសពី ១០រូប ដើម្បីពិនិត្យលើគម្រោងកសិពាណិជ្ជកម្មក្នុងក្របខ័ណ្ឌភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជនសំខាន់ៗ និងត្រូវជួបប្រជុំរៀងរាល់ពីរខែម្តង។ វិស័យឯកជនដែលធ្វើការទាក់ទងនឹងខ្សែច្រវាក់តម្លៃ នឹងរួមចំណែកជាធាតុចូលរបស់ខ្លួន តាមរយៈវេទិកាអាជីវកម្ម សហព័ន្ធ និងសមាគមដែលអាចផ្តល់ជាមតិត្រឡប់ និងព័ត៌មានផ្សេងៗដល់គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន ដែលបានស្នើឡើង និងដល់គណៈកម្មការប្រតិបត្តិ។ វេទិកា សហព័ន្ធ និងសមាគម អាចជួយគណៈកម្មាធិការអន្តរក្រសួងបញ្ចៀសនូវគំនិតផ្តួចផ្តើមណាដែលមិនមែនជាក្របខ័ណ្ឌភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន។

៦៦.  សកម្មភាពគោលនយោបាយកសិពាណិជ្ជកម្មដែលមានលក្ខណៈវៃឆ្លាតទៅនឹងអាកាសធាតុ នឹងត្រូវដឹកនាំ អនុវត្តដោយក្រុមការងារដែលមានតំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងបរិស្ថាន។

៦៧. ទីប្រឹក្សាអនុវត្តគម្រោង និងអ្នកជំនាញផ្នែកបច្ចេកទេសផ្សេងទៀត ព្រមទាំងអ្នកផ្តល់សេវា រួមទាំងបុគ្គលិក រដ្ឋាភិបាលដែលជាអ្នកមានជំនាញបទពិសោធន៍ នឹងអនុវត្តសកម្មភាពកសាងសមត្ថភាព និងសកម្មភាព បណ្តុះបណ្តាលជាច្រើន ព្រមទាំងការបង្ហាញសាកល្បង និងការរៀបចំប្លង់វិស្វកម្មលម្អិត។

## ខ.  ការរៀបចំការអនុវត្តផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP)

៦៨.  នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ មានអាណត្តិជាតិទទួលបន្ទុកផ្នែកអភិវឌ្ឍ ន៍ជនជាតិដើមភាគតិចនៅកម្ពុជា (សរុបមានចំនួន ២៤ ក្រុម ដែលបានទទួលស្គាល់ថាជាក្រុមជនជាតិដើមភាគតិច ស្របច្បាប់ ប៉ុន្តែមិនមែនជនជាតិភាគតិចទេដែលត្រូវរាប់បញ្ចូលចាម ថៃ ឡាវ និងចិន ទោះបីជាកើតក្នុងប្រទេសកម្ពុ ជា ពួកគេត្រូវបានចាត់ថ្នាក់ជាជនជាតិខ្មែរ រួមជាមួយនឹងជនជាតិភាគតិចខ្មែរក៏ដោយ)។ តួនាទីរបស់នាយកដ្ឋាន ភាគច្រើនផ្តោតលើការអភិរក្សវប្បធម៌ និងប្រពៃណី ប៉ុន្តែមិនពាក់ព័ន្ធក្នុងការវាយតម្លៃផែនការអភិវឌ្ឍន៍ជនជាតិភាគ តិច (EMDP) ទោះបីជានាយកដ្ឋាននេះត្រូវបានភ្នាក់ងារមន្ទីររបស់ខេត្តស្នើសុំជំនួយលើការងារដោះស្រាយបញ្ហា របស់ជនជាតិដើមភាគតិចក៏ដោយ។ ទីប្រឹក្សាផ្នែកការពាររបស់អង្គភាពគ្រប់គ្រងគម្រោង នឹងទទួលខុសត្រូវលើការ រៀបចំ និងការធ្វើបច្ចុប្បន្នកម្ម EMDP ហើយផែនការទាំងនេះត្រូវដាក់ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីអនុម័ត។ PICs នឹងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់ភ្នាក់ងារ ទទួលបន្ទុកផ្នែកកិច្ចគាំពារនៅតាមបណ្តាខេត្ត។ ចំណែកភ្នាក់ងារប្រតិបត្តិ នឹងត្រូវទទួលខុសត្រូវលើការអនុវត្ត EDMP តាមរយៈភ្នាក់ងារថ្នាក់ខេត្តរបស់ខ្លួន។

## គ.  ថ្នាក់ខេត្ត

៦៩. ភ្នាក់ងារសំខាន់នៅថ្នាក់ខេត្ត គឺការិយាល័យសុខភាពសត្វ និងបសុព្យាបាលខេត្ត ហើយបុគ្គលិកភ្នាក់ងារខេត្ត នឹងជួយដល់ក្រុមអនុវត្តគម្រោង ដើម្បីៈ

(១).  ធ្វើការសិក្សាមសិទ្ធិលទ្ធភាពរបស់គម្រោង ការស្ទង់មតិផ្នែកសេដ្ឋកិច្ចសង្គម រួមទាំងទិន្នន័យដែល បែងចែកទៅតាមជនជាតិ និងភេទ ដើម្បីយល់ពីបញ្ហាអភិវឌ្ឍន៍របស់ជនជាតិដើមភាគតិចនៅមូលដ្ឋាន។

(២).  រៀបចំ និងចងក្រងជាឯកសារនៃការពិគ្រោះយោបល់ជាមួយសហគមន៍ និងក្រុមជនជាតិភាគតិច នៅមូលដ្ឋាន ដើម្បីកំណត់កិច្ចអន្តរាគមន៍សមស្រប។

(៣).  ជួយក្នុងការរៀបចំកិច្ចអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ឃើញពាក់ព័ន្ធទៅនឹង អនុគម្រោងទាំងមូល។

(៤). ដើរតួនាទីនាំមុខក្នុងការអនុវត្ត និងត្រួតពិនិត្យតាមដានផែនការ EMDP ឬវិធានការពង្រឹង។

### ឃ. ថ្នាក់ស្រុក

៧០. ទោះបីជាក្រុមការងារអនុវត្តគម្រោង គឺជាភ្នាក់ងារនៅថ្នាក់ខេត្តក៏ដោយ បុគ្គលិកថ្នាក់ស្រុកក៏ត្រូវចូលរួមបំពេញបន្ថែមលើក្រុមការងារថ្នាក់ខេត្ត ប្រសិនបើចាំបាច់ និងនៅពេលចាំបាច់ ហើយអាស្រ័យលើលក្ខខណ្ឌធនធាននៅមូលដ្ឋាន។ ក្រុមការងារអនុវត្តគម្រោង នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងមន្ត្រីរដ្ឋបាលភូមិ។ ថ្នាក់ភូមិ និងឃុំសង្កាត់ ដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចសម្របសម្រួលរវាងគម្រោង និងសហគមន៍ និងជួយក្នុងការធ្វើការស្ទង់មតិ ប្រមូលទិន្នន័យ និងរៀបចំការណាត់ជួបជាមួយក្រុមសហគមន៍ និងគ្រួសារតាមសហគមន៍ តាមការចាំបាច់។

### ង. ទីប្រឹក្សា

៧១. រាល់ការអនុវត្តគម្រោង នឹងត្រូវដឹកនាំដោយទីប្រឹក្សាមួយក្រុម ដែលមានអ្នកជំនាញការអន្តរជាតិម្នាក់ និងអ្នកជំនាញការជាតិម្នាក់ ទទួលបន្ទុកផ្នែកគាំពារសង្គម ដែលត្រូវបានចាត់តាំងឱ្យបំពេញទំនួលខុសត្រូវជាក់លាក់លើ LAR និងជនជាតិភាគតិច។ ការការពារផ្នែកបរិស្ថាន នឹងត្រូវបានអនុវត្តដោយអ្នកជំនាញម្នាក់បន្ថែមទៀត។ អ្នកជំនាញផ្នែកគាំពារសង្គម ទទួលខុសត្រូវលើការពិនិត្យពិច័យយ៉ាងត្រឹមត្រូវលើការអនុវត្តអនុគម្រោង និងការបែងចែកទៅតាមប្រភេទជនជាតិភាគតិច ស្របតាមលក្ខខណ្ឌតម្រូវនៃ SPS-ABD (ឆ្នាំ២០០៩)។ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបុគ្គលិករដ្ឋាភិបាល អ្នកជំនាញការទាំងនេះត្រូវទទួលខុសត្រូវលើការបង្កើតផែនការ EMDP ដែលតម្រូវឱ្យមានជាចាំបាច់ និងធ្វើការត្រួតពិនិត្យ និងធ្វើរបាយការណ៍ជាបន្តបន្ទាប់ស្តីពីការអនុវត្តផែនការ EMDP នេះ។ គម្រោងបានស្នើឱ្យជួលអ្នកជំនាញការអន្តរជាតិផ្នែកគាំពារសង្គម ដើម្បីបំពេញការងាររយៈពេល ៣ ខែក្នុងឆ្នាំនីមួយៗរបស់គម្រោង និងជួលទីប្រឹក្សាជាតិឱ្យបំពេញការងាររយៈពេល ៦ ខែក្នុងឆ្នាំនីមួយៗរបស់គម្រោង។ គម្រោងប៉ាន់ប្រមាណថា ការងារពាក់ព័ន្ធនឹងជនជាតិភាគតិច នឹងត្រូវការពេលវេលាតែ ៥% ប៉ុណ្ណោះនៃពេលវេលារបស់អ្នកជំនាញការទាំងនេះ។

## VII. ការរៀបចំការត្រួតពិនិត្យតាមដាន និងការរាយការណ៍

៧២. ចាំបាច់ត្រូវមានការត្រួតពិនិត្យតាមដានផ្ទៃក្នុង ដើម្បីធានាថាការរៀបចំ និងការធ្វើបច្ចុប្បន្នកម្មផែនការ EMDP គឺត្រូវបាន៖ (១). ធ្វើឡើងនៅក្នុងដំណើរការដែលមានការពិគ្រោះយោបល់ពេញលេញ, (២). លាតត្រដាងឱ្យបានសមស្របដល់សហគមន៍ជនជាតិភាគតិចដែលរងផលប៉ះពាល់, (៣). អនុវត្តតាមការគ្រោងទុក, (៤). ធ្វើបច្ចុប្បន្នកម្ម និងកែតម្រូវ តាមការចាំបាច់, និង (៥). រាយការណ៍ជាទៀងទាត់ទៅកាន់អង្គភាពគ្រប់គ្រងគម្រោង ភ្នាក់ងារប្រតិបត្តិគម្រោង និង ADB ។ ដោយសារតែ ក្រុមជនជាតិភាគតិចក្នុងតំបន់គម្រោងមានចំនួនតិច តួច ហើយផលប៉ះពាល់ក៏មានកម្រិតតាមការរំពឹងទុក ដូច្នេះគម្រោង CLHVCIP នឹងពឹងផ្អែកជារួមលើនីតិវិធី

ត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនជាមុន។ ភ្នាក់ងារប្រតិបត្តិ និងភ្នាក់ងារអនុវត្ត ក្រោមជំនួយពីអ្នកជំនាញផ្នែកគាំពារសង្គមជាតិ និងអន្តរជាតិ នឹងអនុវត្តការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានផ្ទៃក្នុងទាក់ទងនឹងការអនុវត្តផែនការ EMDP ។ អ្នកជំនាញផ្នែកគាំពារសង្គមជាតិ និងអន្តរជាតិ ត្រូវធានាថាការត្រួតពិនិត្យតាមដាន និងការរាយការណ៍ ពិតជាត្រូវបានអនុវត្តស្របតាម EGDF និង EMDP ។ ជំនួយផ្នែកបច្ចេកទេសរបស់គម្រោង នឹងផ្តល់ការបណ្តុះបណ្តាលផ្នែកគាំពារសង្គមដល់បុគ្គលិកមកពីភ្នាក់ងារពាក់ព័ន្ធដែលចូលរួមក្នុងការអនុវត្ត ហើយការបណ្តុះបណ្តាលនេះទៀតសោតនឹងផ្តោតលើរបៀបត្រួតពិនិត្យតាមដាន ប្រមូលទិន្នន័យ និងរាយការណ៍។

៧៣. គោលដៅជាក់លាក់សម្រាប់ជនជាតិភាគតិច មិនទាន់បានកំណត់ឃើញនោះទេក្នុងអំឡុងពេលរៀបចំគម្រោង និងអំឡុងពេលរៀបចំក្របខ័ណ្ឌត្រួតពិនិត្យតាមដាន ដោយសារតែគ្មានវិធីប៉ាន់ប្រមាណចំនួនពិតប្រាកដនៃជនជាតិភាគតិចដែលអាចពាក់ព័ន្ធនៅក្នុងអនុគម្រោង CLHVCIP ។ ទោះបីជាចំនួនពិតប្រាកដនៃជនជាតិភាគតិចត្រូវបានគេរំពឹងថានឹងមានតិចតួចក៏ដោយ ក៏អាចនឹងគ្មានជនជាតិភាគតិចដែលជាអ្នកទទួលផលពីអនុគម្រោងទាំងអស់នេះដែរ។

## ឥ. សូចនាករ

៧៤. យ៉ាងហោចណាស់ គម្រោង CLHVCIP ត្រូវតែរាយការណ៍អំពីចំនួន និងប្រភេទនៃអនុគម្រោងដែលមានអ្នកចូលរួមជាជនជាតិភាគតិច ទាំងចំនួន និងភេទនៃសមាជិក ឬក្រុមគ្រួសារជនជាតិភាគតិចដែលចូលរួម និងត្រួតពិនិត្យតាមដានលើការចូលរួមរបស់ជនជាតិភាគតិចនៅក្នុងសកម្មភាព និងការប្រជុំនានាដែលគាំទ្រដោយគម្រោង។ ទិន្នន័យគោលពាក់ព័ន្ធផ្សេងទៀតដែលទទួលបានការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) របស់អនុគម្រោង ក៏នឹងត្រូវដាក់បញ្ចូលផងដែរ តួយ៉ាងដូចជាប្រាក់ចំណូលដែលបានមកពីសកម្មភាពគាំទ្រដោយអនុគម្រោងជាដើម។

៧៥. ប្រភេទសូចនាករទាំងនេះ មានដូចជា៖

(១). តើសកម្មភាព EMDP ដែលបានអនុវត្ត ហើយគោលដៅដែលសម្រេចបានធៀបនឹងពេលវេលាដែលបានព្រមព្រៀង ដែរឬទេ?

(២). តើមានមូលនិធិគ្រប់គ្រាន់ដែលអាចប្រើបានសម្រាប់ការអនុវត្ត EMDP នេះដែរឬទេ?

(៣). តើបានបញ្ចប់ការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិភាគតិច ទៅតាមការគ្រោងទុក រួមមានកិច្ចប្រជុំនានា ការពិភាក្សាជាក្រុម និងសកម្មភាពសហគមន៍ ដែរឬទេ?

(៤). តើការពិគ្រោះយោបល់កន្លងមក ត្រូវបានរៀបចំឡើងរវាងគ្នានឹងគ្នាជាច់ដោយឡែក ដោយបានដាក់បញ្ចូលបញ្ហាយេនឌ័រ ដោយគ្មានការបង្ខិតបង្ខំ និងដោយសមស្របតាមលក្ខណៈវប្បធម៌ ដែរឬទេ?

(៥). តើមានការរៀបចំខិត្តប័ណ្ណព័ត៌មានសមរម្យអំពីគម្រោង និងបានចែកជូនដល់ក្រុមជនជាតិភាគតិច ឬគ្រួសារជនជាតិភាគតិចដែលទទួលរងផលប៉ះពាល់ ដែរឬទេ?

(៦). តើមានលក្ខណៈផ្លាស់ប្តូរណាមួយដែរឬទេ ទាក់ទងនឹងការកាន់កាប់ ការផលិត ការប្រើប្រាស់ ធនធាន និងការគ្រប់គ្រងសំណល់ ធៀបទៅនឹងស្ថានភាពមុនពេលមានគម្រោង?

(៧). តើមានលក្ខណៈផ្លាស់ប្តូណាមួយដែរឬទេ ទាក់ទងនឹងប្រាក់ចំណូលនិងចំណាយ ធៀបទៅនឹង ស្ថានភាពមុនពេលមានគម្រោង? ហើយតើមានការផ្លាស់ប្តូរអ្វីខ្លះ ប្រសិនបើមាន?

(៨). តើស្ថានភាពរបស់ជនជាតិភាគតិចមានភាពប្រសើរឡើងដោយសារគម្រោងដែរឬទេ ឬយ៉ាងហោច ណាស់ក៏ស្ថានភាពនោះនៅដូចដើម?

(៩). តើស្ត្រីជនជាតិភាគតិចបានទទួលផលប្រយោជន៍ដូចបុរសជនជាតិភាគតិច ដែរឬទេ? តើបុរស និងស្ត្រីជនជាតិភាគតិច ទទួលរងផលប៉ះពាល់អវិជ្ជមានស្មើៗគ្នាដែរឬទេ?

៧៦. **កម្មវិធីត្រួតពិនិត្យតាមដាន និងរាយការណ៍៖** ផែនការ EMDP នេះនឹងបង្កើតកម្មវិធីសម្រាប់ អនុវត្ត EMDP ដោយពិចារណាលើកម្មវិធីក្នុងការអនុវត្តគម្រោងនេះ និងផែនការពិគ្រោះយោបល់។ EMDP នេះក៏ នឹងបង្ហាញពីកម្មវិធីត្រួតពិនិត្យតាមដាន និងរាយការណ៍ ដែលត្រូវទាមទារពីបុគ្គលិករបស់ភ្នាក់ងារប្រតិបត្តិពាក់ព័ន្ធ ផងដែរ។ អ្នកជំនាញផ្នែកគាំពារសង្គមដែលជួយដល់ការអនុវត្ត ត្រូវធានាថាបុគ្គលិករបស់ភ្នាក់ងារប្រតិបត្តិនៅថ្នាក់ ខេត្តបានយល់ដឹងពី EMDP និងការទទួលខុសត្រូវរបស់ខ្លួនលើការងារត្រួតពិនិត្យតាមដាន និងរាយការណ៍។ នៅ ពេលកំពុងអនុវត្ត EMDP ត្រូវមានរបាយការណ៍ប្រចាំត្រីមាសមួយស្តីពីការការពារដែលត្រូវរៀបចំឡើងដោយមាន ជំនួយបច្ចេកទេសគម្រោង CLHVCIP សម្រាប់ឱ្យអង្គភាពគ្រប់គ្រងគម្រោងពិនិត្យ និងចម្លងជូនធនាគារអភិវឌ្ឍន៍ អាស៊ី។ សកម្មភាពផ្នែកគាំពារ និងវឌ្ឍនភាពក្នុងការអនុវត្ត នឹងត្រូវដាក់បញ្ចូលក្នុងរបាយការណ៍វឌ្ឍនភាពរបស់ គម្រោង ដែលត្រូវដាក់បញ្ជូនទៅធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។

៧៧. **ការវាយតម្លៃលើកចុងក្រោយ៖** ផែនការ EMDP នេះនឹងបង្ហាញពីដំណើរការមួយដែលត្រូវធ្វើការវាយតម្លៃ នៅដំណាក់កាលចុងក្រោយនៃគម្រោងផងដែរ។ ដំណើរការនេះ នឹងផ្តោតលើក្រុមបង្គោលជាបុរស និងស្ត្រីដាច់ ដោយឡែកពីគ្នា ដែលត្រូវសម្របសម្រួលជាភាសាមូលដ្ឋាន ប្រសិនបើចាំបាច់។ ក្រុមបង្គោលនេះ នឹងកំណត់ពីផល ប្រយោជន៍ដែលត្រូវទទួលបាន បូករួមទាំងបញ្ហា និងឧបសគ្គនានាដែលបានជួបប្រទះអំឡុងពេលអនុវត្តគម្រោង និងកំណត់ពីមធ្យោបាយដែលអាចប្រើប្រាស់បាន ដើម្បីកែលម្អការអនុវត្តគម្រោងឱ្យកាន់តែប្រសើរឡើង។ ការវាយ តម្លៃនេះ ក៏នឹងរាយការណ៍ផងដែរពីកម្រិតប្រាក់ចំណូលក្នុងគ្រួសារ និងជាពិសេសប្រាក់ចំណូលពីសកម្មភាពដែល កំពុងគាំទ្រដោយគម្រោងនេះ។ ការវាយតម្លៃចុងក្រោយនេះ ត្រូវបានធ្វើឡើងដោយក្រុមការងារផ្នែកគាំពារសង្គម របស់គម្រោង ហើយនឹងត្រូវរៀបចំសម្រាប់ធ្វើជាផ្នែកមួយនៃរបាយការណ៍បញ្ចប់គម្រោង។

## VIII. ថវិកា និងការផ្តល់ហិរញ្ញប្បទាន

៧៨. ផែនការ EMDP បង្ហាញពីការចំណាយដែលពាក់ព័ន្ធនីមួយៗ ដែលនឹងស្ថិតក្រោមការរៀបចំផែនការ និង គ្រោងថវិកាលម្អិតអំឡុងពេលអនុវត្តនៅកម្រិតគម្រោង និងអនុគម្រោង។ អង្គភាពគ្រប់គ្រងគម្រោង ត្រូវទទួលខុស

ត្រូវលើការផ្តល់ហិរញ្ញប្បទានចាំបាច់សម្រាប់សកម្មភាពទាំងអស់ទាក់ទងនឹងផែនការ EMDP ដែលរួមបញ្ចូលទាំងសកម្មភាពទាក់ទងនឹងការរៀបចំផែនការ EMDP នេះ (ឧ. ការវាយតម្លៃហេតុប៉ះពាល់សង្គម រួមទាំងការពិគ្រោះយោបល់ ការស្វែងមតិដែលតម្រូវឱ្យមាន) និងសកម្មភាព និងចំណាត់ការដែលជាតម្រូវការស្របតាម IPP។ ផែនការ EMDP នេះនឹងបញ្ជាក់ពីលក្ខខណ្ឌតម្រូវក្នុងការផ្តល់មូលនិធិសម្រាប់សកម្មភាពនីមួយៗក្នុងផែនការ ហើយលក្ខខណ្ឌតម្រូវទាំងនេះ មានភាពខុសៗគ្នាទៅតាមតម្រូវការនៃ EMDP របស់អនុគម្រោងនីមួយៗ។ ការប៉ាន់ស្មានលើការចំណាយដែលបានបញ្ជាក់ក្នុងផែនការ ត្រូវតែរៀបចំឱ្យបានលម្អិត ដោយភ្ជាប់ទៅនឹងសកម្មភាពជាក់លាក់។ ផែនការ EMDP នេះនឹងផ្តោតទៅលើការចំណាយទាក់ទងនឹងការធានាឱ្យមានការចូលរួម និងបរិយាប័ន្ន។

៧៩. ដូចបានពិពណ៌នាខាងលើ គម្រោង CLHVCIP មានថវិកាសម្រាប់ជួលអ្នកជំនាញផ្នែកគាំពារសង្គមជាតិ និងអន្តរជាតិផងដែរ។ ការពិនិត្យពិច័យរបស់អនុគម្រោងទៅលើជនជាតិភាគតិច ការរៀបចំផែនការ EMDP ការបណ្តុះបណ្តាលបុគ្គលិក និងការត្រួតពិនិត្យតាមដានការអនុវត្តផែនការ EMDP ភាគច្រើននឹងធ្វើឡើងដោយមានជំនួយបច្ចេកទេស។ តារាងខាងក្រោមបង្ហាញពីសកម្មភាពគន្លឹះមួយចំនួនដែលនឹងត្រូវចំណាយក្នុងការអនុវត្តផែនការ EMDP នីមួយៗ។ ចំនួនទឹកប្រាក់ចំណាយបណ្តោះអាសន្នគឺ ២៥,០០០ ដុល្លារអាម៉េរិក ដែលត្រូវបានផ្តល់សម្រាប់សកម្មភាព និងការអនុវត្តផែនការ EMDP ក្រោមក្របខ័ណ្ឌគម្រោង CLHVCIP (ដោយមិនរួមបញ្ចូលទាំងការចំណាយលើការជួលទីប្រឹក្សា)។

**តារាងទី 5. ខ្ទង់ចំណាយសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ជនជាតិភាគតិច**

| សកម្មភាព | បរិយាយ | រយៈពេល |
|---|---|---|
| ១. ការបណ្តុះបណ្តាលសម្រាប់ផ្នែកគាំពារទី ៣ ដល់ភ្នាក់ងារប្រតិបត្តិគម្រោង និងភ្នាក់ងារអនុវត្តគម្រោង | ការបណ្តុះបណ្តាលភ្នាក់ងារពាក់ព័ន្ធអំពីគោលបំណងនៃការគាំពារជនជាតិភាគតិច, តម្រូវការសម្រាប់ IPP និងដំណើរការរៀបចំផែនការ EMDP។ ការត្រួតពិនិត្យតាមដាន និងសូចនាករ។ | នៅពេលចាប់ផ្តើមគម្រោងភ្លាម និងមុនពេលការសិក្សាសមិទ្ធិលទ្ធភាពបន្ថែមនៃអនុគម្រោងដែលបានធ្វើឡើងម្តងគឺចំណាយសរុប ៣,០០០ ដុល្លារអាម៉េរិក។ |
| ២. ការវាយតម្លៃហេតុប៉ះពាល់សង្គម | នៅគ្រប់សហគមន៍ដែលមានជនជាតិភាគតិច។ ការបណ្តុះបណ្តាលបុគ្គលិកនៃភ្នាក់ងារគម្រោងស្តីពី SIA។ ការរៀបចំធ្វើ SIA និងការរៀបចំទិន្នន័យគោល។ | កំពុងបន្តធ្វើ ដោយសារអនុគម្រោងត្រូវបានកំណត់ ប៉ុន្តែត្រូវតែធ្វើនៅមុនពេលដែលអនុគម្រោងជាក់លាក់ត្រូវបានអនុវត្ត។ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងថ្លៃដឹកជញ្ជូនសម្រាប់បុគ្គលិកភ្នាក់ងារខេត្ត។ អនុញ្ញាតឱ្យចំណាយ ៥០០ ដុល្លារក្នុងមួយ EMDP ។ |
| ៣. ការរៀបចំ IPP | ការប្រើប្រាស់ទិន្នន័យត្រួតពិនិត្យអនុគម្រោង និងទិន្នន័យនៃការវាយតម្លៃហេតុប៉ះពាល់សង្គម។ | ត្រូវបានរៀបចំដោយជំនួយបច្ចេកទេស។ |

| សកម្មភាព | បរិយាយ | រយៈពេល |
|---|---|---|
| ៤. ការត្រួតពិនិត្យតាមដានលើការអនុវត្ត IPPs | ការត្រួតពិនិត្យប្រចាំត្រីមាស៖ PMU នឹងតម្រូវឱ្យធ្វើការត្រួតពិនិត្យប្រចាំត្រីមាសលើ IPP និងសកម្មភាពអនុវត្ត។<br>ការវាយតម្លៃលើកចុងក្រោយ៖ ការវាយតម្លៃលើកចុងក្រោយលើការអនុវត្ត IPP នឹងមានរយៈពេល ៣ ខែមុនពេលបញ្ចប់គម្រោង។ | បង្កើតឡើងក្នុងផ្នែកគ្រប់គ្រងការរៀបចំអនុវត្ត និងការរៀបចំលក្ខខណ្ឌយោងរបស់ទីប្រឹក្សាគម្រោង។ អង្គភាព PMU នឹងសម្រេចថាតើគួរតែជួលអង្គភាពត្រួតពិនិត្យតាមដានពីខាងក្រៅ (EMO) ឬយ៉ាងណា។ |
| ៥. ការរៀបចំសម្ភារៈព័ត៌មាន និងអប់រំផ្សព្វផ្សាយ | ការរៀបចំសម្ភារៈអំបរំផ្សព្វផ្សាយដែលបានបោះពុម្ព ដើម្បីពន្យល់ដល់ជនជាតិភាគតិច និងជាភាសាជនជាតិភាគតិច ប្រសិនបើចាំបាច់។ ការបកប្រែឯកសារ និងការបោះពុម្ពផ្សេងៗ។ | ការអនុវត្តជារបៀប Ad hoc – តាមការចាំបាច់។ ចំណាយដែលអនុញ្ញាតសរុប ១,០០០ ដុល្លារ ក្នុងមួយអណុគម្រោងដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និងជនជាតិភាគតិច។ |
| ៦. ការប្រជុំ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ | ការជួលអ្នកបកប្រែភាសាក្នុងមូលដ្ឋាន និងអ្នកសម្របសម្រួលជនជាតិភាគតិចក្នុងមូលដ្ឋាន ដើម្បីជួយសម្រួលដល់ការដឹកនាំកិច្ចប្រជុំ ការពិភាក្សាក្រុម ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មាន។ | ការអនុវត្តជារបៀប Ad hoc នៅពេលបានកំណត់អនុគម្រោងជាក់លាក់ តាមការចាំបាច់។ ចំណាយដែលអនុញ្ញាតសរុប ២០ ដុល្លារសម្រាប់មនុស្សម្នាក់ ក្នុងមួយថ្ងៃ។ |
| ៧. ការជួលទីប្រឹក្សាជាតិសម្រាប់ផ្នែកគាំពារទី ៣ | នឹងត្រូវបានរួមបញ្ចូលជាមួយផ្នែកគាំពារទី ២ (RS/LA)។ | ថវិកាចំណាយសម្រាប់ជួលទីប្រឹក្សាជាតិ រយៈពេល ៣០ ខែ (៦ ខែ ក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៥ ឆ្នាំ)។ ៥% នៃពេលវេលាធ្វើការពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ឬជនជាតិភាគតិច។ |
| ៨.ការជួលទីប្រឹក្សាអន្តរជាតិផ្នែកគាំពារទី ៣ | នឹងត្រូវបានរួមបញ្ចូលជាមួយផ្នែកគាំពារទី ២ (RS/LA)។ | ថវិកាចំណាយ សម្រាប់ជួលទីប្រឹក្សាអន្តរជាតិ រយៈពេល ១៥ ខែ (៣ ខែ ក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៥ ឆ្នាំ) ។ ៥% នៃពេលវេលាធ្វើការពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ឬជនជាតិភាគតិច។ |
| 9. ការត្រៀមបម្រុងទុក | ដើម្បីទុកដោះស្រាយចំពោះផលប៉ះពាល់ដែលមិនអាចប៉ាន់ស្មានបានជាមុន និងការផ្លាស់ប្តូរផ្សេងទៀតដែលបានកំណត់។ | បញ្ចូលចំណាយបន្ថែមលើ EMDP ផ្ទាល់ចំនួន ១០%ទៀត។ |

CLHVCIP=គម្រោងសុខភាពសត្វឆ្លងកាត់ព្រំដែន នៃមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញខ្សែច្រវាក់តម្លៃសត្វ, EMO = អង្គភាពត្រួតពិនិត្យតាមដានខាងក្រៅ, EMDP = ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច, SIA = ការវាយតម្លៃហេតុប៉ះពាល់សង្គម, PMU = អង្គភាពគ្រប់គ្រងគម្រោង។

# ឧបសម្ព័ន្ធ 1. បញ្ជីត្រួតពិនិត្យជនជាតិភាគតិច

ក. បញ្ជីត្រួតពិនិត្យផលប៉ះពាល់លើជនជាតិដើមភាគតិច និងជនជាតិភាគតិច សម្រាប់អនុគម្រោង

| កង្វល់សំខាន់ៗ | បាទ/ចាស៎ | ទេ | អត់ដឹង | កំណត់សម្គាល់ |
|---|---|---|---|---|
| **ក. ការកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច** | | | | |
| ១. តើមានក្រុមសង្គម-វប្បធម៌ដែលមានវត្តមាន នៅក្នុង ឬប្រើប្រាស់តំបន់គម្រោង ដែលអាច ចាត់ទុកថាជា "កុលសម្ព័ន្ធ" (កុលសម្ព័ន្ធភ្នំ កុលសម្ព័ន្ធតាមរដូវកាល ក្រុមជនជាតិកុលសម្ព័ន្ធ) "ជនជាតិភាគតិច" (ជនជាតិដើមភាគតិច ឬជនជាតិភាគតិច) ឬ "សហគមន៍ជនជាតិដើមភាគតិច" នៅក្នុងតំបន់គម្រោងដែរឬទេ? | | | | |
| ២. តើមានច្បាប់ ឬគោលនយោបាយជាតិ ឬក្នុងស្រុក ក៏ដូចជាការសិក្សាស្រាវជ្រាវ ឬការសិក្សាផ្នែកនរវិទ្យា ដែលចាត់ទុកក្រុមទាំងនេះ ថាមានវត្តមាននៅក្នុង ឬកំពុងប្រើប្រាស់ តំបន់ គម្រោងធ្វើជាកម្មសិទ្ធិរបស់ "ជនជាតិភាគ តិច" ឬកុលសម្ព័ន្ធតាមរដូវកាល ឬជនជាតិកុលសម្ព័ន្ធ ជនជាតិភាគតិច ឬសហគមន៍វប្បធម៌ដែរឬទេ? | | | | |
| ៣. តើក្រុមបែបនេះ បានកំណត់អត្តសញ្ញាណ ខ្លួនឯងថាជាផ្នែកមួយនៃក្រុមសង្គម និងវប្បធម៌ ខុសប្លែកពីគេដែរឬទេ? | | | | |
| ៤. តើក្រុមទាំងនេះរក្សាការភ្ជាប់សមូហភាពទៅនឹងទីជម្រក ឬទឹកដីដូនតា និង/ឬធនធាន ធម្មជាតិនៅក្នុងទីជម្រក និងទឹកដីទាំងនេះដែរឬទេ? | | | | |
| ៥. តើក្រុមទាំងនេះរក្សានូវលក្ខណៈ វប្បធម៌ សេដ្ឋកិច្ច សង្គម និងនយោបាយខុសប្លែកពីសង្គម និងវប្បធម៌ជាទូទៅក្នុងប្រទេសដែរឬ? | | | | |
| ៦. តើក្រុមទាំងនេះនិយាយភាសាខុសប្លែកគ្នា ឬគ្រាមភាសាដែរឬទេ? | | | | |
| ៧. តើក្រុមទាំងនោះមានប្រវត្តិសាស្ត្រ សង្គម និងសេដ្ឋកិច្ច ដែលមានលក្ខណៈ ខ្វែងគំនិតគ្នា ដកហូតសិទ្ធិ | | | | |

| កង្វល់សំខាន់ៗ | បាទ/ចាស់ | ទេ | អត់ដឹង | កំណត់សម្គាល់ |
| --- | --- | --- | --- | --- |
| អំណាច មិនរាប់បញ្ចូល និង/ឬមាន លក្ខណៈរើសអើង ដែរឬទេ ? | | | | |
| ៨. តើក្រុមទាំងនោះ ត្រូវបានតំណាងថាជា "ជនជាតិដើមភាគតិច" ឬជា "ជនជាតិភាគតិច" ឬ "កុលសម្ព័ន្ធតាមរដូវកាល" ឬ "ជនជាតិកុលសម្ព័ន្ធ" នៅក្នុងស្ថាប័នដែលមានសិទ្ធិធ្វើសេចក្តីសម្រេចជាផ្លូវការណាមួយ នៅថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋានដែរឬទេ ? | | | | |
| **ខ. ការកំណត់អត្តសញ្ញាណផលប៉ះពាល់ ដែលអាចកើតមាន** | | | | |
| ៩. តើគម្រោងនេះនឹងផ្តល់ផលប្រយោជន៍ ដោយផ្ទាល់ ឬដោយប្រយោល ឬកំណត់គោលដៅចំពោះជនជាតិដើមភាគតិចដែរឬទេ ? | | | | |
| ១០. តើគម្រោងនេះនឹងប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ការអនុវត្តសង្គម-វប្បធម៌ និងជំនឿរបស់ជនជាតិដើមភាគតិចដែរឬទេ ? (ឧ. ការចិញ្ចឹមបីបាច់កូន សុខភាព ការអប់រំ សិល្បៈ និងអភិបាលកិច្ច) | | | | |
| ១១. តើគម្រោងនេះ នឹងប៉ះពាល់ដល់ មធ្យោបាយចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគ តិចដែរឬទេ ? (ឧ. ប្រព័ន្ធផលិតកម្មស្បៀង ការគ្រប់គ្រងធនធានធម្មជាតិ សិប្បកម្ម ពាណិជ្ជកម្ម ស្ថានភាពការងារ) | | | | |
| ១២. តើគម្រោងនេះស្ថិតនៅក្នុងតំបន់ណាមួយ (ដី ឬទឹកដី) ដែលជនជាតិដើមភាគតិចកំពុងកាន់កាប់ជាកម្មសិទ្ធិ ឬកំពុងប្រើប្រាស់ និង/ឬអះអាងថាជាដែនដីដូនតារបស់ពួកគេដែរឬទ ? | | | | |
| **គ. ការកំណត់អត្តសញ្ញាណនៃតម្រូវការពិសេស** តើសកម្មភាពគម្រោង រួមមានៈ | | | | |
| ១៣. តើមានការអភិវឌ្ឍជាលក្ខណៈពាណិជ្ជកម្ម លើធនធាន វប្បធម៌ និងចំណេះដឹងរបស់ជនជាតិដើមភាគតិចដែរឬទេ ? | | | | |
| ១៤. តើមានការផ្លាស់ទីជារូបវន្តពីទឹកដីដែលធ្លាប់មានជាលក្ខណៈប្រពៃណី ឬជាទំនៀមទម្លាប់ដែរឬទេ ? | | | | |

| កង្វល់សំខាន់ៗ | បាទ/ចាស | ទេ | អត់ដឹង | កំណត់សម្គាល់ |
|---|---|---|---|---|
| ១៥. តើការអភិវឌ្ឍពាណិជ្ជកម្មនៃធនធានធម្មជាតិ (ដូចជា រ៉ែ អ៊ីដ្រូកាបូន ព្រៃឈើ ទឹក ការបរបាញ់ ឬកន្លែងនេសាទ) នៅក្នុងដីជាទំនៀមទម្លាប់ដែលកំពុងប្រើប្រាស់ ហើយដែលនឹងអាចប៉ះពាល់ដល់ការចិញ្ចឹមជីវិត ឬការប្រើប្រាស់ជាវប្បធម៌ ពិធីសាសនា ការគោរពដល់ព្រលឹងវិញ្ញាណ ដែលអាចកំណត់លើអត្តសញ្ញាណ និងសហគមន៍ជនជាតិដើមភាគតិចដែរឬទេ? | | | | |
| ១៦. តើមានការបង្កលក្ខណៈឱ្យមានការទទួលស្គាល់ស្របច្បាប់លើសិទ្ធិ ប្រើប្រាស់ដីធ្លី និងទឹកដី ដីដែលធ្លាប់មានជាលក្ខណៈប្រពៃណី ឬប្រើប្រាស់ជាលក្ខណៈទំនៀមទម្លាប់ កាន់កាប់ ឬទាមទារដោយជនជាតិភាគតិច ដែរឬទេ? | | | | |
| ១៧. តើមានការបែងចែកដីដែលធ្លាប់មានជាលក្ខណៈប្រពៃណី ឬធ្លាប់ប្រើប្រាស់ជាលក្ខណៈទំនៀមទម្លាប់ កាន់កាប់ ឬទាមទារដោយជនជាតិភាគតិច ដែរឬទេ? | | | | |

# ឧបសម្ព័ន្ធ 2. ទស្សនទាន និងវិធីសាស្ត្រក្នុងការវាយតម្លៃផលប៉ះពាល់សង្គម

## ក,　ការវាយតម្លៃហេតុប៉ះពាល់សង្គម

១.　ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) ជួយដល់ការលើកកម្ពស់ការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន តាមរយៈការជួយឱ្យសម្រេចបាននូវលទ្ធផលនៃការអភិវឌ្ឍប្រកបដោយសមភាព និងនិរន្តរភាព ក៏ដូចជារួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍។ លទ្ធផលនៃការអភិវឌ្ឍសង្គមអាចសម្រេចបាន តាមរយៈវិធីសាស្ត្រនៃ SIA ដែលមានដូចខាងក្រោម៖

(១).　លទ្ធភាពទទួលបានសេវា ធនធាន និងឱកាសកាន់តែច្រើនប្រកបដោយបរិយាប័ន្ន និងដោយសមភាព។

(២).　ការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់ក្រុមក្រីក្រ និងក្រុមបាត់បង់ឱកាសចូលរួមក្នុងជីវភាពសង្គមសេដ្ឋកិច្ច និងនយោបាយ។

(៣).　សុវត្ថិភាពដោះស្រាយហានិភ័យរ៉ាំរ៉ៃ និងហានិភ័យកើតឡើងភ្លាមៗ ជាពិសេសក្នុងចំណោមក្រុមក្រីក្រ និងក្រុមជួបការលំបាក។

២.　វិសាលភាព និងជម្រៅនៃការវិភាគសង្គម នឹងប្រែប្រួលអាស្រ័យលើវិស័យ ការយកចិត្តទុកដាក់ និងភាពស្មុគស្មាញនៃគម្រោង និងបរិបទសង្គមដែលត្រូវអនុវត្ត។ ទោះជាយ៉ាងណាក្តី ផ្នែកសំខាន់គឺការផ្តោតលើការវិភាគផ្នែកសង្គម ហើយនឹងត្រូវដាក់បញ្ចូលទំហំទិដ្ឋភាពសង្គមសំខាន់ៗ និងយុទ្ធសាស្ត្រ ដូចខាងក្រោម៖

(១).　ការចូលរួម

(២).　បញ្ហាយេនឌ័រ និងការអភិវឌ្ឍ

(៣).　កិច្ចគាំពារសង្គម និង

(៤).　ការគ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះផ្នែកសង្គមផ្សេងទៀត។

## ខ.　លទ្ធផលសំខាន់ៗនៃការវិភាគសង្គម

៣.　ការវិភាគសង្គម គឺជាផ្នែកសំខាន់មួយនៃដំណើរការរៀបចំគម្រោង និងគួរតែរួមចំណែកដល់ការវិភាគផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ការពិចារណាលើជម្រើសរៀបចំគម្រោងជំនួស និងការរៀបចំជាលើកចុងក្រោយ រួមមានការត្រួតពិនិត្យតាមដាន និងការវាយតម្លៃសូចនាករ។ លទ្ធផលសរុបនៃការវាយតម្លៃផ្នែកសង្គម នឹងផ្តល់លទ្ធផលចម្បងៗ ដូចខាងក្រោម៖

(១).　ប្រវត្តិស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ក្រុមប្រជាជនដែលពាក់ព័ន្ធ

(២).　សកម្មភាពសង្គម ឬផែនការកាត់បន្ថយ ឬវិធានការផ្សេងទៀតដែលបានដាក់បញ្ចូលក្នុងការរៀបចំគម្រោង និង

(៣).　គោលដៅ និងសូចនាករអភិវឌ្ឍសង្គម។

៤. ចំពោះគម្រោងភាគច្រើន ដំណើរការប្រមូលទិន្នន័យ នឹងរួមមានទាំងទិន្នន័យបឋម និងទិន្នន័យមានស្រាប់ និងការរួមបញ្ចូលគ្នារវាងវិធីសាស្ត្របែបគុណភាព និងបែបបរិមាណ។ វិធីសាស្ត្របែបគុណភាព គឺពាក់ព័ន្ធជាពិសេសទៅនឹងការវិភាគផ្នែកសង្គម ព្រោះវាអាចកំណត់ឃើញពីបញ្ហា និងចាប់យកអថេរដែលមិនអាចទទួលបានតាមរយៈការស្ទង់មតិ ជាពិសេសទាក់ទងទៅនឹងបរិយាប័ន្ន/អបរិយាប័ន្នសង្គម ការផ្តល់សិទ្ធិអំណាច/ការដកសិទ្ធិអំណាច និងសុវត្ថិភាព/អសុវត្ថិភាព។

## គ. វិធីសាស្ត្រប្រមូលទិន្នន័យ

៥. ក្នុងការអនុវត្ត SIA មានការណែនាំឱ្យប្រើវិធីសាស្ត្រសំខាន់ៗចំនួនពីរដើម្បីប្រមូលទិន្នន័យ គឺការប្រមូលទិន្នន័យបែបគុណភាព និងបែបបរិមាណ។ ទិន្នន័យទាំងអស់ដែលទទួលបាន គួរតែត្រូវបានបែងចែកទៅតាមភេទ និងជនជាតិ៖

(១). បទសម្ភាសន៍ផ្អែកលើកម្រងសំណួរអំពីកម្រិតគ្រួសារ៖ កម្រងសំណួរទាំងនេះនឹងមានជាសំណួរបិទ រួមជាមួយនឹងចម្លើយទៅនឹងសំណួរពហុជ្រើសរើស ឬការឆ្លើយតបផ្អែកលើការរាប់ចំនួនលេខ។

(២). ការប្រជុំក្រុមគោលដៅ (ឬប្រជុំជាក្រុម)៖ ការប្រជុំនេះតាមបែបជាការពិគ្រោះយោបល់ដោយប្រើសំណួរបើក (semi-structured consultation) ដើម្បីស្វែងយល់ពីឥរិយាបថ ការព្រួយបារម្ភ និងចំណង់ចំណូលចិត្តរបស់ប្រជាជន។ ជាមួយក្រុមតូចៗទាំងនេះ (ជាទូទៅអ្នកចូលរួមពី ១០-១៥ នាក់ បូករួមអ្នកសម្របសម្រួលម្នាក់ទៅពីរនាក់)។ ក្រុមគោលដៅនេះ ពិតជាមានប្រយោជន៍សម្រាប់ប្រមូលទស្សនៈយល់ឃើញរបស់សមាជិកសហគមន៍ ដែលអាចមានការស្ទាក់ស្ទើរមិនហ៊ាននិយាយនៅទីសាធារណៈ (ដូចជាស្ត្រី ជនជាតិដើមភាគតិច ជនពិការ ឬប្រជាជនក្រីក្រ និងគ្រួសារក្រីក្រ)។ ការប្រជុំក្រុមគោលដៅនេះ គឺនិយមប្រើក្រុមគោលដៅនៅតាមមូលដ្ឋាន ដោយមានបែងចែកទៅតាមភេទ និងជនជាតិ (ឧ. ការញែកឱ្យដាច់ដោយឡែកពីគ្នារវាងក្រុមបុរស និងក្រុមស្ត្រី)។

## ឃ. ទិន្នន័យមានស្រាប់

៦. ប្រភពទិន្នន័យមានស្រាប់ដែលអាចពាក់ព័ន្ធនៅក្នុងការរៀបចំប្រវត្តិស្ថានភាពសេដ្ឋកិច្ចសង្គម រួមមានដូចខាងក្រោម៖

(១). <u>ការជំរឿនប្រជាជន</u>៖ ជាធម្មតា ការធ្វើជំរឿនថ្នាក់ជាតិអាចផ្តល់នូវទិន្នន័យមូលដ្ឋានស្តីពីការងារ ទំហំគ្រួសារ លំនៅដ្ឋាន និងការទទួលបានសេវាមូលដ្ឋាន រួមមានទិន្នន័យដែលបែងចែកទៅតាមតំបន់ ឬរដ្ឋ ឬខេត្ត។

(២). <u>ការស្ទង់មតិលើកម្រិតជីវភាពរស់នៅ (LSMS) និងការស្ទង់មតិលើគ្រួសារដែលមានស្រាប់ដទៃទៀត</u>៖ LSMS និងការស្ទង់មតិលើប្រជានបទជាច្រើនផ្សេងទៀត អាចផ្តល់ទិន្នន័យអំពីចំណូល និងចំណាយក្នុងក្រសារ ការងារ សុខភាព ការអប់រំ កម្មសិទ្ធិដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត និងលទ្ធភាពទទួលបានសេវាមូលដ្ឋាន និងកម្មវិធីសង្គមនានា។

(៣). ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាព៖ ជាទូទៅ ការស្ទង់មតិទាំងនេះ អាចផ្តល់ទិន្នន័យអំពី -(ក). សុខភាព អត្រាមរណរបស់ទារក អត្រាកំណើត ការពន្យារកំណើត និងការធ្វើផែនការគ្រួសារ ការថែទាំផ្ទៃពោះមុនពេលសម្រាល ប្រភេទមន្ទីរព្យាបាល និងការថែទាំដែលប្រើប្រាស់ដោយស្ត្រីសម្រាប់ការសម្រាលកូន ការបំបៅកូន ការចាក់ថ្នាំបង្ការ ការប្រើប្រាស់មណ្ឌលសុខភាពដោយម្តាយ និងទារក ការពេញចិត្តជាមួយសេវាសុខភាព និងថ្លៃចំណាយលើការព្យាបាល -(ខ). លទ្ធភាពទទួលបានការអប់រំ -(គ). មុខរបររបស់បុរស និងស្ត្រី -(ឃ) ការធ្វើចំណាកស្រុក -(ង). ការទទួលបានសេវាទឹកស្អាត អនាម័យ និងថាមពល និង -(ច) កម្មសិទ្ធិប្រើប្រាស់មុខទំនិញដែលមានរយៈពេលយូរ។ ការស្ទង់មតិទាំងនេះ ត្រូវបានយកមកអនុវត្តដើម្បីគណនាទ្រព្យសម្បត្តិក្នុងគ្រួសារ និងជាពិសេសពាក់ព័ន្ធទៅនឹងការវិភាគផ្នែកយេនឌ័រ។

(៤). ការស្ទង់មតិអំពីការងារ៖ ការស្ទង់មតិនេះ អាចផ្តល់ទិន្នន័យអំពី (ក). ភាពមានការងារធ្វើ ភាពគ្មានការងារធ្វើ និងស្ថានភាពគ្មានការងារធ្វើ (ខ). ប្រាក់ឈ្នួល និងប្រាក់ចំណូលផ្សេងៗក្នុងគ្រួសារ (គ). ប្រជាសាស្ត្រ និង (ឃ). លក្ខណៈក្នុងការរស់នៅ។ ទោះជាយ៉ាងណាក្តី ការស្ទង់មតិនេះ គឺទំនងជាមិនបានផ្តល់ព័ត៌មានអំពីសហគ្រាសខ្នាតតូច និងសកម្មភាពអាជីវកម្មក្រៅផ្លូវការផ្សេងទៀត ឬកម្លាំងពលកម្មដែលមិនទទួលប្រាក់កម្រៃរបស់សមាជិកគ្រួសារ ទាក់ទងនឹងវិស័យកសិកម្ម ឬអាជីវកម្មលក្ខណៈគ្រួសារឡើយ។

## ខ. ប្រវត្តិរបស់អ្នកទទួលផលពីគម្រោង

៧. លទ្ធផលសំខាន់ៗបានពីការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) គឺជាការកត់ត្រាប្រវត្តិស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ក្រុមគោលដៅ ដែលជាធាតុចូលសំខាន់ក្នុងការរៀបចំគម្រោង និងផ្តល់ទិន្នន័យមូលដ្ឋានសម្រាប់ការត្រួតពិនិត្យតាមដានផលប៉ះពាល់សង្គមរបស់គម្រោងលើក្រុមពាក់ព័ន្ធ។ គោលបំណងនៃការកត់ត្រាប្រវត្តិទាំងនេះ គឺដើម្បី៖

(១). កំណត់ឱ្យឃើញក្រុមអតិថិជន/ក្រុមអ្នកទទួលផល និងប្រជាជនផ្សេងទៀតដែលអាចនឹងរងផលប៉ះពាល់ដោយសារគម្រោងនេះ។

(២). កំណត់ឱ្យឃើញក្រុមតូចៗដែលមានតម្រូវការ និងចំណាប់អារម្មណ៍ខុសៗគ្នា។

(៣). វាយតម្លៃពីតម្រូវការចាំបាច់ ការចង់បាន ឧបសគ្គ និងសមត្ថភាពរបស់ក្រុមទាំងនេះ និងក្រុមតូចៗទាក់ទងទៅនឹងគម្រោងដែលស្នើឡើង។

៨. ប្រវត្តិស្ថានភាពទាំងនេះ អាចធ្វើជាមូលដ្ឋានសម្រាប់ការវិភាគបន្ថែមទៅលើបញ្ហាសំខាន់ៗផ្នែកសង្គម (ឧ. ទាក់ទងទៅនឹងបញ្ហាយេនឌ័រ ជនជាតិដើមភាគតិច ការតាំងលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ការងារ លទ្ធភាព ឬហានិភ័យសុខភាព/ការជួញដូរ ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធគម្រោងធំៗ)។ ប្រវត្តិស្ថានភាពទាំងនេះ ក៏ជាជំនួយសម្រាប់ក្រុមរៀបចំគម្រោងក្នុងការកំណត់សមាសភាគគម្រោង ការជ្រើសរើសបច្ចេកទេស និងការរៀបចំការ

អនុវត្តដែលមានលក្ខណៈសមស្រប ដែលអាចធ្វើបាន ហើយដែលអាចឆ្លើយតបទៅនឹងតម្រូវការក្នុងមូលដ្ឋាន និងសមត្ថភាពតាមជាក់ស្តែង។

## ច. ខ្លឹមសារប្រវត្តិស្ថានភាពសេដ្ឋកិច្ចសង្គម

៩. ប្រវត្តិស្ថានភាពសេដ្ឋកិច្ចសង្គម គឺពឹងផ្អែកលើទិន្នន័យបឋម និងមានស្រាប់ ដែលទទួលបានតាមរយៈការសម្ភាសន៍តាមគ្រួសារនីមួយៗ ការពិភាក្សាជាក្រុម និងរបាយការណ៍ផ្សេងទៀតដែលបានពិនិត្យសម្រាប់ផ្តល់ជាទិន្នន័យមានស្រាប់ដែលពាក់ព័ន្ធ។ ទម្រង់នៃប្រវត្តិស្ថានភាពផ្នែកសេដ្ឋកិច្ចសង្គមចំពោះការដោះស្រាយបញ្ហាសង្គមក្នុងវិស័យកសិកម្ម និងអភិវឌ្ឍជនបទ ត្រូវបានបង្ហាញនៅខាងក្រោម។

១០. ទីតាំង និងលក្ខណៈរូបវន្តៈ

(១). ផែនទី (រួមមានផែនទីបង្ហាញផ្លូវធ្វើដំណើរ ការប្រើប្រាស់ដីធ្លី ទន្លេ ស្ពាន តំបន់តាំងទីលំនៅជាថ្មីសំខាន់ៗ) និង

(២). ការពិពណ៌នាអំពីទីតាំង

១១. កត្តាសេដ្ឋកិច្ច (រួមមានទិន្នន័យដែលបែងចែកទៅតាមភេទ ជនជាតិ និងកម្រិតប្រាក់ចំណូល)៖

(១). កម្មសិទ្ធិលើទ្រព្យសម្បត្តិ
(២). ដីធ្លី (ឧ. ចំនួន ប្រភេទ របាយ សិទ្ធិកាន់កាប់)
(៣). ផ្សេងៗទៀត (ឧ. សត្វចិញ្ចឹម ឧបករណ៍ សំណង់អគារ)
(៤). ប្រភេទជីវភាពរស់នៅ (ឧ. មុខរបរចិញ្ចឹមជីវិត ពាណិជ្ជកម្មអាជីវកម្ម ឬទាំងពីរ)
(៥). ប្រាក់ចំណូល និងប្រាក់ចំណាយក្នុងគ្រួសារ
(៦). ជំនាញ
(៧). ការងារ និងការបែងចែកកម្លាំងពលកម្ម
(៨). ការប្រើប្រាស់ និងការទទួលបានឥណទាន
(៩). ការប្រើប្រាស់ និងការទទួលបានសេវាទីផ្សារ
(១០). ការប្រើប្រាស់ និងការទទួលបានជាតុចូលផ្នែកពាណិជ្ជកម្ម។

១២. ហេដ្ឋារចនាសម្ព័ន្ធសង្គម (រួមមានការបែងចែកទិន្នន័យទៅតាមភេទ ជនជាតិ និងកម្រិតប្រាក់ចំណូល)៖

(១). ការទទួលបានសេវាសុខភាព
(២). ការអប់រំ (ថ្នាក់បឋមសិក្សា អនុវិទ្យាល័យ ការអប់រំក្រៅប្រព័ន្ធ)
(៣). ទឹក និងអនាម័យ
(៤). លំនៅឋាន
(៥). ផ្លូវថ្នល់ និងទំនាក់ទំនង

(៦). ថាមពល។

១៣. កត្តាប្រជាសាស្ត្រ (រួមមានការបែងចែកទិន្នន័យទៅតាមភេទ ជនជាតិ និងកម្រិតប្រាក់ចំណូល)៖

(១). អាយុ ភេទ ទំហំគ្រួសារ

(២). អត្រាកំណើត និងមរណៈ

(៣). សុខភាព និងអាហារូបត្ថម្ភ (របស់មនុស្សពេញវ័យ និងកុមារ)

(៤). ចំណាកស្រុក (ក្នុង និងក្រៅប្រទេស)

(៥). ចំនួនគ្រួសារដែលមានតែឪពុក ឬមានតែម្ដាយ។

១៤. រចនាសម្ព័ន្ធសង្គម (រួមមានភស្តុតាងនៃភាពខុសគ្នា ដោយផ្អែកទៅតាមភេទ ជនជាតិ ឬកម្រិតប្រាក់ចំណូល)៖

(១). រចនាសម្ព័ន្ធគ្រួសារ

(២). រចនាសម្ព័ន្ធសង្គមនៅក្នុងសហគមន៍

(៣). ព័ត៌មានអំពីរបៀបធ្វើការសម្រេចចិត្តជាសមូហភាព

(៤). រចនាសម្ព័ន្ធអង្គការចាត់តាំងក្នុងមូលដ្ឋាន

(៥). អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសហគមន៍មូលដ្ឋាន

(៦). កម្រិតនៃសិទ្ធិពលសង្គម ការគោរពក្នុងសង្គម និងគំនិតផ្ដួចផ្ដើម

## ឧបសម្ព័ន្ធទី 3. ទម្រង់ផែនការអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច (IPDP)

១. ទម្រង់នេះ គឺជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវទី ៣ នៃគោលការណ៍ការពារ។ ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) គឺតម្រូវឱ្យមានជាចាំបាច់សម្រាប់គម្រោងទាំងអស់ដែលមានផលប៉ះពាល់លើជនជាតិដើមភាគតិច។ កម្រិតនៃស្ថានភាពលម្អិត និងគ្រប់ជ្រុងជ្រោយ គឺមានលក្ខណៈស្របគ្នាទៅនឹងសារៈសំខាន់នៃផលប៉ះពាល់ចម្បងៗមកលើជនជាតិដើមភាគតិច។ ទិដ្ឋភាពចម្បងៗនៃទម្រង់នេះ នឹងផ្តល់ជាការណែនាំសម្រាប់រៀបចំផែនការ IPDP ទោះបើជាមិនចាំបាច់បង្ហាញទៅតាមលំដាប់ក៏ដោយ។

### ក. សេចក្តីសង្ខេប

២. ផ្នែកនេះនឹងពិពណ៌នាអំពីជាតុពិតសំខាន់ៗ លទ្ធផលរកឃើញសំខាន់ៗ និងសកម្មភាពដែលបានណែនាំឱ្យអនុវត្ត។

### ខ. ការពិពណ៌នាគម្រោង

៣. ផ្នែកនេះ នឹងផ្តល់នូវការពិពណ៌នាទូទៅអំពីគម្រោង ការបង្ហាញអំពីសមាសភាគគម្រោង និងសកម្មភាពទាំងឡាយដែលអាចបង្កផលប៉ះពាល់លើជនជាតិដើមភាគតិច និងការកំណត់ទីតាំងអនុវត្តគម្រោង។

### គ. ការវាយតម្លៃផលប៉ះពាល់សង្គម

៤. ផ្នែកនេះ គឺសំដៅលើ៖

(១). ការពិនិត្យឡើងវិញលើក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលអាចអនុវត្តចំពោះជនជាតិដើមភាគតិចនៅក្នុងបរិបទគម្រោង។

(២). ការផ្តល់ព័ត៌មានជាមូលដ្ឋានអំពីលក្ខណៈប្រជាសាស្ត្រ សង្គម វប្បធម៌ និងនយោបាយរបស់ក្រុមសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និងទឹកដីដែលពួកគាត់ធ្លាប់មាន ឬប្រើប្រាស់ជាលក្ខណៈប្រពៃណី ឬកាន់កាប់ និងធនធានធម្មជាតិដែលពួកគាត់អាស្រ័យលើ។

(៣). ការកំណត់ឱ្យឃើញអ្នកពាក់ព័ន្ធសំខាន់ៗក្នុងគម្រោង និងពន្យល់ពីដំណើរការដែលមានលក្ខណៈសមស្របទៅតាមវប្បធម៌ និងបញ្ហាយេនឌ័រ សម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិច នៅក្នុងដំណាក់កាលនីមួយៗនៃការរៀបចំ និងការអនុវត្តគម្រោង ដោយការគិតគូពិចារណាទៅលើការត្រួតពិនិត្យឡើងវិញ និងលើព័ត៌មានជាមូលដ្ឋាន។

(៤). ការវាយតម្លៃផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានសំខាន់ៗរបស់គម្រោងនេះ ដោយផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់។ កត្តាសំខាន់ក្នុងការកំណត់ផលប៉ះពាល់អវិជ្ជមានសំខាន់ៗដែលអាចកើតមាន គឺការវិភាគលើបញ្ហាយេនឌ័រទាក់ទងនឹងភាពងាយរងគ្រោះ និងហានិភ័យចំពោះជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ដែលកំពុងស្ថិតក្នុងស្ថានភាពជាក់លាក់នានារបស់ខ្លួន និងទំនាក់ទំនងជិតស្និទ្ធទៅនឹងការប្រើប្រាស់ដីធ្លី និងធនធាន

ធម្មជាតិ ព្រមទាំងកង្វះការទទួលបានឱកាស ដែលជាឱកាសមានសម្រាប់តែក្រុមផ្សេងទៀតនៅក្នុងសហគមន៍ ឬសង្គមជាតិដែលពួកគេកំពុងរស់នៅ។

(៥). ការរួមបញ្ចូលទាំងការវាយតម្លៃលើបញ្ហាយេនឌ័រតាមទស្សនៈយល់ឃើញរបស់ក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយសារគម្រោង និងផលប៉ះពាល់នៃបញ្ហាយេនឌ័រនេះមកលើស្ថានភាពសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់ពួកគេ។

(៦). ការកំណត់ឱ្យឃើញ និងផ្តល់ជាអនុសាសន៍ ដោយផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាមួយជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និងផ្អែកលើវិធានការចាំបាច់ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ប៉ុន្តែប្រសិនបើវិធានការនេះមិនអាចធ្វើទៅបាន ចាំបាច់ត្រូវតែកំណត់វិធានការទាំងឡាយណាដែលអាចបន្ធូរបន្ថយ កាត់បន្ថយ និង/ឬផ្តល់សំណងចំពោះផលប៉ះពាល់ទាំងនោះ និងត្រូវតែធានាថាជនជាតិដើមភាគតិចពិតជាបានទទួលអត្ថប្រយោជន៍សមស្របទៅតាមលក្ខណៈវប្បធម៌ ក្រោមក្របខ័ណ្ឌអនុវត្តគម្រោងនេះ។

## ឃ. ការបញ្ចេញព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម

៥. ផ្នែកនេះ គឺសំដៅលើ៖

(១). ការពិពណ៌នាអំពីការបញ្ចេញព័ត៌មាន ដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល ដែលត្រូវបានធ្វើឡើងអំឡុងពេលរៀបចំគម្រោង។

(២). ការសង្ខេបអំពីមតិយោបល់របស់ពួកគាត់លើលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់សង្គម និងការកំណត់ឱ្យឃើញចំពោះការព្រួយបារម្ភ ដែលបានលើកឡើងក្នុងការពិគ្រោះយោបល់ និងរបៀបដោះស្រាយបញ្ហាទាំងនេះ។

(៣). ក្នុងករណីដែលសកម្មភាពគម្រោង តម្រូវឱ្យមានការចូលរួមគាំទ្រឱ្យបានទូលំទូលាយពីសហគមន៍ចាំបាច់ត្រូវរៀបចំឯកសារអំពីដំណើរការ និងលទ្ធផលនៃការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និងការព្រមព្រៀងណាមួយដែលជាលទ្ធផលបានពីការពិគ្រោះយោបល់នោះ សម្រាប់សកម្មភាព និងវិធានការការពាររបស់គម្រោង ក្នុងការដោះស្រាយផលប៉ះពាល់ទាំងនោះ។

(៤). ការពិពណ៌នាអំពីយន្តការក្នុងការពិគ្រោះយោបល់ និងក្នុងការចូលរួមដែលត្រូវអនុវត្ត សំដីធានាឱ្យមានការចូលរួមរបស់ជនជាតិភាគតិចក្នុងអំឡុងពេលអនុវត្តគម្រោង។

(៥) ការបញ្ជាក់លើការបញ្ចេញព័ត៌មានអំពីផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (EMDP) (ទាំងផែនការ ព្រាង និងផែនការចុងក្រោយ) ទៅដល់ជនជាតិដើមភាគីតិចដែលរងផលប៉ះពាល់។

## ខ. វិធានការការពារផលប្រយោជន៍

៦. ផ្នែកនេះ នឹងបញ្ជាក់ពីវិធានការដើម្បីធានាថាជនជាតិដើមភាគតិចទទួលបាននូវអត្ថប្រយោជន៍សេដ្ឋកិច្ច និងសង្គមសមស្របទៅតាមលក្ខណៈវប្បធម៌ ហើយដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។

## ច.  វិធានការកាត់បន្ថយ

៧. ផ្នែកនេះ នឹងបញ្ជាក់ពីវិធានការដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច ហើយក្នុងករណីមិនអាចបញ្ចៀសបានទេនោះ ចាំបាច់ត្រូវបញ្ជាក់ពីវិធានការបន្ធូរបន្ថយ ឬកាត់បន្ថយ និងផ្តល់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមានទាំងនោះទៅដល់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ម្នាក់ៗ។

## ឆ.  ការកសាងសមត្ថភាព

៨. ដោយសារតែជាគម្រោងនេះពាក់ព័ន្ធលើផ្នែកប្រព័ន្ធខ្សែច្រវាក់តម្លៃសត្វដៃរនោះ ដូច្នេះនឹងអាចមានឱកាសតិចតួចសម្រាប់ការកសាងសមត្ថភាពទូទៅរបស់ក្រុមជនជាតិដើមភាគតិច ជនជាតិភាគតិច ហើយអ្វីដែលអាចផ្តល់ជូនជាកសាងសមត្ថភាពចម្បងនោះ គឺផ្នែកបច្ចេកទេស។ ផ្នែកនេះ គឺជាការព្យាយាមផ្តល់វិធានការដើម្បីពង្រឹងសមត្ថភាពរបស់អ្នកចូលរួមក្នុងអនុគម្រោងដែលជាជនជាតិដើមភាគតិច ឬជនជាតិភាគតិច ឱ្យទទួលបានគុណប្រយោជន៍ពីសកម្មភាពគាំទ្រដោយគម្រោង និងទទួលបានផលប្រយោជន៍ជាអតិបរមា ជាពិសេសពីវិស័យកសិកម្ម និងការបណ្តុះបណ្តាលសមត្ថភាពផ្សេងៗដែលនឹងត្រូវផ្តល់ជូន។

## ជ.  យន្តការដោះស្រាយបណ្តឹងតវ៉ា

៩. ផ្នែកនេះ នឹងបរិយាយអំពីនីតិវិធីដោះស្រាយបណ្តឹងតវ៉ាទាំងឡាយណាធ្វើឡើងដោយក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់។ ផ្នែកនេះក៏នឹងពន្យល់ពីរបៀបដោះស្រាយបណ្តឹងតវ៉ាសម្រាប់ក្រុមជនជាតិដើមភាគតិច ដែលមានលក្ខណៈសមស្របទៅតាមវប្បធម៌ ហើយដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។

## ឈ.  ការរៀបចំស្ថាប័ន

១០. ផ្នែកនេះ នឹងពិពណ៌នាពីទំនួលខុសត្រូវលើការរៀបចំស្ថាប័ន និងយន្តការសម្រាប់អនុវត្តវិធានការនានានៃផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (EMDP)។ ផ្នែកនេះ ក៏នឹងពិពណ៌នាអំពីដំណើរការនៃការចូលរួមរបស់អង្គការក្នុងមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តវិធានការនៃផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP) នេះ ប្រសិនបើមាន។

## ញ.  ការត្រួតពិនិត្យតាមដាន ការរាយការណ៍ និងការវាយតម្លៃ

១១. ផ្នែកនេះ នឹងពិពណ៌នាអំពីយន្តការ និងចំណុចគោលដែលសមស្របទៅនឹងគម្រោងនេះ សម្រាប់ត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP)។ ផ្នែកនេះ ក៏នឹងបញ្ជាក់អំពីការរៀបចំឱ្យមានការចូលរួមពីក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់នៅក្នុងដំណើរការរៀបចំ និងការកំណត់របាយការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

## ដ.  ថវិកា និងការផ្តល់ហិរញ្ញប្បទាន

១២. ផ្នែកនេះ នឹងពិពណ៌នាអំពីថវិកាដែលជាមុខចំណាយខុសៗគ្នាសម្រាប់សកម្មភាពទាំងអស់ដែលបានពិពណ៌នានៅក្នុងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (EMDP) នេះ។

## ឧបសម្ព័ន្ធទី 4. គំរូឧទាហរណ៍នៃការពិភាក្សាជាក្រុម (FGD) ដែលបានសម្របសម្រួល ក្នុងអំឡុងពេលចុះត្រួតពិនិត្យផ្នែកបច្ចេកទេស TRTA

**ទីតាំង៖** ភូមិបឹងត្រាវី ឃុំស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម

| | |
|---|---|
| **កាលបរិច្ឆេទ៖** | ថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០២១ |
| **ពេលវេលា៖** | ១៤:៣០ - ១៧:៣០ រសៀល |
| **អ្នកចូលរួម៖** | អ្នកភូមិចំនួន ២២នាក់ (ស្រី ១០នាក់ ប្រុស ១២នាក់), មេភូមិ (ប្រុស) |
| **អ្នកសង្កេតការណ៍៖** | បុគ្គលិក GDHAP និង PDAFF (ប្រុសទាំង ៥នាក់) |
| **អ្នកសម្របសម្រួល៖** | អ្នកជំនាញជាតិផ្នែកយេនឌ័រ, TRTA |
| **ធនធានមនុស្ស៖** | អ្នកជំនាញអន្តរជាតិផ្នែកគាំពារសង្គម, TRTA |
| **ភាសា៖** | ចាម និងខ្មែរ |

---

១. បន្ទាប់ពីពិភាក្សាជាមួយ GDHAP និង PDAFF ក្រុមការងារជំនួយបច្ចេកទេស TRTA បានសម្រេចថាពិតជាមានសារៈសំខាន់ណាស់ក្នុងការសម្របសម្រួលឱ្យមានការភិភាក្សាជាក្រុម (FGD) ជាមួយជនជាតិចាមឥស្លាមដែលជាអ្នកចិញ្ចឹមសត្វនៅក្នុងភូមិនានានៃខេត្តកំពង់ចាម។ ក្រៅពីជាជនជាតិភាគតិច ក៏នៅមានជាលក្ខខណ្ឌតម្រូវនៃគោលការណ៍ការពាររបស់ ADB ដើម្បីកំណត់គោលដៅក្រុមជនជាតិភាគតិចផងដែរ ដែលការបញ្ជាក់នេះត្រូវបានធ្វើឡើងដោយអ្នកជំនាញអន្តរជាតិទទួលបន្ទុកផ្នែកគាំពារសង្គម TRTA។ គួរកត់សម្គាល់ផងដែរថា ក្រុម TRTA កាលពីដើមឆ្នាំបានចុះពិនិត្យជាក់ស្តែងនៅតាមភូមិចាមមួយចំនួនក្នុងខេត្តកំពង់ចាម។ ប៉ុន្តែដោយសារស្ថានភាពកូវីដ-១៩ ទើបគេមិនអាចចំណាយពេលបានច្រើនធ្វើដំណើរឆ្លងកាត់ពីស្រុកមួយទៅស្រុកមួយក្នុងខេត្តកំពង់ចាម ដើម្បីសម្រួលដល់ការរៀបចំការពិភាក្សាជាក្រុម តាមតម្រូវការបានទេ។ ការពិភាក្សាជាក្រុម (FGD) នេះត្រូវបានរៀបចំឡើងទាំងស្រុងដោយក្រុមបច្ចេកទេស TRTA ប៉ុន្តែក៏ត្រូវបានដឹកនាំដោយអតីតភ្នាក់ងារពេទ្យសត្វភូមិម្នាក់ដែលស្គាល់សហគមន៍ទាំងនេះយ៉ាងច្បាស់ផងដែរ។ ជារួម មានការអះអាងថាស្ត្រីជនជាតិចាម មានឋានៈតិចជាងស្ត្រីខ្មែរ។ ទន្ទឹមនឹងនេះយើងបានរកឃើញថាមិនមានការជំទាស់ចំពោះការអញ្ជើញពួកគេ ដោយបន្ទាន់ភ្លាមៗឱ្យចូលរួមក្នុងការពិភាក្សាជាក្រុមនោះទេ ប៉ុន្តែយ៉ាងណាក៏ដោយ បុគ្គលិកនៃអគ្គនាយកដ្ឋាន GDHAP បានណែនាំឱ្យស្គាល់ក្រុមបង្គោល និងបានពន្យល់ពីគោលបំណងនៃការពិភាក្សាជាក្រុម និងសុំអភ័យទោសចំពោះការជូនដំណឹងបន្ទាន់បែបនេះ។ ការអញ្ជើញពួកគាត់ឱ្យចូលរួមក្នុងការពិភាក្សាជាក្រុមនេះ មិនបានបង្កការរំខានអ្វីដល់ពួកគាត់ទេ ប៉ុន្តែពួកគេពិតជារីករាយដែលបានការចូលរួមក្នុងការពិភាក្សា គ្រាន់តែថាសោកស្តាយដែលមនុស្សពេញវ័យជាច្រើននាក់មិនបានចូលរួម ដោយសារពួកគេជាប់រវល់ក្នុងការងារស្រែចម្ការ និងការនេសាទនៅខាងក្រៅភូមិ។

២. អ្នកសម្របសម្រួល TRTA ចង់ឱ្យបុគ្គលិកធនធាន TRTA ជួយសម្រួលដល់ការពិភាក្សាជាក្រុម (FGD) ដោយសារតែគាត់មិនសូវមានចំណេះដឹងអំពីសង្គមឥស្លាមនៅតាមជនបទ និងព្រួយបារម្ភក្រែងមានការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវ ឬការធ្វើសារខុសៈ យើងចង់ឱ្យសហគមន៍មូលដ្ឋានបានឃើញថា ស្ត្រីស្ថិតនៅជួរមុខនៃសកម្មភាពគម្រោង ហើយស្ត្រីក៏ត្រូវបានកំណត់ជាគោលដៅរបស់គម្រោងផងដែរ។ ទន្ទឹមនឹងនេះ អ្នកសម្របសម្រួល

TRTA (អ្នកស្រី) បានពន្យល់យ៉ាងខ្លី និងយ៉ាងសាមញ្ញអំពីអត្ថន័យនៃការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងនេះ ហើយស្ត្រីទាំងអស់មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះអ្វីដែលអ្នកសម្របសម្រួលរូបនេះបានលើកឡើងដូច្នេះ។ ម្យ៉ាងទៀត អ្នកសម្របសម្រួលរូបនេះបានប្រាប់ដល់ក្រុមស្ត្រីទាំងនោះដូច្នេះថា ប្រសិនបើអ្នកបាន អានត្រង់ចំណុចដែលរៀបរាប់អំពីការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាពដែលមាននៅក្នុងឯកសាររបាយការណ៍របស់ ADB អ្នកទាំងអស់គ្នាអាចនឹងយល់ច្រលំបន្តិចបន្តួចដែរ។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រីក៏បានអះអាងដែរថា ឯកសារនោះមានរួមបញ្ចូលពីយុទ្ធសាស្ត្រ និងគោលនយោបាយសំខាន់ៗ ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីដែលរស់នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា រួមទាំងស្ត្រីជនជាតិចាមឥស្លាមនៅក្នុងភូមិនេះ ដែលអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងផងដែរ។

៣. នៅក្នុងកាលៈទេសៈជួបជុំគ្នានេះ អ្នកចូលរួមក្នុងការពិភាក្សាជាក្រុម (FGD) មួយចំនួន បានចោទសួរថាតើសកម្មភាពវិនិយោគប្រភេទណាដែលគម្រោងនឹងគាំទ្រ ក្រៅពីអ្វីដែលអ្នកសម្របសម្រួល TRTA បានរៀបរាប់ ហើយបុគ្គលិកធនធាន TRTA បានចោទសួរអ្នកតំណាង GDHAP ថាតើគាត់មានបំណងចង់ចុះបញ្ជីការវិនិយោគលើការរៀបចំក្រោលសត្វ ការផ្ទុកចំណី ការគ្រប់គ្រងសំណល់ ការគ្រប់គ្រង ការវេចខ្ចប់ ការអភិរក្ស និងការស្តុកទុក ការកែច្នៃ និងទីផ្សារផលិតផលសត្វ ដែរឬទេ។ មានការសង្កត់ធ្ងន់ផងដែរថា ក្រុមអ្នកផលិត ឬអ្នកចិញ្ចឹមនឹងអាចទទួលបានតម្លៃខ្ពស់ជាងនេះទៀត ប្រសិនបើពួកគេអាចផលិតបានកាន់តែច្រើន ជាជាងការធ្វើទីផ្សារផលិតកម្មសត្វដែលមានជាក់ស្តែង។ អ្នកចូលរួមក្នុងការពិភាក្សាជាក្រុម ពិតជាមានការចាប់អារម្មណ៍ចំពោះការពន្យល់ពីបុគ្គលិក GDHAP ហើយពួកគេបានលើកឡើងជាយោបល់ថា ប្រសិនបើបុគ្គលិកគ្រប់គ្នានៅក្នុងអគ្គនាយកដ្ឋាន GDHAP អាចធ្វើបានស្រដៀងគ្នានឹងបុគ្គលិកទាំងឡាយដែលបានចូលរួមសង្កេតមើលការពិភាក្សាជាក្រុមនេះ នោះកម្មវិធីគម្រោងអាចទទួលបានជោគជ័យច្រើន។

៤. បុគ្គលិកធនធាន TRTA បានគូសបញ្ជាក់អំពីអ្វីដែលកំពុងត្រូវបានពិចារណាផងដែរសម្រាប់ការគាំទ្រជាសម្ភារៈថ្មីៗសម្រាប់បន្ថែមតម្លៃផលិតកម្មសត្វ (ដូចជារទេះដាក់ចំណីចល័ត ទ្រុងដាក់សត្វ ជញ្ជីងថ្លឹងសត្វ អាងផឹកទឹកសត្វ ប្រព័ន្ធចំណីសត្វរាវសម្រាប់មាន់ទា កន្លែងស្តុកចំណីសត្វ និងប្រព័ន្ធស្រោចទឹក) និងគ្រឿងបន្លាស់ថ្មីៗ ឬគ្រឿងបំពាក់បន្ថែមសម្រាប់គ្រឿងចក្រ យានជំនិះ ឬឧបករណ៍ផ្សេងៗទៀត។ បុគ្គលិកធនធាន TRTA ក៏បានលើកឡើងពីសកម្មភាពដែលមិនត្រូវបានគាំទ្រពីគម្រោងផងដែរ ប៉ុន្តែពាក់ព័ន្ធនឹងការប្រើប្រាស់ដីដោយស្ម័គ្រចិត្តដូចជាការទិញដីដែលពួកគាត់ប្រកែកគ្នាមិនគួរជាការបារម្ភអ្វីនោះទេ ប៉ុន្តែអ្វីដែលបារម្ភនោះគឺការហាមប្រាមចំពោះសកម្មភាពគ្រប់ប្រភេទដែលខុសនឹងទំនៀមសាសនា។ សម្រាប់ការក្បួនសាសនាតាមបែបហាឡាល់ (Halal) ការសម្លាប់សត្វពាហនៈមានសារៈសំខាន់ជានិមិត្តរូបតាមទស្សនៈរបស់ឥស្លាម ប៉ុន្តែវាក៏មានលក្ខណៈមនុស្សធម៌ជាងអ្វីដែលពួកគេបានសង្កេតឃើញនៅក្នុងការសម្លាប់ដែលធ្វើឡើងដោយអ្នកមិនមែនជាជនជាតិមូស្លីមនៅកម្ពុជា។ ពួកគេបានលើកឡើងដូច្នេះថា ការសម្លាប់ខុសក្បួនសាសនាបែបនេះ បង្ហាញពីការយល់ដឹងមិនពេញលេញអំពីជនជាតិចាមឥស្លាម ហើយពួកគេតែងតែលើកឡើងពីបញ្ហានេះម្តងហើយម្តងទៀត។

៥.	ស្ត្រីទាំងអស់ដែលបានចូលរួមក្នុងក្រុមពិភាក្សាបាននិយាយថា ទោះបីជាអ្វីដែលអាចនិយាយបានអំពីស្ត្រីឥស្លាមចាមក៏ដោយ ពួកគេមិនត្រូវបានទុកចោលមិនអើពើពីបុរសចាមឥស្លាមនោះដែរ៖ អ្នកដែលបានប្រកែកតតាំងគឺដោយសារពួកគេដឹងតិចតួចណាស់អំពីទំនាក់ទំនងយេនឌ័រពិតប្រាកដ នៅក្នុងសហគមន៍ជនបទរបស់ពួកគេ។ បុគ្គលិកធនធាន TRTA បាននិយាយថាគាត់បានអានសំណេរអក្សរសិល្ប៍ដែលបង្ហាញថាស្ត្រីជនជាតិចាមមូស្លីមហាក់ដូចជាជួបការលំបាកដោយសារការមិនត្រូវអើពើ ហេតុដូច្នេះគម្រោងចាំបាច់ត្រូវយល់ឱ្យបានច្បាស់ពីការពិតជាពិសេសចំពោះអ្វីដែលស្ត្រីខ្លួនឯងប្រកែកតវ៉ា។ ជាចុងក្រោយ អ្នកចូលរួមក្នុងក្រុមពិភាក្សាទាំងអស់បាននិយាយថាពួកគេពេញចិត្តចំពោះការពិភាក្សាជាក្រុមបែបនេះតទល់មុខគ្នា និងមានសារៈសំខាន់ស្មើគ្នា ហើយមិនចង់ពិភាក្សាតាមអ៊ីនធឺណែត ឬតាមអនឡាញនោះទេ។

## ឧបសម្ព័ន្ធទី 5. សន្ទេបបទសម្ភាសន៍ជាមួយអ្នកជំនាញ ជាមួយប្រធានសហគមន៍ចាម

(នៅខេត្តកំពង់ចាម ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២)

| | |
|---|---|
| តើនេះជាប្រភេទគម្រោងដែលអាចឱ្យកសិករចិញ្ចឹមសត្វចូលរួមក្នុងប្រព័ន្ធខ្សែច្រវាក់តម្លៃកសិកម្ម និងទទួលបានអត្ថប្រយោជន៍តាមបរិមាណ ដែរឬទេ? | យើងចង់ឃើញកសិករចិញ្ចឹមសត្វទទួលបានជោគជ័យ ប៉ុន្តែមានបញ្ហាកាន់តែច្រើនទាក់ទងនឹងការធ្វើពាណិជ្ជកម្មលក់ដូរ ក្នុងវិស័យផលិតកម្មសត្វក្នុងខេត្តឧត្តរមានជ័យ។ បញ្ហាទី ១ កសិករចិញ្ចឹមសត្វរបស់យើងត្រូវប្រកួតប្រជែងជាមួយកសិករដែលនាំសត្វឆ្លងកាត់ព្រំដែន ហើយរដ្ឋាភិបាលនៅទីនោះមានតួនាទីផ្តល់ការគាំទ្រកាន់តែច្រើនឡើងៗ។ ក៏នៅមានបញ្ហាទាក់ទងនឹងសុខភាពសត្វ ការបែងចែកដីធ្លី ចំណេះដឹងរបស់កសិករ និងជំនួយពីរដ្ឋាភិបាលផងដែរ។ យ៉ាងណាមិញ គម្រោងនេះគឺជាគម្រោងមួយដែលមានសុភវិនិច្ឆ័យច្បាស់លាស់បំផុតសម្រាប់ការអនុវត្តនៅក្នុងខេត្តនេះ។ |
| ធ្លាប់មានការស្នើឱ្យបង្កើតមជ្ឈមណ្ឌលជាតិបង្កាត់ពូជគោ និងស្ថានីយបង្កាត់ពូជសិប្បនិម្មិតនៅខេត្តតាកែវ៖ តើនេះជាគំនិតល្អដែរទេ? | នេះជាគំនិតល្អណាស់ ព្រោះនៅមជ្ឈមណ្ឌលជាតិបង្កាត់ពូជគោខេត្តតាកែវ គេមិនបង្កាត់ពូជជ្រូកទេ។ ជាគោលការណ៍ហារ៉ាមសម្រាប់ប្រជាជនម៉ូស្លីមក្នុងការចិញ្ចឹមសត្វពាហនៈដែលត្រូវបានបង្កាត់ពូជ និងអាចជាកន្លែងដែលជ្រូកក៏ត្រូវបានបង្កាត់ផងដែរ។ តាមច្បាប់សារីយ៉ាស (Shariah Law) មិនហាមឃាត់ចំពោះការបង្កាត់ពូជសិប្បនិម្មិតចំពោះសត្វចិញ្ចឹមទេ។ ទោះបីជាបុគ្គលមិនមែនជាមូស្លីមមួយចំនួនគិតថាក្រឹត្យថ្កោលទោសហ្វាតវ៉ា (Fatwa) អាចត្រូវបានចេញសម្រាប់បច្ចេកវិទ្យាបង្កាត់ពូជសិប្បនិម្មិតរបស់មនុស្សក៏ដោយ។ នោះក៏មិនត្រឹមត្រូវដែរ យ៉ាងហោចណាស់នៅទីនេះក្នុងប្រទេសកម្ពុជាក្នុងចំណោមអ្នកកាន់សាសនាចាម។ |
| ការលើកកម្ពស់ប្រព័ន្ធខ្សែច្រវាក់តម្លៃសត្វដែលអាចជោគជ័យបាន ទាមទារឱ្យមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់៖ តើអ្នកយល់យ៉ាងណាចំពោះហេដ្ឋារចនាសម្ព័ន្ធបែបនេះនៅក្នុងខេត្តកំពង់ចាម? | ក្នុងនាមជាអ្នកកាន់សាសនាឥស្លាម ខ្ញុំមិនអាចទទួលយកបានទេចំពោះការសម្លាប់សត្វគោ ឬសត្វមាន់ទា នៅក្នុងកន្លែងណាមួយ មានការសម្លាប់សត្វជ្រូកដែរ។ នេះជាការមិនអាចទទួលយកបានទាំងស្រុងសម្រាប់អ្នកកាន់សាសនាឥស្លាម។ ជាងនេះទៅទៀត ចំពោះសត្វគោនិងមាន់ទារបស់ឥស្លាម ត្រូវតែសម្លាប់តាមក្បួនហាឡាល់ ហើយខ្ញុំមិនបានលើកឡើងអំពីចំណុចនេះនៅក្នុងលក្ខខណ្ឌតម្រូវរបស់ GMP និង HACCP ដែលជាស្តង់ដាល្អនោះទេ ប៉ុន្តែប្រសិនបើកម្ពុជាចង់នាំចេញផលិតផលសាច់ហាឡាល់ទៅកាន់ប្រទេសអាស៊ានផ្សេងទៀត។ ក្នុងប្រទេសថៃ រដ្ឋាភិបាល និងអ្នកកែច្នៃផលិតផលសាច់ហាឡាល់បានសហការគ្នាយ៉ាងល្អ ដើម្បីធានាថាប្រទេសថៃមានកេរ្តិ៍ឈ្មោះជាអ្នកផលិតដែលមានការបញ្ជាក់ទទួលស្គាល់ចំពោះផលិតផលសាច់ហាឡាល់នេះ។ ចំណុចនេះជំរុញឱ្យមានការធ្វើពាណិជ្ជកម្មច្រើនផងដែរ ដោយសារតែប្រទេសថៃអាចធ្វើទីផ្សារផលិតផលសត្វរបស់ខ្លួននៅក្នុងប្រទេសកាន់សាសនាឥស្លាម ដោយគ្មានការពិបាកណាមួយឡើយ។ |

| | |
|---|---|
| យើងដឹងថាបញ្ហាសុខភាពសត្វមានសារៈសំខាន់ណាស់ ប៉ុន្តែតើអ្នកយល់យ៉ាងណាចំពោះមន្ទីរពិសោធន៍រោគវិនិច្ឆ័យសត្វ ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលជាតិផលិតវ៉ាក់សាំងនៅខេត្តតាកែវ? | នេះជាបញ្ហាគួរឲ្យចាប់អារម្មណ៍សម្រាប់អ្នកកាន់សាសនាឥស្លាម។ ប្រជាជនម៉ូស្លីមនិយមកាន់តែច្រើនត្រូវបានប្រឆាំងទៅនឹងវ៉ាក់សាំងជាច្រើន លុះត្រាតែវាច្បាស់ថាផលិតផលសត្វអ្វីអាចប្រើប្រាស់បាន ព្រោះវាជាក្បួនហាម៉ាមដើម្បីប្រើវ៉ាក់សាំងដែលរួមបញ្ចូលផលិតផលសាច់ជ្រូក។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលអ្នកបានឃើញហើយថា ជនជាតិចាមមានភាពរហ័សរហួនក្នុងការទទួលថ្នាំបង្ការប្រឆាំងនឹងជំងឺកូវីដ-១៩។ យើងអាចមើលទៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី បង់ក្លាដែស ប៉ាគីស្ថាន និងអារ៉ាប៊ីសាអូឌីត ឬសូម្បីតែអ្នកកាន់សាសនាឥស្លាមនៅភាគខាងត្បូងប្រទេសថៃ។ ដូច្នេះ ជាទូទៅ ខ្ញុំគិតថា សំណើនេះគឺល្អណាស់ ទោះបីជាខ្ញុំគិតថាការរៀបចំឱ្យមានមន្ទីរពិសោធន៍រោគវិនិច្ឆ័យសត្វនៅក្នុងខេត្តកំពង់ចាម ក៏ជាគំនិតល្អមួយដែរ។ |
| តើអ្នកអាចកំណត់ចំពោះសេវាផលិតកម្មសត្វ ដែលនឹងត្រូវទទួលបានជាប្រយោជន៍ពីសកម្មភាពកសាងសមត្ថភាពដែរឬទេ? ហើយអ្នកណាគួរតែទទួលបានសេវានេះ? | ខ្ញុំចង់ឃើញសកម្មភាពកសាងសមត្ថភាពដែលនឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកចិញ្ចឹមសត្វទាំងអស់ រួមទាំងយើងជាជនជាតិចាមឥស្លាមផងដែរ។ ខ្ញុំមិនចង់រិះគន់បុគ្គលិកមន្ទីរកសិកម្មខេត្តនោះទេ ប៉ុន្តែខ្ញុំគិតថាមនុស្សជាច្រើនក្នុងភូមិសុទ្ធតែបានចេះដឹងអំពីការអនុវត្តការចិញ្ចឹមសត្វច្រើនជាងមន្ត្រីទាំងនៅផង។ យ៉ាងណាក៏ដោយ ខ្ញុំទទួលស្គាល់ថាមានបុគ្គលិកល្អៗចេះដឹងច្រើនមួយចំនួននៅក្នុងមន្ទីរកសិកម្មខេត្ត។ សំណួរសំខាន់ដែលខ្ញុំចង់សួរ គឺថាតើអ្វីទៅដែលពួកគេហៅថា "ការវាយតម្លៃតម្រូវការបណ្តុះបណ្តាលដោយមានការចូលរួម"? នៅក្នុងភូមិចាមរបស់យើង យើងសូមអរគុណចំពោះអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានបានប្រើប្រាស់វិធីសាស្ត្រល្អៗ ក្នុងការវាយតម្លៃពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រជាពលរដ្ឋដែលចូលរួមក្នុងសកម្មភាពចិញ្ចឹមជីវិតដោយពឹងផ្អែកលើដីធ្លី។ |
| គម្រោងនេះស្នើឱ្យមានការគាំទ្រសេវាសុខភាពសត្វ និងសុវត្ថិភាពចំណីអាហារដោយប្រើប្រព័ន្ធ ICT ៖ តើអ្នកគិតថាវាអាចទៅរួចដែរទេ? | ខ្ញុំឃើញគម្រោងនេះកំពុងនិយាយអំពីការចាប់យកទិន្នន័យលើការកំណត់អត្តសញ្ញាណសត្វ និងសត្តឃាតផងដែរ។ តើនេះអាចមានន័យថាសកម្មភាពរបស់ជនជាតិចាមក្នុងដំណើរការសត្តឃាត នឹងត្រូវបានត្រួតពិនិត្យដែរឬទេ? ជាការពិតណាស់ យើងចាប់អារម្មណ៍លើសុវត្ថិភាពចំណីអាហារ ប៉ុន្តែយើងមិនប្រាកដចំពោះការឃ្លាំមើលនោះទេ។ |
| គម្រោងនេះ ស្នើឡើងនូវអ្វីដែលសំដៅទៅលើការអនុញ្ញាតឱ្យមានជាគោលនយោបាយសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ សុខភាព សុវត្ថិភាព និងពាណិជ្ជកម្មសត្វ និងផលិតផលសត្វ។ តើអ្នកយល់ឃើញយ៉ាងណាដែរចំពោះចំណុចនេះ? | បំណងប្រាថ្នាធំរបស់ខ្ញុំ គឺចង់បានគោលនយោបាយណាមួយដែលបង្កើតឡើងដើម្បីបម្រើផលប្រយោជន៍រួមសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ដោយមិនគិតពីសាវតាជនជាតិ ឬជំនឿសាសនា ដើម្បីធ្វើឱ្យការចិញ្ចឹមសត្វបានប្រព្រឹត្តទៅដោយយុត្តិធម៌។ |

| | |
|---|---|
| ដោយសារនេះជាគម្រោងផ្តល់មូលនិធិរបស់ ADB បញ្ហាដែលទាក់ទងនឹងយេនឌ័រ ភាពក្រីក្រ និងជនជាតិភាគតិច ចាំបាច់ត្រូវតែដោះស្រាយ៖ តើអ្នកអាចផ្តល់មតិអ្វីខ្លះលើបញ្ហាទាំងនេះ? | ខ្ញុំបានអានសេចក្តីថ្លែងគោលនយោបាយការពាររបស់ ADB ស្តីពីផលប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយស្ម័គ្រចិត្ត និងលើជនជាតិដើមភាគតិច។ យើងមិនមែនជាជនជាតិដើមនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែយើងជាជនជាតិភាគតិច ដូច្នេះត្រូវតែរួមបញ្ចូលពួកយើងនៅក្នុងការការពារសម្រាប់ជនជាតិដើមភាគតិច។ ខ្ញុំដឹងថាតើគម្រោងនឹងអាចជួយឱ្យអ្នកក្រ រួចផុតពីភាពក្រីក្រដែរឬអត់នោះទេ! ប៉ុន្តែរឿងមួយដែលខ្ញុំចេះតែឆ្ងល់ថាហេតុអ្វីបានជានៅក្នុងគម្រោងផ្សេងទៀតនៅក្នុងខេត្តកំពង់ចាមនេះ គេមិនបានលើកឡើងពីជនជាតិចាមដូច្នេះ។ |
| មានបញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងប្រព័ន្ធចិញ្ចឹមសត្វ ដូច្នេះតើអ្នកគិតថាអាចអនុវត្តបានចំពោះគម្រោងបែបនេះដែរឬទេ? | នៅក្នុងសាសនាឥស្លាម យើងមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបញ្ហាបរិស្ថាន។ យើងជឿថា គម្ពីរកូអាន (Qur'an) ទទួចជាពិសេសឱ្យយើងចេះថែរក្សាបរិស្ថាន ប៉ុន្តែយើងក៏គិតដែរថាសាសនាទាំងអស់ គឺស្រដៀងគ្នាចំពោះបញ្ហានេះ។ មិនមែន ព្រះទេដែលជាអ្នកបំផ្លាញបរិស្ថាន ប៉ុន្តែគឺមនុស្សដែលលោភលន់ និងគិតតែពីចង់មានចង់បានហួសហេតុ។ |
| តើអ្នកមានគំនិត ឬយោបល់ណាមួយដែលគម្រោងអាចយកមកពិភាក្សា មុនពេលបញ្ចប់ការរៀបចំគម្រោង និងដើម្បីត្រៀមខ្លួនសម្រាប់ការអនុវត្តនាពេលខាងមុខ? | សូមជួយជានាឱ្យបានប្រាកដថា ជនជាតិចាម រួមទាំងជនជាតិចាមមូស្លីម ត្រូវបានរួមបញ្ចូលនៅក្នុងសកម្មភាពគម្រោង។ ទាំងក្តីកង្វល់របស់យើង និងក្តីប្រាថ្នារបស់យើង ត្រូវបានបញ្ជាក់យ៉ាងច្បាស់រួចរាល់អស់ហើយ។ |